ជំនួសឲ្យការហែកបំបែកទំនាក់ទំនងពីគ្នា ជម្លោះក្លាយជាឈ្នាន់ថ្មីសំរាប់ជាន់ចូលទៅក្នុងទំនាក់ទំនងផ្ទាល់ខ្លួនដ៏សែនជ្រៅ ។ ការរីកចំរើន និង ការផ្លាស់ប្តូរមិនមែនកើតឡើងដោយស្វ័យប្រវត្តិទេ ។ ពួកវាចេញមកពីការខំប្រឹងប្រែង ដែលយើងធ្វើឡើង ដើម្បីដោះស្រាយបញ្ហារបស់យើង ។

ការផ្សះផ្សាគឺជាសមិទ្ធផលមួយដ៏មានគុណភាពខ្ពស់ ។ តួនាទីភាគីទី ៣ សំខាន់ណាស់ ។ បើសិនជាអ្នកស្ថិតនៅក្នុងមុខងារភាគីទី ៣ ចូរអ្នកបញ្ជាក់ច្បាស់ថាហេតុអ្វីបានជាអ្នកនៅទីនោះ ។ ទោះជាមិនបានគិតក៏ដោយ ក៏គូរភាគីដែលធ្វើសង្គ្រាមស្វែងរកមើលចំណុចរួមគ្នាមួយ ដើម្បីយកមកជាសំអាងនៃការព្រមព្រៀង គឺសូម្បីតែភាគតូចបំផុតក៏ដោយ ហើយដែលប្រការនេះពួកគេក៏អាចធ្វើជាអ្នកសម្រុះសម្រួលផងដែរ ។ ដូច្នោះអ្នកសម្រុះសម្រួលក្លាយជាជនរងគ្រោះម្នាក់នៃជម្លោះរបស់ពួកគេ! អ្នកសម្រុះសម្រួល ឬ បុគ្គលទី ៣ ទទួលបាន ៧០% ប៉ុណ្ណោះនៃអ្វីៗក៏ដោយ ដែលកំពុងតែកើតឡើង ។

ជម្លោះភាគច្រើនផងដែរ អាចត្រូវបានដោះស្រាយនៅដំណាក់កាលដំបូង បើសិនអ្នកដឹកនាំមានចិត្តនឹងធ្វើសកម្មភាពលឿនល្មមគ្រប់គ្រាន់នោះ ។ ភាគីទី ៣ ទុកឲ្យការធ្វើអន្តរាគមន៍យូរពេក បន្ទាប់មកពួកគេធ្វើឲ្យរឿងរ៉ាវស្មុគស្មាញ ដោយព្យាយាមនាំភាគីទាំងសងខាងមកជាមួយគ្នាឆាប់ពេក ក្រោយពីដំណាក់កាលរួបរួម ។ ជំហានដ៏ចំបងមួយចំពោះការដោះស្រាយជម្លោះ គឺធ្វើឲ្យមនុស្សយល់ពីភាពខុសគ្នារបស់អ្នកដទៃ ថាជាការខុសគ្នាហើយទាំងសរសើរផង ប៉ុន្តែមិនមែនជាការខុសឆ្គងនោះទេ ។

## ស្ទីលនៃការដោះស្រាយជម្លោះ

| | | |
|---|---|---|
| ☹ | សហការគ្នា | ក្នុងនាមភាគីទន់ខ្សោយ ខ្ញុំនឹងយល់ស្របជាមួយឥឡូវនេះ ។ |
| ☹ | គេចវេះ | ការគេចនិងការបោះពួយទៅមុខ ។ បើសិនខ្ញុំអាចរត់លឿនល្មម នោះខ្ញុំមិនត្រូវគេចាប់បានទេ ។ ខ្ញុំមិនអាចឈ្នះ ដូច្នេះខ្ញុំនឹងដកខ្លួនចេញ ។ |
| ☹ | ការពារ | នៅមិនទាន់បរិយាយពីបំណងប្រាថ្នារបស់ខ្ញុំ ប៉ុន្តែខ្ញុំនឹងធ្វើឲ្យវាលំបាកសំរាប់អ្នកដទៃទៀត ។ |
| 😐 | សម្របសម្រួល | គំនិត និង រឿងរ៉ាវត្រូវបានពិពណ៌នា ប៉ុន្តែមិនបានថ្លែងដោយពិតទេ ។ ទោះជាយ៉ាងណាក៏ដោយខ្ញុំផ្តល់ឲ្យតិចតួច ដើម្បីនឹងបានទទួលតិចមកវិញ ។ |
| 😐 | ចរចារបន្ទន់ឥរិយាបថ | ខ្ញុំមិនប៉ងឲ្យទទួលបានគ្រប់ទាំងអ្វីដែលខ្ញុំចង់បានទេ ។ ដំណើរដែលយើងចាប់ផ្តើមដើរឆ្ពោះទៅរកគ្នា (ហើយវាជាមុខងាររបស់ខ្ញុំដែលត្រូវដើរឲ្យលឿនជាងបន្តិច) ខ្ញុំផ្តល់ឲ្យដើម្បីនឹងចុះសម្រុងគ្នា ។ |

| | | |
|---|---|---|
| 😐 | ប្រឈមមុខ | យើងដាក់គ្រប់ទាំងបញ្ហាបញ្ចូលគ្នា ។ |
| ☹ | ប្រកួតប្រជែង | បង្ខំចង់បានតែអ្វីដែលខ្ញុំចង់បាន ដោយមិនខ្វល់អំពីអ្វីដែលអ្នកចង់បានទេ ។ អ្នកស្លូតត្រង់ទទួលការឈឺចាប់ក្នុងការប្រកួតប្រជែង ។ |
| ☹ | វាយប្រហារយកឈ្នះ | មធ្យោបាយដ៏ល្អបំផុតនៃការការពារកំណាត់លើជំហររបស់ខ្លួន ។ ជាញឹកញាប់វាជាជំហរមួយដែលបានរៀបឡើងដ៏ឈឺចាប់ ហើយអ្នកនឹងរកឃើញថាការទាស់ប្រឆាំងដែលទើបតែត្រៀមរួចជាស្រេច ។ ខ្ញុំនឹងឈ្នះថ្លៃប៉ុន្មានក៏ដោយ ។ |
| ☺ | ផ្សះផ្សា | ការផ្សះផ្សាគឺជាកិច្ចសហការដែលធានាអះអាង ។ ខ្ញុំនឹងនិយាយអ្វីដែលខ្ញុំចង់និយាយ ហើយខ្ញុំនឹងចង់ស្តាប់ ។ ខ្ញុំមិនហួសហេតុលើអ្វីដែលខ្ញុំចង់បាន ប៉ុន្តែសំខាន់លើអ្វីដែលអ្នកចង់បាន ។ ភាគីទាំងពីរជាអ្នកឈ្នះ បើសិនយើងដោះស្រាយនូវភាពខុសគ្នារបស់យើង ។ (ម៉ាថាយ ១៨:១៥) |

ខ្ញុំត្រូវតែទទួលស្គាល់ថា ទាំងខ្ញុំ ហើយនិង អ្នកមានសិទ្ធិ ហើយប្តេជ្ញាធ្វើឲ្យសិទ្ធិរបស់អ្នកទាំងពីរត្រូវបានពួជាប្រាកដ ។

## គោលការណ៍នៃដំណោះស្រាយជម្លោះ

១. ផ្តើមគំនិតដោះស្រាយជម្លោះភ្លាមៗ និង ដោយវិជ្ជមានៈ ទទួលយកគ្រប់ទាំងការមិនយល់ស្របគ្នា ទុកជាឱកាសមួយធ្វើឲ្យកាន់តែជ្រៅនូវទំនាក់ទំនងរបស់អ្នក (អេភេសូ ៤:១៥ "និយាយសេចក្តីពិតក្នុងសេចក្តីស្រឡាញ់" ) ឬ

២. ជ្រើសរើសពេលដ៏សមរម្យបំផុតៈ (សុភាសិត ១៥ៈ២៣ "ពាក្យមួយម៉ាត់ពោលត្រូវនោះល្អណាស់ហ្ន៎" ) ។ កុំនិយាយថា "ពេលក្រោយ" ប៉ុន្តែត្រូវកំណត់ពេលវេលាច្បាស់លាស់ ។ ចូរឲ្យប្រាកដផងដែរថាប្រធានបទត្រូវបានកំណត់ច្បាស់លាស់ ដូច្នេះអ្នកទាំងពីរដឹងពីអ្វីដែលអ្នកត្រូវពិភាក្សា ។

៣. កំណត់អត្ថន័យ ឬ រឿងរ៉ាវជម្លោះដោយច្បាស់លាស់ៈ វាអាចនឹងជួយបើការសរសេរវាចុះ ។ ជម្លោះកាន់តែតូច គឺនឹងត្រូវបានកំណត់អត្ថន័យដោះស្រាយកាន់តែងាយស្រួលជាង ។

៤. រក្សារឿងរ៉ាវនៃការអនុវត្តន៍ដែលមិនមែនជាបញ្ហាផ្ទាល់ខ្លួនៈ រក្សារឿងរ៉ាវឲ្យនៅច្បាស់ និង ជានិច្ចកាលឲ្យនៅចំពោះមុខអ្នក ។ បើសិនជឿងឆ្ងល់ចំពោះការវាយប្រហារផ្ទាល់ខ្លួន នោះត្រូវយកចិត្តទុកដាក់ឲ្យរហ័ស និង ដោយស្រទន់ទៅចំពោះអ្វីដែលកំពុងកើតឡើង ។

៥. ស្តាប់ដោយយកចិត្តទុកដាក់ចំពោះបុគ្គលផ្សេងទៀតៈ (សុភាសិត ១៨ៈ១៣ "កុំឲ្យឆ្លើយមុនដែលអ្នកបានស្តាប់រឿង" យ៉ាកុប ១ៈ១៩ "ឆាប់នឹងស្តាប់ក្រនឹងនិយាយ") ។

៦. ទទួលយកការទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនៈ ការទម្លាក់កំហុសលើអ្នកដទៃធ្វើឲ្យខូចដល់ទំនាក់ទំនង ហើយគ្មានប្រសិទ្ធិភាពលើការផ្លាស់ប្តូរវិជ្ជមានទេ (រ៉ូម ១៤ៈ១៣) ។

៧. រកឃើញដំណោះស្រាយឆ្លាស់គ្នាៈ កាលណាមនុស្សម្នាក់ៗបានលើកបញ្ហាឡើងនោះ សេចក្តីត្រូវការសំរាប់ការផ្លាស់ប្តូរនៃឥរិយាបថប្រែជាច្បាស់លាស់ ។ ជំហានបន្ទាប់គឺជាដំណោះស្រាយនៃបញ្ហា ដែលវាមិនជាការងាយស្រួលខានមិនបាន ។ វាតម្រូវឲ្យមានការជញ្ជឹងគិត និង ការបញ្ចេញគំនិតឡើង ។ គប្បីគិតដូចជាមានដំណោះស្រាយយ៉ាងច្រើនដែលអាចធ្វើបាន ។ មើលគ្រប់ជ្រុងគ្រប់ផ្នែក ។

៨. សម្រេចចិត្តលើដំណោះស្រាយ ដែលអាចទទួលយកទាំងសងខាងៈ បន្ទាប់ពីការរកឃើញយ៉ាងយកចិត្តទុកដាក់គ្រប់ទាំងផ្លូវផ្សេងទៀត និង ប៉ាន់តម្លៃពួកវា ហើយចូរធ្វើការសំរេចចិត្ត ។ បើសិនម្នាក់ក្នុងចំណោមពួកអ្នកគេចូលចិត្តផ្លូវផ្សេងទៀត ប៉ុន្តែអ្នកដទៃរកឃើញថាវាមិនអាចទទួល បាន ចូរពិភាក្សាពីហេតុផល ។

៩. ចាប់ផ្តើមធ្វើការភ្លាមលើដំណោះស្រាយ ដែលឯកភាព: ជញ្ជឹងគិតលើរឿងរ៉ាវចំណែករបស់អ្នកផ្ទាល់ ទុកឲ្យបុគ្គលដទៃមានសេរីភាពលើកិច្ចការទទួលខុសត្រូវរបស់គាត់ ។

១០. រក្សាក្នុងគំនិតនូវភាពទទូច លើគោលការណ៍នៃការអត់ទោស របស់ព្រះគម្ពីរ: ខ្វះភាពស្ម័គ្រចិត្តក្នុងការអត់ទោសគឺ ជាញឹកញាប់ជាឧបស័គ្គដ៏ធ្ងន់ធ្ងរចំពោះការដោះស្រាយជម្លោះ ជាងការធ្វើឲ្យបុគ្គលនោះអាក់អន់ចិត្ត តើបទគម្ពីរនិយាយដូចម្តេចអំពីការអត់ទោស? ចូរធ្វើជាគំរូជាជាងធ្វើជាចៅក្រម នោះមានប្រយោជន៍យ៉ាងខ្លាំងបំផុតក្នុងការដោះស្រាយជម្លោះ ។

## ការសន្និដ្ឋានជាមូលដ្ឋានខ្លះអំពីជម្លោះ

១. *ជម្លោះគឺភាគច្រើនមិនអាចចៀសផុត* ។ ជម្លោះកើតឡើងតាមចំណែករៀងខ្លួនពីព្រោះគ្រប់គ្នាដឹងពីមនុស្ស និង ស្ថានភាពខុសៗគ្នា ។ ការដឹងខុសៗគ្នាយ៉ាងនេះអនុញ្ញាតឲ្យមានចំណង់ និង ការសំរេចផ្សេងគ្នា ដែលផ្ទុយមកវិញបណ្តាលឲ្យមានជម្លោះ ។

២. *ជម្លោះរួមចំណែកទាំងតម្លៃផ្ទាល់ខ្លួន និង មូលដ្ឋាននៃសេចក្តីត្រូវការ* ។ គ្រប់មនុស្សទាំងអស់គឺមានមូលដ្ឋានតម្លៃ និង សេចក្តីត្រូវការផ្សេងៗ ។ ទាំងនេះត្រូវបានកំណត់អត្ថន័យដូចជាត្រូវការឲ្យស្រឡាញ់ និង ត្រូវការឲ្យមានអារម្មណ៍ថាមានតម្លៃ ។ បើសិនជាសេចក្តីត្រូវការទាំងនេះមិនត្រូវបានបំពេញទេនោះ ចំនួនពិតប្រាកដនៃភាពខ្វះខាតគឺត្រូវមានអារម្មណ៍នៅក្នុងបុគ្គលិកលក្ខណៈ ។

៣. *ជម្លោះតាមធម្មតាផុសចេញឡើងដូចជាអាការរោគ* ។ យើងគប្បីត្រូវដឹងពីការពិត ដែលព្យាយាម ដោះស្រាយតែអាការរោគពីខាងក្រៅនៃជម្លោះនោះនឹងមិនធ្វើឲ្យបាត់បុសបញ្ហាទេ ។ ការព្យាយាមមួយគប្បីធ្វើឡើងដើម្បីមើលពីក្រោមផ្ទៃរឿង និង រកឃើញអ្វី ដែលជាមូលដ្ឋានបណ្តាលឲ្យកើតមានបញ្ហា ។

៤. *ជម្លោះ ត្រូវតែដោះស្រាយដោយឲ្យបានឆាប់រហ័ស តាមដែលអាចធ្វើទៅបាន* ។ មនុស្សខ្លះចូលចិត្តមិនអើពើជម្លោះតូចតាច ដោយមិនចង់ធ្វើឲ្យ "ទូកឃ្លីងឃ្លោង" ដូច្នេះពេលជម្លោះធំដុំកើតឡើង នោះពួកគេមិនអាច

និងដោះស្រាយវាបាន ពីព្រោះពួកគេមិនបានរៀនពីរបៀបដោះស្រាយរឿងតូចតាច ។

៥. *ជម្លោះផ្តល់ឱកាសសំរាប់ការលូតលាស់* ។ លោក ហ.ណ. រ៉ៃ (H.N. Right) និយាយថា "ជម្លោះ" គឺដូចជាដាក់រំសេវឲ្យផ្ទុះ ។ ប្រសិនបើបានប្រើប្រាស់វានៅក្នុងមធ្យោបាយត្រឹមត្រូវ វាអាចជាប្រយោជន៍យ៉ាងខ្លាំងបំផុត ។ តែបើប្រើវាក្នុងមធ្យោបាយខុស វាអាចបក់ផាត់ការសាកល្បង កម្លាំង និងធនធានរបស់មនុស្សម្នាក់ ។

### មធ្យោបាយ ៥ យ៉ាងដែលយើងប្រើសំរាប់ប្រាស្រ័យទាក់ទង

| | | |
|---|---|---|
| ១ | ការសន្ទនា | ការប្រាស្រ័យទាក់ទងពីរផ្លូវ |
| ២ | ការពិភាក្សា | ចែកចាយកត្តាមតិ និង តម្លៃផ្សេងជាមួយគ្នា |
| ៣ | ការជជែកវែកញែក | គោលបំណងដើម្បីឈ្នះ និងជំណឿមចាប់យក |
| ៤ | ការកោកកាក | គោលបំណងដើម្បីឈ្នះ និងទម្លាក់ចុះ |
| ៥ | ការនិយាយ | ស្តាប់ អធិស្ឋាន និងដោះស្រាយរឿងរ៉ាវ |

### ប្រភពឯកសារស្រាវជ្រាវ


លោក Cormack និង David ស្តីពីការមានសន្តិភាពជាមួយគ្នា: ពីជម្លោះទៅការផ្សះផ្សា (MARC Monarch Publication, 1989)

លោក Huggett និង Joyce ស្តីពីជម្លោះ: ការយល់ ការគ្រប់គ្រង និងការលូតលាស់តាមរយៈជម្លោះ (N. P.: Eagle, 1998)

លោក Lingerfelter, Sherwood G និង Marvin K. Mayers ការបំរើឆ្លងកាត់វប្បធម៌ផ្សេង: គំរូតំណាងមួយសំរាប់ទំនាក់ទំនងផ្ទាល់ខ្លួន ។ (N. P., 1986)

សំណុំធីកឃ្មុំ ១/២ (តុលា ២០០០): ៣៣-៤០

# ពន្លឺសន្ធោសន្ធៅចេញពីអាំស្ទែរដាំ ឆ្នាំ ២០០០

ដោយលោក ឃីន សិលា

នៅឆ្នាំ ១៩៨៣ គេបានធ្វើសន្និសីទសំរាប់អ្នកផ្សាយដំណឹងល្អ នៅក្រុងអាំស្ទែរដាំ លើកទី ១ ហើយ នៅលើកទី ២ គេធ្វើនៅឆ្នាំ ១៩៨៦ ។ ប៉ុន្តែទាំងពីរលើកនោះ គ្មានគ្រីស្ទបរិស័ទខ្មែរណាម្នាក់ បានចូលរួមឡើយ ។

អាំស្ទែរដាំ ឆ្នាំ ២០០០ ដែលគេបានធ្វើឡើង នៅថ្ងៃទី ២៩ កក្កដារហូតដល់ថ្ងៃទី ០៦ សីហា គឺជាសន្និសីទលើកទី ៣ ។ លើកនេះ មានចំនួនមនុស្សចូលរួម មួយម៉ឺនពីរឃម្ភៃប្រាំនាក់ មកពីប្រទេសផ្សេងៗចំនួន ២០៩ ប្រទេស នៅលើសកលលោក នោះហើយនិង មានអ្នកស្ម័គ្រចិត្តបំរើក្នុងសន្និសីទនោះ មកពីប្រទេសមួយចំនួនធំនៅជុំវិញពិភពលោក ចំនួន ៧៥០ នាក់ថែមទៀតផង ។ នៅលើកនេះ គ្រីស្ទបរិស័ទខ្មែរបានទៅចូលរួមក្នុងសន្និសីទនេះ ចំនួន ២០ នាក់ និង អ្នកបកប្រែ ៤ នាក់ ។ ហេតុដូច្នេះហើយ ព្រឹត្តិការណ៍នេះ គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយ ដែលយើងជាខ្មែរបានចូលរួម ក្នុងការប្រមូលផ្តុំនៃអ្នកដឹកនាំក្រុមជំនុំ និង អ្នកផ្សាយដំណឹងល្អ យ៉ាងច្រើនកុះករបែបនេះ ។

តើអ្វីទៅជាការចាប់អារម្មណ៍របស់យើង ក្នុងព្រឹត្តិការណ៍នេះ? តើយើងទទួលបានបទពិសោធន៍បែបណា រៀនបានអ្វីខ្លះ ហើយនិង តើយើងបានដឹងថាព្រះមានបន្ទូលមកកាន់យើងយ៉ាងណាខ្លះ? ក្នុងចំណោមប្រតិភូទាំង ២៤នាក់ ពីប្រទេសកម្ពុជាដែលបានចូលរួមព្រឹត្តិការណ៍នោះ មាន ១៤នាក់ បានបញ្ចេញមតិដូចខាងក្រោមនេះ ។



លោក ខួន សំ

សន្និសីទអាំស្ទែរដាំឆ្នាំ២០០០ ផ្ដល់ឱកាសដ៏ប្រពៃ សំរាប់គ្រប់ក្រុមទាំងអស់ ដោយមិនប្រកាន់ថាគណៈនិកាយអ្វីឡើយ មិនថាជាកាតូលិក ឬ ក៏ប្រូតេស្តង់។ ខ្ញុំបានទទួលអារម្មណ៍ពីព្រះវិញ្ញាណ ដែលនាំឲ្យយើងមានការរួបរួម និង ព្រះជាម្ចាស់បានសំអិតសំអាងជីវិតអ្នកផ្សាយដំណឹងល្អរបស់ព្រះអង្គឲ្យបានបរិសុទ្ធ ដោយសារតែអាំស្ទែរដាំ ។ យើងត្រូវតែធ្វើការអ្វីមួយដើម្បីផ្សាយដំណឹងល្អដល់ប្រជាជាតិរបស់យើង ដោយផ្អែកលើអ្វី ដែលយើងបានរៀនពីអាំស្ទែរដាំនោះ ។



លោក នួន គាព

អាំស្ទែរដាំ ឆ្នាំ ២០០០ ជំរុញឲ្យវិញ្ញាណរបស់ខ្ញុំផ្ដោតយ៉ាងខ្លាំងលើការអធិស្ឋាន ។ ការអធិស្ឋានជាកត្តាដំបូងបំផុត ក្នុងដំណើរការទាំងស្រុងរបស់ការផ្សាយដំណឹងល្អ ។ នេះជាមេរៀនមួយដែលខ្ញុំចាប់អារម្មណ៍ជាងគេបំផុត ។ តាមរយៈការអធិស្ឋានអ្វី ដែលយើងគិតថាមិនអាចធ្វើបាន បែរទៅជាអាចធ្វើបាន ។ ព្រះជាម្ចាស់ធ្វើការតាមរយៈសេចក្ដីអធិស្ឋានរបស់យើង ។



លោក អៀង ស៊ុនឃេង

ការផ្សាយដំណឹងល្អ មិនមែនគ្រាន់តែជាកិច្ចការរបស់គ្រូគង្វាលតែម្នាក់ប៉ុណ្ណោះទេ ។ អ្នកជឿគ្រប់រូបត្រូវតែផ្សាយដំណឹងល្អ ។ អាំស្ទែរដាំ ធ្វើឲ្យខ្ញុំចាប់អារម្មណ៍យ៉ាងខ្លាំងលើការផ្សាយដំណឹងល្អ ។ អាំស្ទែរដាំ ធ្វើឲ្យខ្ញុំចាប់អារម្មណ៍យ៉ាងខ្លាំង លើការផ្សាយដំណឹងល្អ គឺជាការងាររបស់មនុស្សគ្រប់រូប ។ ខ្ញុំនឹងបង្រៀនពួកជំនុំ

របស់ខ្ញុំ និងលើកទឹកចិត្តឲ្យគេយល់ច្បាស់ពីការផ្សាយដំណឹងល្អ ដែលខ្ញុំបានរៀន ពីអាំស្វែរដាំឆ្នាំ ២០០០។



លោក សាយ សេដ្ឋា

ការអធិស្ឋានជាមេរៀនមួយ ដែលប៉ះពាល់ចិត្តរបស់ខ្ញុំយ៉ាងខ្លាំងនៅកំឡុងពេល ដែលខ្ញុំបានចូលរួមសន្និសីទអាំស្វែរដាំឆ្នាំ ២០០០ ។ ខ្ញុំចាប់អារម្មណ៍យ៉ាងខ្លាំង នៅពេលដែលគ្រូអធិប្បាយម្នាក់ដាក់ដៃលើផែនទីពិភពលោក រួចគាត់អធិស្ឋាន ។ តាមរយៈការអធិស្ឋានរបស់យើង ព្រះជាម្ចាស់តែងតែធ្វើការបំផ្លាស់បំប្រែ និងធ្វើឲ្យដួងចិត្តរបស់មនុស្ស ដែលរឹងរូសប្រែទៅជាទន់បាន ។



លោក ឡាច ហឿន

អាំស្វែរដាំឆ្នាំ ២០០០ បាននាំឲ្យយើងមានភាពជិតស្និតគ្នា ។ គឺបានធ្វើឲ្យយើងមានចិត្តក្តួលអាណិត និងស្រឡាញ់ដល់មនុស្សនៅក្នុងសង្គមរបស់យើង ហើយនិង ធ្វើឲ្យយើងមានចិត្តឆេះឆួលចង់នាំឲ្យគេជឿដល់ព្រះគ្រីស្ទ ! អ្វីដែលខ្ញុំចាប់អារម្មណ៍បំផុតនោះ គឺការទៀងទាត់ពេលវេលា ។ គ្រប់ទាំងកម្មវិធីទាំងអស់ គឺចាប់ផ្តើមទៀងពេល ហើយនិង ចប់ទៅវិញទៀងពេលទៀត ។ នេះជាមេរៀនសំខាន់សំរាប់យើងជាអ្នកដឹកនាំគឺថា៖ បើយើងចង់ឲ្យសហការីរបស់យើងទៀងពេល យើងត្រូវតែទៀងពេលដែរ! ខ្ញុំស្ញើចអស្ចារ្យ ហេតុអ្វីក៏ព្រឹត្តិការណ៍ដ៏ធំយ៉ាងនេះ ម៉េចក៏រៀបចំបានល្អ ស៊ីចង្វាក់គ្នា និងទៀងទាត់ពេលល្អម្លេះ !



លោក តាំង ទើកឃួន

អាំស្បែរដាំឆ្នាំ២០០០ បានផ្តល់ឲ្យខ្ញុំនូវបន្ទុកមួយ នៅក្នុងចិត្តរបស់ខ្ញុំ គឺឲ្យខ្ញុំស្រឡាញ់ដល់ប្រជាជាតិរបស់ខ្ញុំកាន់តែខ្លាំងឡើង និងផ្តល់ឲ្យខ្ញុំមាននិមិត្តថ្មីសំរាប់ប្រជាជាតិយើងថ្វាយព្រះគ្រីស្ទ ! យើងត្រូវអនុវត្តនូវអ្វីដែលយើងបានរៀនពីអាំស្បែរដាំមក ។



លោក អ៊ុក ប៊ុនធឿន

គ្រប់ទាំងមេរៀន ដែលខ្ញុំបាននោះ គឺផ្តោតទៅលើការផ្សាយដំណឹងល្អ សំរាប់ប្រជាជាតិយើង ។ ការផ្សាយដំណឹងល្អដល់ប្រជាជាតិជាតួនាទី របស់យើង និងជាចំណែកមួយដ៏សំខាន់ នៃជីវិតរបស់យើង ជាអ្នកជឿនៅជំនាន់ដំបូងគេ ។ អាំស្បែរដាំឆ្នាំ ២០០០ ធ្វើយើងនឹកឃើញពីទឹកចិត្តឆេះឆួលក្នុងការផ្សាយដំណឹងល្អរបស់សាវ័ក នៅក្នុងគម្ពីរកិច្ចការ ។



លោកស្រី ស៊ិន ម៉ាណែត

មុនពេលទៅអាំស្បែរដាំ ខ្ញុំគ្រាន់តែដឹងថាការផ្សាយដំណឹងល្អ គឺសំរាប់តែមនុស្សប្រុសប៉ុណ្ណោះទេ តែបន្ទាប់ពីបានរៀននៅឯអាំស្បែរដាំ ទើបខ្ញុំបានដឹងថាសូម្បីតែស្ត្រីក៏ត្រូវតែមានតួនាទីសំខាន់ ក្នុងការផ្សាយដំណឹងល្អ និង នាំព្រលឹងមនុស្សថ្វាយព្រះយេស៊ូដែរ ។ ខ្ញុំប្តេជ្ញាក្នុងចិត្តថា និង ខំផ្សាយដំណឹងល្អនៅក្នុងព័ន្ធកិច្ចស្ត្រីផងដែរ ។



លោកស្រី ម៉ែន វ៉ាន់នី

ខ្ញុំបានទទួលការប៉ះពាល់ចិត្ត យ៉ាងខ្លាំងក្នុងការផ្សាយដំណឹងល្អសំរាប់ប្រជាជាតិខ្ញុំ ដោយមេរៀនទាំងឡាយនៅអាំស្ទែរដាំ ឆ្នាំ ២០០០ ។ ដួងចិត្តរបស់ខ្ញុំ មានអំណរយ៉ាងខ្លាំង ដោយបានឃើញហ្វូងមនុស្សយ៉ាងច្រើន មកពីប្រជាជាតិនានា នៅជុំវិញសកលលោក និងបានស្តាប់ព្រះរាជសាររបស់ព្រះ តាមរយៈគ្រូអធិប្បាយមកពីប្រទេសជាតិផ្សេងៗ ព្រមទាំងបានស្តាប់ទីបន្ទាល់ដែលប៉ះពាល់ដួងចិត្តជាច្រើន ពីពួកកុលសម្ព័ន្ធនៅទ្វីបអាមេរិក និងទ្វីបអាហ្វ្រិក ។



លោក ខ៊ែត សារ៉ាន់

អាំស្ទែរដាំឆ្នាំ ២០០០ មិនគ្រាន់តែធ្វើឲ្យខ្ញុំចាប់អារម្មណ៍ចំពោះការចាំបាច់ នៃផ្សាយដំណឹងល្អដល់ប្រជាជាតិយើងប៉ុណ្ណោះទេ ប៉ុន្តែបានបង្ហាញឲ្យខ្ញុំឃើញយ៉ាងធំទូលាយដល់សេចក្តីត្រូវការ របស់ពិភពលោកទាំងមូល ដែលយើងត្រូវឈោងចាប់ថ្វាយព្រះជាម្ចាស់។



លោក ឌួន កក្កដា

អាំស្ទែរដាំ ឆ្នាំ ២០០០ មិនគ្រាន់តែជំរុញឲ្យយើងផ្សាយដំណឹងល្អ ដល់ប្រជាជាតិយើងប៉ុណ្ណោះទេ តែត្រូវផ្សាយដំណឹងល្អ ដល់លោកិយទាំងមូលផងដែរ។ អាំស្ទែរដាំឆ្នាំ ២០០០ ក៏ជំរុញឲ្យយើងក្លាយទៅជាកងទ័ពដ៏ជាញជ័យ ផ្នែកការអធិស្ឋានថែមទៀត ។ ដើម្បីធ្វើការងារដ៏ធំបែបនោះ ឲ្យបានសម្រេច យើងត្រូវការគ្នាទៅវិញទៅមក ។ ខ្ញុំធ្លាប់អស់ទឹកចិត្ត បាក់កម្លាំង ចង់លះ

បង់ចោលការងារមុន ពេលទៅអាំស្ទែរដាំ ប៉ុន្តែឥឡូវនេះ ខ្ញុំមានសេចក្តីសង្ឃឹមថ្មី និង កម្លាំងថ្មី សំរាប់ការងារ ផ្សាយដំណឹងល្អដល់ប្រជាជាតិខ្ញុំ ។



លោក ឃេង ចេង

អាំស្ទែរដាំ ឆ្នាំ ២០០០ សង្កត់ធ្ងន់លើសេចក្តីពិតនៃព្រះរាជសារ ដែលយើងជាអ្នកផ្សាយដំណឹងល្អ ផ្សាយប្រាប់ដល់ហ្វូងមនុស្ស ។ យើងត្រូវនិយាយតែសេចក្តីពិត ។ ដំណឹងល្អទាំង៤ ដែលយើងផ្សាយទៅនោះ ជាទូទៅមិនគ្រប់គ្រាន់ទេ ហើយគេក៏មិនបានឃើញព្រះយេស៊ូ ឬ ជឿព្រះអង្គដែរ តែដំណឹងល្អទី ៥ ដែលជាជីវិតរស់នៅរបស់យើងផ្ទាល់ និង ការប្រព្រឹត្តិរបស់យើងផ្ទាល់នោះទេវិញទេ ដែលអាចធ្វើឲ្យគេ ឃើញព្រះយេស៊ូនៅក្នុងជីវិតរបស់យើង ។



លោក ម៉ម ឬណាឬស

ខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីជីវិត បរិសុទ្ធរបស់អ្នកផ្សាយដំណឹងល្អដូចជាលោក ប៊ៀល្លី ក្រាហាំ ។ គឺមាន ប៊ៀល្លីក្រាហាំ តែមួយដូចគ្នា នៅទី សាធារណៈ ទោះនៅទីកន្លែងគ្មានគេឃើញ ។ ក្នុងនាមជាអ្នកផ្សាយដំណឹងល្អ យើងត្រូវតែមានចរិយាសម្បត្តិបរិសុទ្ធមិនថានៅទីណាក៏ដោយ ។ អាំស្ទែរដាំផ្តល់ឲ្យខ្ញុំមានឱកាសស្គាល់ មិត្តភក្តិថ្មីៗ និង ជួបមុខមនុស្សប្លែកៗជាច្រើន ។ អាំស្ទែរដាំ ជាព្រឹត្តិការណ៍ដ៏ធំសម្បើមអស្ចារ្យណាស់!



លោក អ៊ុន សិលា

អាំស្ទែរដាំ ឆ្នាំ ២០០០ មានតួនាទីយ៉ាងសំខាន់បំផុតក្នុងការផ្ដល់ឲ្យមានចំហេះ ដល់ប្រឆេះទៀនរបស់អ្នកផ្សាយដំណឹងល្អ ហើយនិងនាំមកនូវការរួបរួមគ្នា ដែលបានផ្ដល់ភាពជិតស្និតក្នុងចំណោមគណៈនិកាយជាច្រើន ។ ខ្ញុំសូមសម្ដែងនូវការអរគុណយ៉ាងជ្រាលជ្រៅដល់បណ្ឌិត ប៉េល្លីក្រាហាំ ដែលបានផ្ដល់ឲ្យយើងនូវមត៌កដ៏ប្រពៃនេះ ។ ព្រឹត្តិការណ៍នេះជាព្រឹត្តិការណ៍ដ៏គួរឲ្យស្ញើមអស្ចារ្យ និង ធ្វើឲ្យមានការប៉ះពាល់ចិត្តមែនទែន!

អាំស្ទែរដាំ ឆ្នាំ ២០០០ បានផ្ដល់ឲ្យយើងនូវកិច្ចការសំខាន់ពីរយ៉ាង ។ ទី ១ គឺជំរុញលើកទឹកចិត្តដល់អ្នកដែលល្ហើយខ្សោះនឹងការងារឲ្យបន្តខំធ្វើការទៅមុខទៀត ។ គ្រូគង្វាល និង អ្នកផ្សាយដំណឹងល្អ ដែលទន់លោង យោងខ្លួនទាំងត្រដរ ភាគច្រើនចាប់ផ្ដើមមានកម្លាំងឆេះសន្ធោសន្ធៅឡើងវិញ ។ ទី ២ អាំស្ទែរដាំ ផ្ដល់ឲ្យយើងមានកម្លាំងសំរាប់បំណងរបស់យើងដែលចង់រួបរួមគ្នានោះបានកាន់តែខ្លាំងឡើង ។ រយៈពេលយ៉ាងយូរមកហើយ ដែលយើងខំប្រឹងយ៉ាងត្រដាបត្រដួស ព្រោះចង់បានការរួបរួមក្នុងចំណោមគ្រីស្ទបរិស័ទខ្មែរ ដែលរហូតមកដល់ពេលនេះទៅហើយហាក់ដូចជាគ្មានលេចជាដុំកំភួនអ្វីសោះ ។ តែអាំស្ទែរដាំឆ្នាំ២០០០បានបង្ហាញឲ្យយើងឃើញថា យើងឥឡូវព្រមធ្វើការជាមួយគ្នា ដែលយើងមិនធ្លាប់ដែលបានធ្វើការរួបរួមច្រើនប៉ុន្មានទេពីមុនមក ។ បើគ្រីស្ទបរិស័ទទាំងអស់នេះ ដែលគេមកពីប្រទេសជាច្រើនទូទាំងពិភពលោកនិយាយភាសាផ្សេងគ្នា និងមានទំនៀមទម្លាប់ផ្សេងគ្នា គេអាចរួបរួមគ្នាធ្វើការជាមួយគ្នាបាន ចុះយើងជាខ្មែរនៅក្នុងប្រទេសខ្មែរនិយាយភាសាខ្មែរដូចគ្នា និង មានទំនៀមទម្លាប់ដូចគ្នា តើយើងពិតជាអាចថ្វាយបង្គំព្រះជាមួយគ្នា និង ធ្វើការបំរើព្រះជាមួយគ្នាបានទេឬអ្វី? ដួងចិត្តរបស់យើងបានរួបរួមគ្នាយ៉ាងពិតប្រាកដដោយ

មិនប្រកាន់ថានិកាយគេនិកាយយើង ក្រុមប្រឹក្សាគេក្រុមប្រឹក្សាយើង ឬ ក្រុមជំនុំគេក្រុមជំនុំយើងទៀតឡើយ ដោយសារតែអាំស្វែរដាំ ឆ្នាំ ២០០០ ។

ប្រទេសកម្ពុជាមាន ៥ ក្រុមប្រឹក្សារបស់គ្រីស្ទបរិស័ទដែលឥឡូវនេះព្រមអង្គុយជាមួយគ្នារៀបចំផែនការ និងធ្វើការជាមួយគ្នាដើម្បីរៀបចំព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រមួយដែលហ្វឹកហ្វឺនអ្នកដឹកនាំដែលគ្រោងធ្វើនៅខែវិច្ឆិកាឆ្នាំ២០០០ ខាងមុខនេះស្ថិតនៅក្រោមខ្លឹមសារ "យើងរួបរួមគ្នា ដើម្បីពង្រីកអាណាចក្រព្រះ" ក្រុមការងារឬគណៈកម្មាធិការយន្តការដែលមានឈ្មោះថា "និមិត្តសំរាប់កម្ពុជា" ក្រុមនេះមានអ្នកដឹកនាំមកពី **KFC, CCC, EFC, CBC** និង **Methodist Council** រួមជាមួយបេក្ខភាពជាឯកត្តបុគ្គលមួយចំនួនធំទៀត ។ ក្រុមនេះនឹងគ្រោងធ្វើឲ្យមានព្រឹត្តិការណ៍ជាលំដាប់លំដោយមួយដែលមានគ្រូគង្វាល និងអ្នកផ្សាយដំណឹងល្អចំនួន៥០០ នាក់ចូលរួម ។

ព្រឹត្តិការណ៍នេះអស្ចារ្យណាស់មែនទេ?សូមជួយអធិស្ឋានសំរាប់ព្រឹត្តិការណ៍ និង គម្រោងផែនការនេះផង !

HONEYCOMB 1/2 (October 2000): 41–46

# The Glow from Amsterdam 2000

UON Seila

The first Amsterdam conference for itinerant evangelists convened in 1983; the second in 1986. But no Cambodian Christian attended either.

Amsterdam 2000, held 29 July to 6 August, was the third in this series. Ten thousand two hundred twenty-five participants from two hundred nine countries around the world were there, as well as seven hundred fifty volunteer stewards from around the globe. This time there were twenty participants and four translators from Cambodia. Thus this was an historical event that we Cambodians experienced by participating in such a big gathering of church leaders and evangelists.

What were our impressions of this event? What did we experience, learn, and sense that God was saying to us? The following comments were made by thirteen of the twenty-four Cambodian delegates.



*Ngoun Sam*

The Amsterdam 2000 conference provided an excellent opportunity for all groups regardless denomination—Catholic or Protestant. I sense a spirit of unity and of God's working to mold holy lives in his evangelists as a result of the Amsterdam

gathering. We must do something to evangelize our nation based on what we learned there.



*Noun Pheap*

Amsterdam 2000 provoked my innermost being to concentrate on prayers. Prayer is a first element for the whole process of evangelization. This was the subject which interested me most. With prayer, the impossible can be possible. God is at work through our prayers.



*Eang Sun Heng*

Evangelization is not only for a pastor. Every believer must evangelize. Amsterdam gave me the strong impression that evangelization is everyone's task. I will teach and encourage my church to understand the whole concept of evangelism which I learned in Amsterdam 2000.



*Say Setha*

Prayer was the subject which most touched my heart during the Amsterdam conference. It was impressed on me while one of the speakers laid his hand on the globe map and prayed. Through our prayer God will often change things and soften people's hearts.



*Lao Hoeun*

Amsterdam 2000 brought us closer to one another. It stirred up love and compassion for the people in our society, and gave us the desire to win them for Christ! What impressed me most was its punctuality. Every program started and ended on time. This is an important lesson for us as leaders: if we want our colleagues to be punctual, we must be punctual as well! It amazed me how such a big event was so well organized, harmonious, and on time!



*Taing Vek Houng*

Amsterdam 2000 gave me the burden of loving my nation, and gave me a vision for the nation. We must do something to reach our nation for Christ! We have to put into practice what we learned from Amsterdam.



*Ouk Bun Thoeun*

Every subject that I learned focused on the evangelism of our nation. Evangelizing the nation is our responsibility, and an essential part of our lives as first-generation believers.



*Sin Maneth*

Before Amsterdam I thought that evangelism was only for men. After Amsterdam I learned that every individual has a very important role in evangelizing and winning souls for Jesus. I committed myself to evangelizing women and teaching them to evangelize also.



*Mem Vanny*

I was inspired by Amsterdam 2000 to evangelize my nation. My heart felt joy to see a multitude from many nations around the world, and to hear the messages from different nations and the touching testimonies from hill tribes and Africa.



*Nget Sarann*

Amsterdam 2000 not only impressed on me the need to evangelize our nation, but broadened my mind to see that the whole world needs to be reached for God.



*Toun Kakda*

Amsterdam 2000 encouraged us to evangelize not only our nation, but the whole world as well. We were also challenged to become prayer warriors who go forth to attack

the enemy so that he will not confuse us into fighting among ourselves. In order to accomplish a task as big as world evangelism we need one another. I was burned out and I wanted to quit and give up before Amsterdam, but now I have new hope and strength for my nation.



*Heng Cheng*

Amsterdam 2000 emphasized the truth of the message we evangelists share with the multitudes. We have to speak the truth. The four Gospels which we share with the people are often not enough. They don't yet see Jesus or believe in Him. But the fifth Gospel—which is our own lives and our behavior—can make them see Jesus in us!



*Mam Barnabas*

I am so impressed by the holy life of the evangelist Billy Graham. There is only one Billy Graham: he is the same man in public and in private. As evangelists we must embody only one character—that of holiness—and not have a double standard. Amsterdam provided me a chance to make new friends and meet new faces. It was a great and wonderful event!



*Uon Seila*

Amsterdam 2000 played a crucial role in providing a big spark to ignite the evangelists' candlewicks, and in bringing about unity and closeness among denominations. Thank you very much, Billy Graham, for such a good legacy you passed on to us. It was an amazing and touching event!

Amsterdam 2000 did two important things for us. First, it encouraged those who had grown weary with the work to continue on. Many burned-out pastors and evangelists began to glow brightly again. Second, it strengthened our desire for unity. For a long time we have yearned and struggled for unity among Christians in Cambodia, but until now have enjoyed too little of it. But Amsterdam 2000 has convinced us to work together like never before. If all these Christians from all over the world, speaking many languages and from many different cultures, can get along, then surely we in Cambodia, from one nation, one language, and one culture, should be able to worship and work together! Our hearts are now truly united—regardless of denomination, council, or church—because of Amsterdam 2000.

Cambodia is home to five Christian councils which are now willing to sit down, plan, and work together to launch an historical event of leadership training in November 2000 under the theme of "Advancing the Kingdom through Unity." The task group or mechanism committee, known as "Vision for Cambodia," consists of KFC, CCC, CFC, CBC, and the Methodist church. Together with a score of individuals, this task group will plan to hold a series of events in a gathering of five hundred pastors and evangelists.

What a wonderful event! Please remember this event and the plans we are laying in your prayer!

HONEYCOMB 1/2 (October 2000): 47–55

# God and Money

*Robert CHOY*

What are your first thoughts when you read this topic? Many people never consider that the subject of God *and* money go together, at least not in the way that God *and* love or God *and* faith do. For others, the well-known Bible phrase "the love of money is the root of all evil" comes to mind, and they somehow feel that even thinking about "money" in the context of their Christian faith is wrong.

In considering this subject, we need to start by being honest with ourselves. For most of us this means acknowledging that deep down in our hearts we find security in what money can buy and do for us. We recognize we have a practical need for it in our daily lives—for food, housing, transport, our family, and other legitimate needs. Then there are the things that we see others have, and that we want in our own lives—better clothes, a new bike or car, etc.

Many reading this article know what it is to have little or no money. As a developing country, Cambodia has serious problems with money corruption at all levels of society.

We have a choice. We can let the world around us influence our attitudes and practices, or we can find what God's word says about money and seek to apply His wisdom in our lives. This article aims to do the latter, so that we may "live a life worthy of the Lord and may please Him in every way" (Col 1:10). Since God is primarily interested in our motives and where our "heart" truly is, we will examine the "attitudes" people commonly have towards money—greed, contentment, and giving. A follow-up

article in the next edition of *Honeycomb* will then look at what God's word says about the "practical" aspects of handling money—earning, spending, saving, and debt.

### Why Should We Study about "God and Money"?

Here are six reasons:

- because the Bible **TEACHES** about it. There are over 700 direct references to money or wealth in the Bible. Jesus' parables and teachings often used money as a way of understanding truth about God and His kingdom—the rich young ruler, the parable of the talents, the poor widow who gave everything she had, the rich man who built up barns, etc. God's word is *not* silent on the subject of money, so it must be important!
- because money can **TRAP** and deceive us. We need to be warned of the deception and danger of loving money. When we want to become rich we can fall into temptation and into many foolish and harmful desires that can bring ruin and destruction (1 Tim 6:9).
- because money **TESTS** whether our heart is truly devoted to God or not. Our deceitful human heart fools us into thinking that somehow loving money while we are serving God is possible. However, while we can deceive ourselves, we can't fool God. Matthew 6 says that if our treasure is money, our heart will also be devoted to it. It is clear that "you cannot serve both God and money."
- so that we might **TRUST** in God and not forget Him when we have money and wealth. It is easy to become proud and forget God when we prosper. We need to remember that it is God who gives us the ability to earn the money we have (Deut 8:13–14, 17–18).
- so that one day God can entrust us to look after "**TRUE**" riches of eternal value. If we are faithful in wisely handling money or "worldly riches," God can then entrust us to look after His true riches of far greater eternal value (Luke 16:11).

- so that God can **TRANSFORM** our understanding of money, rather than us conforming to the world's attitude and practices.

## Greed

**The Dangers of Greed.** Greed is the desire for money and possessions, a craving for more than what we have, and not being satisfied or content. Both the Old and New Testaments warn us about the danger of greed and its consequences.

- **Exodus 20:17** (the tenth commandment) says that it is wrong to covet anything that belongs to your neighbor. Covet means "to want to have the possessions of others." It is much more than admiring what others have, but includes feeling envy, and resenting the fact that others have what you don't have. While the word "neighbor" means anyone outside ourselves, isn't it often those closest to us—our friends, work colleagues, and those who live next door (our literal neighbors)—of whom we are jealous? Those closest to us have the greatest potential to create feelings of covetousness in us, as we so easily see what *they* have and what *we* do not.
- **Ecclesiastes 5:10** says that if we love money we'll never have enough or be completely satisfied.
- **Luke 12:15–21.** Jesus tells us to "be on our guard against all kinds of greed," and that how much we own is not the "true" purpose or meaning of our life. He reminds us that:
    - ◊ we need to *be on our guard.* Why? Because greed often lurks at the door of our lives. We need to be aware of this and take action to protect ourselves.
    - ◊ there are *all kinds of greed.* Greed is like temptation that comes in many different ways which are not always obvious. Greed can be present in different areas of our lives.
    - ◊ we need to remember *the true purpose or meaning of our life is not how much we own.* Remembering this will stop greed taking a hold of our lives.

- **1 Timothy 6:9–10** tells us how greed and the love of money will lead us into foolish and harmful desires that end in ruin and destruction. In addition, the love of money is a root of all kinds of evil: it can lead us to wander from our faith and experience much grief or sorrow. Once we let greed enter our lives, the end result will surely be bad for us.

**Are We Trying to Serve Two Masters?** The tax collectors in Jesus' time were greedy for money, and took from the poor more than they should have for their own gain. While I hope that we don't exercise this extreme form of greed, we probably do struggle with mixed motives, if we are truly honest.

While trying our best to follow and serve God, we may sense the subtle temptation to try to serve money at the same time. Although our hearts deceive us into thinking we can somehow serve both these "masters," Matthew 6:24 tells us clearly what Jesus thinks: "you *cannot* serve both God and money."

1 Tim 6:5 warns us about wrongly supposing that "godliness is a means to financial gain." The Bible gives us many examples of those who tried to "serve two masters," and the consequences for their lives. It is good to learn from their mistakes:

- In Luke 18:18–24, the rich young ruler kept all the commandments of God since he was a child, so was a morally upright man. He had only one weakness—he loved money also. His mixture of motives was a desire to please God but also a love of riches. The result of his meeting with Jesus was that he "walked away sorrowfully." Jesus used this example to teach how difficult it is for those who love riches to enter the kingdom of heaven.
- In Matthew 26:14–15 we read of Judas, who is probably the clearest example of greed in the Bible. He was a disciple of Jesus, but his love for money was used by Satan to get him to betray the Lord. He received thirty pieces of silver, but committed suicide soon after.

- In Acts 5:1–4, Ananias and Sapphira generously sold their land and gave the proceeds to the church, but secretly kept back part of the money they had received. They were trying to serve God by being generous to the church, but wanted some of the money and the praise of people for themselves. When they lied to Peter about keeping some of the money secretly for themselves, they came under the judgment of God and died.
- Numbers 22–24 tells the story of Balaam, a prophet of God in the early days of Israel. He tried to use the special power that God had given him for personal gain. Because of his desire for money, he was hired to curse God's people. Balaam had a mixture of motives—he was committed to obey God, yet he also desired personal gain. 2 Peter 2:15 says that he loved the "wages of wickedness." Later, he lost his money and his life.

## Contentment

Contentment is "realizing that God has given to us everything we *need* for our present happiness." What we *need* is very different from what we *want*! The Bible encourages us to be at peace and satisfied with:

- *what we have.* The world around us tells us that more and more possessions will bring us happiness. But Heb 13:5 says to "keep your lives free from the love of money and be content with what you have."
- *whatever our circumstances are, be they good or bad.* We need to follow Paul's example when he says, "I have learned to be content whatever the circumstances, whether well fed or hungry, whether living in plenty or in want" (Phil 4:11–12).
- *what we earn* (Luke 3:14). It is easy to compare our pay with that of others, and to feel not happy that they receive more than we. Our attitude instead should be that "we work with all our heart, as working for the Lord, not for men, since we know that we will receive . . . from the Lord . . . a reward" (Col 3:23–24).

- *others being blessed or having an advantage over us.* In Gen 13:8–11, Abraham allowed Lot to take first choice of the land which lay before them. He was content for Lot to be blessed with more fertile land, rather than taking it for himself. If we learn contentment, we can be happy with others being blessed or having more than we.

**Three Secrets of Contentment.** The first secret of being content lies in our attitude. We need to be *grateful* and to *enjoy what we have* (money, possessions, health, family), rather than *complain about what we don't have.* We should not compare what we are or have with those around us, as this results only in pride (if we have more) or envy (if we have less).

The second secret is based on our relationship with God. The best example is found in Paul, whose "secret" of contentment was being able to draw on the inner strength of God in his life for everything he needed (Phil 4:13).

Third, we can be content by always remembering the following truths:

- God will never leave us or forsake us (Heb 13:5). The assurance of God's faithfulness and presence in our lives will bring us contentment, whatever our financial situation.
- We brought nothing into this world when we were born, and we can take nothing out when we die (1 Tim 6:7). Our money and possessions are only temporary, and have no value in eternity once we have finished here (Matt 6:19). Godliness with contentment is great gain (1 Tim 6:6). A contented and godly life is of greater benefit than trying to accumulate possessions.
- Having sufficient for our needs should be our goal. The writer of Prov 30:8–9 says, "Give me neither poverty (too little) nor riches (too much), but give me only my daily bread (just enough to satisfy), otherwise I may have too much and forget you, or I may become poor and steal and dishonor the name of my God."

Having the above attitudes, relying on God's strength rather than our own, and remembering the truths of God's word, will help us to be content whatever circumstances we face.

## Giving

We support God's work and purposes in the world by giving to His people and those in need. In giving to others, our inner motivation is of primary importance.

**Three Reasons for Giving.** "Freely you have received, freely give," says Matt 10:8. "God loved the world so much, that He gave His one and only Son," reads the familiar John 3:16. First, then, *we give to others as a natural response to having received* so much from God. When we truly appreciate all that we have received from God, we should freely want to give to others, out of gratitude for what God has generously given us.

Second, *giving breaks the power of greed and materialism* (placing too much importance on material things) in our lives. 1 Tim 6:17–18 encourages us *not* to put our hope in wealth, but to put our hope in God and to *be generous and willing to share.* Similarly, in Luke 18:22 Jesus encourages the rich young ruler to "sell all you have, *and give to the poor. . . .*" The practice of deliberately giving to others destroys the power of greed and of "wanting of more and more" which can so easily take hold of our lives.

In Acts 20:35 Jesus said that "it is more blessed to give than to receive." The generous man will himself be blessed, says Prov 22:9. Thus the third reason for giving is that when we generously do so, *we in turn receive God's blessings.* 2 Cor 9:6 describes the law of sowing and reaping as "whoever sows sparingly will also reap sparingly, and whoever sows generously will also reap generously." When we give generously, we will receive blessings from God in ways we may not ever have imagined. Luke 6:38 encourages our giving by promising that "in the same measure that we give, so we will receive." How much we

give *out* to others will determine how much we receive *into* our lives.

**To Whom Should We Give?** The Bible tells us that we should give to:

- Those who work and minister in the church. 1 Tim 5:17; 1 Cor 16:1
- God's people who are in need. Rom 12:13; 2 Cor 8:14; James 2:14–17
- Those from whom we receive spiritual encouragement or teaching. Rom 15:27; Gal 6:6
- The poor and needy. Matt 6:2

Prov 19:17 says that he who is kind to the poor lends to the Lord, and he will reward him for what he has done. If we "lend" to the Lord, He will surely reward us later.

**How Much Should We Give?** Ten percent of income (the tithe) is clearly mentioned in the Old Testament (Mal 3:8–10). While the New Testament does not provide a specific figure, the principles of tithing in Deut 14:22–28, as well as the principle generosity noted above in 2 Cor 9:6 and Luke 6:38, indicate we should give at least ten percent, and more, as God prospers us financially.

The following examples of giving in the Bible, help guide us further:

- Malachi 3:8 indicates we can be *robbing God if we don't give* what is rightfully His—if we do tithe (v 10), we will receive tremendous blessing.
- Abraham offered *10% of everything* he had to the priest in Gen 14:20.
- God's people should give *in proportion to the way God has blessed* them (Deut 16:17).
- The Corinthians gave even *beyond their ability* in 2 Cor 8:3.
- Cornelius gave *generously* to those in need in Acts 10:2
- A poor widow put in *all she had* to live on in Mark 12:44

- David desired to give only what has *cost him something personally* in 2 Sam 24:24
- In the early church *all possessions* were shared among the believers (Acts 4:32).

**How Should We Give?**

We should give . . . to God the *first and the best* from the wealth we gain. Prov 3:9

We should give . . . *cheerfully*, not reluctantly or under compulsion. 2 Cor 9:7

We should give . . . *generously* on every occasion. 2 Cor 9:11

We should give . . . with our *very best effort.* 2 Cor 8:7

We should give . . . *in secret* so that no one but God himself can see us. Matt 6:3-4

We should realize that . . . it is a *privilege* to give to God's people. 2 Cor 8:4

We should have . . . a *discipline of setting aside money* each week in accordance with our income. 1 Cor 16:2

May our generous gifts, as Paul says, prove to be a "fragrant offering, an acceptable sacrifice, pleasing to God." As a result of our giving, there is the wonderful promise that "God will (in turn) meet all our needs according to his glorious riches in Christ Jesus" (Phil 4:18–19).

សំណុំឯកសារ ១/២ (តុលា ២០០០): ៥៦-៦៧

# ព្រះ និង ប្រាក់

ដោយ រ៉ូបឺត ឆយ

*******

នៅពេលដែលអ្នកបានអានអត្ថបទនេះ តើចំណាប់អារម្មណ៍ដំបូងរបស់អ្នកជាអ្វីទៅ? មានមនុស្សជាច្រើនមិនបានគិតថារឿងព្រះ និង ប្រាក់នេះត្រូវទៅស្របជាមួយគ្នានោះឡើយ តែយ៉ាងហោចណាស់ក៏មិនដូចគ្នាព្រះជាម្ចាស់ និង សេចក្តីស្រឡាញ់ ឬ ព្រះជាម្ចាស់ និង ជំនឿនោះបានទេ ។ ចំពោះអ្នកខ្លះ គឺគេចាំយ៉ាងច្បាស់នៅក្នុងគំនិតរបស់គេនូវព្រះគម្ពីរដ៏ល្បីល្បាញមួយ ខដែលចែងថា "ការស្រឡាញ់ប្រាក់នោះជាឫសគល់នៃអំពើអាក្រក់" សូម្បីតែគិតអំពី"ប្រាក់"ក៏គេគិតថាខុសឆ្គង ចំពោះជំនឿគ្រីស្ទបរិស័ទរបស់គេដែរ ។

ក្នុងការពិចារណាចំពោះផ្នែកនេះ យើងចាប់ផ្តើមស្មោះត្រង់ជាមួយខ្លួនយើងជាមុនសិន ។ ដ្បិតក្នុងចំណោមគ្នាយើងភាគច្រើន រឿងនេះមានន័យថាព្រមទទួលស្គាល់ដល់ជម្រៅដួងចិត្តរបស់យើង យើងយល់ឃើញថាសន្តិសុខ/ក្តីសុខសាន្ត ដែលប្រាក់អាចទិញរបស់អ្វីផ្សេងៗ និង ជួយសម្រួលរឿងគ្រប់យ៉ាងសំរាប់យើង ។ យើងទទួលស្គាល់ថា យើងមានសេចក្តីត្រូវការយ៉ាងពិតជាក់ស្តែងសំរាប់ការប្រើប្រាក់ នៅក្នុងការរស់នៅប្រចាំថ្ងៃរបស់យើង ដូចជា អាហារ ជំរកស្នាក់នៅ ថ្លៃដឹកជញ្ជូន ចំណាយនៅក្នុងគ្រួសាររបស់យើង និង សេចក្តីត្រូវការស្របច្បាប់របស់យើងផ្សេងៗទៀត ។ ក្រោយមកទៀតមានរបស់ជាច្រើនដែលយើងឃើញអ្នកដទៃមាន ហើយនិងយើងចង់មានដូចគេដែរ នោះដូចជា ខោអាវថ្មី កង់ថ្មី ឬ ឡានថ្មី ជាដើម . . . ។

មនុស្សជាច្រើន ដែលបានអានអត្ថបទនេះនឹងដឹងច្បាស់ពីការដែលត្រូវតែមានប្រាក់តិចតួច ឬ មិនចាំបាច់មានប្រាក់សោះនោះ ។ ក្នុងខណៈដែលកម្ពុជា

ជាប្រទេសកំពុងអភិវឌ្ឍន៍ បញ្ហាលុយកាក់ ជាបញ្ហាធ្ងន់ធ្ងរមែនទែន ដោយមានអំពើពុករលួយជាមួយប្រាក់នេះ គ្រប់ជាន់ថ្នាក់ទាំងអស់នៅក្នុងសង្គម ។

យើងមានឱកាសក្នុងការជ្រើសរើសដើម្បីធ្វើការសម្រេចចិត្ត ។ យើងអាចឲ្យមជ្ឈដ្ឋាន ដែលនៅជុំវិញយើងមានឥទ្ធិពលគ្របដណ្តប់មកលើឥរិយាបទ និង ការប្រព្រឹត្តិរបស់យើង ឬ ក៏យើងអាចរកព្រះបន្ទូលព្រះ ដែលបានចែងពីប្រាក់ ហើយនិងប្រើព្រះគតិបណ្ឌិតនោះ នៅក្នុងជីវិតរបស់យើងបាន ។ អត្ថបទនេះមានបំណងជួយបង្គ្រប់នូវ ចំណុចខ្វះខាតចុងក្រោយ ដើម្បីឲ្យយើងអាច "រស់នៅក្នុងជីវិត បែបគួរនឹងព្រះអម្ចាស់ និងគាប់ព្រះហឫទ័យ នៅក្នុងគ្រប់ទាំងផ្លូវ (កូល៉ុស១:១០) ។ ដោយហេតុតែ ព្រះជាម្ចាស់យកព្រះហឫទ័យទុកដាក់ជាដំបូងលើសន្ទុះចិត្ត និង ដួងចិត្តពិតប្រាកដរបស់យើងនៅឯណានោះ យើងនឹងពិចារណាមើលនូវ "អកប្បកិរិយា" ដែលមនុស្សយើងជាទូទៅមានចំពោះប្រាក់ដូចជា ការលោភលន់ ការស្អប់ចិត្ត និង ការថ្វាយដង្វាយ/ការចែកទាន ។ នៅក្នុងអត្ថបទ ជាបន្ទាប់ក្នុងការបោះពុម្ពលើកក្រោយរបស់ សំណុំទឹកឃ្មុំ យើងនឹងពិនិត្យមើលព្រះបន្ទូលព្រះជាម្ចាស់ ដែលចែងពីទិដ្ឋភាព "ជាក់ស្តែង" នៃការចាត់ចែងពីប្រាក់កាស ដូចជាការរកប្រាក់ ការចំណាយប្រាក់ ការសន្សំប្រាក់ និង ការជាប់បំណុលដោយសារប្រាក់ ។

**ហេតុអ្វីបានជាយើងត្រូវសិក្សាអំពី "ព្រះ និង ប្រាក់"** ?

នេះនែ៎ ជាហេតុផលទាំងប្រាំមួយយ៉ាងដូចតទៅ៖

- ពីព្រោះព្រះគម្ពីរបាន ចរទ្រៀង អំពីប្រាក់នេះ ។ មានខគម្ពីរយោងជាង ៧០០ ដែលនិយាយទាក់ទងជាមួយនឹងប្រាក់ ឬ ទ្រព្យសម្បត្តិ ។ រឿងប្រៀបប្រដូច និង សេចក្តីបង្រៀនរបស់ព្រះយេស៊ូ តែងតែប្រើប្រាក់ ជាឧទាហរណ៍ពន្យល់ឲ្យយល់ពីសេចក្តីពិត អំពីព្រះជាម្ចាស់ និង អាណាចក្ររបស់ព្រះអង្គ ដូចជារឿងប្រៀបប្រដូច បុរសអ្នកមានម្នាក់ រឿងប្រៀបប្រដូចប្រាក់ពាន់ ស្ត្រីមេម៉ាយក្រីក្រម្នាក់ ដែលបានថ្វាយទាំងអស់នូវអ្វីដែលគាត់មានរឿងប្រៀបប្រដូចពីបុរសអ្នកមាន/ថៅកែម្នាក់ ដែលបានសង់ជង្រុកស្រូវជាដើម ។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់មិនបាននៅស្ងៀមស្ងាត់ មិនចែងពីលុយកាក់នោះឡើយ បើព្រះបន្ទូលបានចែងពីរឿងនេះ អ៊ីចឹងប្រាកដជាសំខាន់ហើយរឿងនេះ!

- ពីព្រោះតែប្រាក់អាចធ្វើឲ្យយើង **ជាប់អន្ទាក់** និង ក៏អាចបោកបញ្ឆោតយើងដែរ ។ ព្រះគម្ពីរបានព្រមានយើងចំពោះការឆបោក និង ការគ្រោះថ្នាក់ដោយសារស្រឡាញ់ប្រាក់ ។ នៅពេលដែលយើងចង់ក្លាយជាអ្នកមាននោះ យើងអាចក្លាយទៅជាធ្លាក់ទៅក្នុងសេចក្តីល្បួង និង ធ្លាក់ទៅក្នុងសេចក្តីប៉ងប្រាថ្នាដែលល្ងីល្ងើ និង ប្រកបដោយគ្រោះថ្នាក់ជាច្រើន ដែលជាហេតុអាចនាំមកនូវក្តីហិនវិនាស និង សេចក្តីអន្តរាយផ្សេងៗ (១ ធីម៉ូថេ ៦:៩) ។
- ពីព្រោះប្រាក់ អាច **សាកល្បងល** មើលពីចិត្តរបស់យើងថា តើចិត្តរបស់យើងពិតជាស្មោះស្ម័គ្រចំពោះព្រះជាម្ចាស់ ឬ ក៏អត់នោះទេ ។ ចិត្តរបស់មនុស្សយើង ដែលប្រកបដោយការបោកបញ្ឆោតបានធ្វើឲ្យយើងគិតទៅដល់ការស្រឡាញ់ប្រាក់ នៅក្នុងខណៈដែលយើងកំពុងបំរើព្រះជាម្ចាស់នោះក៏អាចទៅរួចដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ យើងអាចបញ្ឆោតខ្លួនយើងបានតែយើងមិនអាចបញ្ឆោតព្រះជាម្ចាស់បានឡើយ ។ ម៉ាថាយជំពូក ៦ បានថែងថា បើទ្រព្យសម្បត្តិប្រាក់កាសរបស់យើងនៅឯណា ចិត្តរបស់យើងនឹងដក់ នៅកន្លែងនោះដែរ ។ គឺច្បាស់ណាស់ដែលថា "អ្នកមិនអាចបំរើព្រះ និង បំរើប្រាក់ ផងបានទេ ។"
- ដើម្បីឲ្យយើងអាច **ឧកចិត្ត** ដល់ព្រះជាម្ចាស់ និង មិនឲ្យយើងភ្លេចព្រះអង្គនៅពេលដែលយើងមានប្រាក់ និង មានទ្រព្យសម្បត្តិ ។ គឺងាយណាស់ក្នុងការធ្វើឲ្យយើងមានអំនួត និង ភ្លេចព្រះ នៅពេលដែលយើងក្លាយជាអ្នកមានស្តុកស្តម្ភ ។ យើងត្រូវចងចាំថា ព្រះជាម្ចាស់ទេតើ ដែលផ្តល់ឲ្យយើងមានលទ្ធភាព ដើម្បីរកប្រាក់បាន (ចោទិយកថា ៨:១៣-១៤, ១៧-១៨) ។
- ដើម្បីឲ្យថ្ងៃមួយព្រះជាម្ចាស់អាចផ្ទុកផ្តាក់ឲ្យយើងមើលថែ "សម្បត្តិដ៏ ពិត " ដែលមានតម្លៃអស់កល្បជានិច្ច ។ បើសិនជាយើងស្មោះត្រង់ក្នុងការមើលថែប្រាក់កាស ឬ "សម្បត្តិលោកិយ" នេះ ដោយប៉ិនប្រសប់នោះ ព្រះជាម្ចាស់នឹងផ្ទុកផ្តាក់ឲ្យយើងមើលថែសម្បត្តិ ដ៏ពិតរបស់ព្រះអង្គ ដែលមានតម្លៃដ៏មហាសាលអស់កល្បជានិច្ច (លូកា ១៦:១១) ។
- ដើម្បីឲ្យព្រះជាម្ចាស់អាច **ចំផ្លាស់ចំប្រែ** ការយល់ដឹងរបស់យើងស្តីពីប្រាក់ តែមិនឲ្យយើងត្រាប់តាមឥរិយាបទ និង ការប្រព្រឹត្តិរបស់លោកិយ ដែលទាក់ទងទៅនឹងរឿងប្រាក់កាស ។

### សេចក្ដីលោភលន់

គ្រោះថ្នាក់នៃការលោភលន់ ។ សេចក្ដីលោភលន់ គឺជាការប៉ងប្រាថ្នាចង់បានកាន់តែច្រើនឡើងៗ ជាងអ្វីដែលយើងមាន ហើយនិង មិនដែលស្កប់ស្កល់ចិត្ត ឬ ពេញចិត្តនូវអ្វីដែលខ្លួនមានឡើយ ។ ទាំងគម្ពីរសញ្ញាចាស់និង សញ្ញាថ្មីព្រមានយើងពីសេចក្ដីគ្រោះថ្នាក់នៃការលោភលន់ និង ផលវិបាកនៃការលោភលន់នោះ ។

- និក្ខមនំ ២០:១៧ (ក្រឹត្យវិន័យទាំងដប់ប្រការ) បានចែងថា ការកេងយករបស់អ្វីពីអ្នកជិតខាងខ្លួននោះ មិនត្រឹមត្រូវឡើយ ។ ការកេងយកមានន័យថា "ចង់បានរបស់អ្នកដទៃ" ។ គឺមិនបានកោតសរសើរដល់អ្នកដទៃ ដែលឃើញគេមាន តែបែរជាច្រណែនឈ្នានីសដល់អ្នកដទៃ ដោយព្រោះគេមានជាងខ្លួន ។ ពាក្យថា "អ្នកជិតខាង" គឺមានន័យថា អ្នកដែលមិនជាខ្លួនយើង មែនទេ? អ្នកទាំងនោះជាទូទៅនៅជិតដិតនឹងយើង គឺដូចជាមិត្តសម្លាញ់របស់យើង សហការី ដែលធ្វើការជាមួយយើង និង អ្នកដែលនៅជាប់របងជាមួយយើង (ជាអ្នកជិតខាង) ដែលយើងច្រណែន ។ អ្នកទាំងនោះ ដែលនៅជិតដិតនឹងយើង មានសក្ដានុពលធំធេងណាស់ ដែលធ្វើឲ្យយើងមានអារម្មណ៍នៃការចង់កេងយករបស់គេ ដោយយើងឃើញថាគេមានតែយើងមិនមានដូចគេ ។
- សាស្ដា ៥:១០ បានចែងថា បើយើងស្រឡាញ់ប្រាក់ យើងមិនដែលមានគ្រប់គ្រាន់ទេ ឬ ក៏មិនដែលបានស្កប់ចិត្តដែរ ។
- លូកា ១២:១៥-២១ ព្រះយេស៊ូមានបន្ទូលប្រាប់មកយើងថា "ចូរប្រយ័ត្ន ហើយខំចៀសវាងពីគ្រប់ទាំងសេចក្ដីលោភចេញ" ហើយនិងបានបញ្ជាក់ថា យើងមានច្រើនប៉ុណ្ណា នោះមិនមែនជាគោលដៅ "ពិត" ឬ ក៏អត្ថន័យពិតនៃជីវិតរបស់យើងទេ ។ ព្រះអង្គបានរំលឹកយើងថា៖
    - យើងត្រូវ*តែប្រយ័ត្ន* ហេតុអ្វី? ពីព្រោះការលោភលន់ តែងតែលបចាំនៅឯមាត់ទ្វារជីវិតរបស់យើង ។ យើងត្រូវដឹងពីរឿងនេះ និង ប្រយ័ត្នការពារខ្លួនយើផ្ទាល់ ។
    - *សេចក្ដីលោភលន់មានច្រើនប្រភេទ* ។ សេចក្ដីលោភលន់គឺដូចជាសេចក្ដីល្បួង ដែលមកពីគ្រប់មធ្យោបាយផ្សេងៗ ដែលតែងតែ

មើលមិនឃើញច្បាស់សោះ ។ សេចក្តីលោភលន់អាចនៅក្នុងជីវិតរបស់យើងនៅពេលនេះក្នុងផ្នែកផ្សេងៗ ។

- យើងត្រូវចងចាំពី*គោលដៅពិត ឬ អត្ថន័យពិតរបស់ជីវិតរបស់យើងមិនអាស្រ័យលើអ្វីដែលយើងមាននោះទេ* ។ ការចងចាំនេះនឹងជួយបញ្ឈប់នូវសេចក្តីលោភលន់ មិនឲ្យមកចាក់ឫសនៅក្នុងជីវិតរបស់យើង ។

- ១ ធីម៉ូថេ ៦:៩-១០ ប្រាប់យើងនូវផលវិបាកនៃសេចក្តីលោភលន់ និង សេចក្តីស្រឡាញ់ប្រាក់ ដែលនឹងនាំឲ្យយើងធ្លាក់ទៅក្នុងសេចក្តីប៉ងប្រាថ្នាដ៏ល្ងីល្ងើ និង ប្រកបដោយគ្រោះថ្នាក់ជាទីបំផុត ដែលនៅពេលចុងក្រោយឲ្យមានភាពអន្តរាយ និង ការវិនាសបង់ ហើយនិងបានចែងថា ការស្រឡាញ់នោះគឺជាឫសគល់នៃអំពើទុច្ចរិតទាំងអស់ និងអាចនាំឲ្យយើងវង្វេងចេញពីជំនឿ និង ប្រឈមមុខនឹងសេចក្តីទុក្ខព្រួយយ៉ាងខ្លាំង ។ នៅពេលដែលយើងអនុញ្ញាតឲ្យសេចក្តីលោភលន់ចូលមកក្នុងជីវិតរបស់យើង លទ្ធផលចុងក្រោយពិតជាអាក្រក់ណាស់សំរាប់យើង ។

**តើយើងកំពុងព្យាយាមបំរើចៅហ្វាយពីរឬ?** ពួកអ្នកទារពន្ធ កាលពីសម័យព្រះយេស៊ូគឺលោភលន់ចង់បានប្រាក់ណាស់ និងគេបានយកពន្ធពីអ្នកក្រលើសពីច្បាប់តម្រូវឲ្យបង់ពន្ធដោយព្រោះអ្នកយកពន្ធទាំងនោះ គេបានយកជាប្រយោជន៍ផ្ទាល់ខ្លួនរបស់គេ ។ ខ្ញុំសង្ឃឹមថា យើងមិនប្រើនូវរបៀបលោភលន់ដ៏ហួសហេតុនេះទេ យើងប្រហែលជាមានអារម្មណ៍ច្របូកច្របល់នៅក្នុងចិត្ត បើសិនជាយើងពិតជាស្មោះត្រង់មែន ។

នៅពេលដែលយើងព្យាយាមអស់ពីសមត្ថភាពរបស់យើង ដើម្បីដើរតាម និង បំរើដល់ព្រះជាម្ចាស់ សេចក្តីល្បួងដែលលេចធ្លោរឡើង គឺយើងព្យាយាមបំរើប្រាក់នៅពេលជាមួយគ្នា ។ ទោះបីជាចិត្តរបស់យើងបោកបញ្ឆោតយើងឲ្យគិតថា យើងអាចបំរើ "ចៅហ្វាយ" ទាំងពីរក៏ដោយ គម្ពីរម៉ាថាយ ៦:២៤ បានចែងយ៉ាងច្បាស់នូវអ្វី ដែលព្រះយេស៊ូទ្រង់ព្រះតំរិះថា៖ "អ្នករាល់គ្នាមិនអាចបំរើព្រះផង និង ប្រាក់ផងបានទេ" ។

១ ធីម៉ូថេ ៦:៥ ព្រមានយើងអំពីការគិតខុសឆ្គង ដែលថា "ការកោតខ្លាចព្រះ ជាមធ្យោបាយ ដើម្បីបានចំណេញប្រាក់ ។" ព្រះគម្ពីរបានផ្តល់ឲ្យយើងនូវគំរូ

ជាច្រើននៃអស់អ្នកណាដែលបានព្យាយាម "បំរើចៅហ្វាយពីរ" ហើយនិងផលវិបាកទាំងឡាយ នៅក្នុងជីវិតរបស់គេ ។ គឺមានប្រយោជន៍ ដែលយើងត្រូវរៀនពីកំហុសរបស់ពួកគេគឺ:

- នៅក្នុងគម្ពីរ លូកា ១៨:១៨-២៨ មានតាម៉ឺនវ័យក្មេង ដែលមានស្តុកស្តម្ភម្នាក់ ដែលគោរពប្រតិបត្តិដល់គ្រប់ទាំងបញ្ញត្តិរបស់ព្រះជាម្ចាស់តាំងពីក្មេង ដូច្នេះ គាត់ជាមនុស្សសុចរិតល្អណាស់ ។ គាត់មានចំណុចខ្សោយមួយ គឺគាត់ស្រឡាញ់ប្រាក់ដែរ ។ គាត់មានទឹកចិត្តច្របូកច្របល់ ដោយចង់ផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់ផង តែស្រឡាញ់ទព្យសម្បត្តិផង ។ ក្រោយពីគាត់បានជួបជាមួយព្រះយេស៊ូរួចមក គាត់ "បានដើរចេញទៅទាំងកើតទុក្ខព្រួយ" ។ ព្រះយេស៊ូបានប្រើគំរូនេះ ដើម្បីបង្រៀនឲ្យដឹងពីការលំបាករបស់អស់អ្នកណា ដែលស្រឡាញ់ទ្រព្យសម្បត្តិ គឺមានការពិបាកក្នុងការចូលទៅក្នុងនគរស្ថានសួគ៌ ។
- នៅក្នុងគម្ពីរ ម៉ាថាយ ២៦:១៤-១៥ យើងបានអានពីរឿងរបស់យូដាស ប្រហែលគាត់ជាអ្នកដែលជាគំរូដ៏ប្រសើរនៃការលោភលន់ នៅក្នុងព្រះគម្ពីរ ។ គាត់ជាសិស្សរបស់ព្រះយេស៊ូ ប៉ុន្តែគាត់ស្រឡាញ់ប្រាក់ដែលអាក្រក់វាប្រើឲ្យគាត់ក្បត់នឹងព្រះយេស៊ូ ។ គាត់បានទទួលប្រាក់ ៣០ ដុំ ប៉ុន្តែគាត់ក៏ធ្វើអត្តឃាដមិនយូរប៉ុន្មាន ក្រោយពីទទួលប្រាក់នោះរួចហើយ ។
- នៅក្នុងកិច្ចការជំពូក ៥:១-៤ អាណានាស និង សាភីរ៉ាមានចិត្តសទ្ធាជ្រះថ្លាបានលក់ដីរបស់គេ និង បាននាំមកថ្វាយដល់ពួកជំនុំ ប៉ុន្តែបានលួចទុកប្រាក់ដែលគេបានទទួលពីលក់ដីនោះមួយចំណែក ។ ពួកគេបានព្យាយាមបំរើព្រះជាម្ចាស់ចំពេក ដោយមានចិត្តសទ្ធាជាមួយនឹងពួកជំនុំ ប៉ុន្តែចង់បានប្រាក់ខ្លះ និងចង់បានការកោតសរសើរពីមនុស្សដទៃសំរាប់ខ្លួនឯង ។ នៅពេលដែលគេបានកុហកដល់ពេត្រុស ចំពោះរឿងលាក់ប្រាក់ទុកខ្លះ សំរាប់ប្រើការខ្លួនឯងនោះ ពួកគេត្រូវទទួលនូវការកាត់ទោសពីព្រះជាម្ចាស់ ហើយពួកគេក៏ស្លាប់ទាំងពីរនាក់ទៅ ។

ជនគណនាជំពូក ២២-២៤ ប្រាប់ពីរឿងរបស់បាឡាម ដែលជាព្យាការីរបស់ព្រះជាម្ចាស់នៅកាលពីសម័យដើម នៃប្រទេសអ៊ីស្រាអែល ។ គាត់បានព្យាយាមប្រើអំណាចចេស្តាដ៏ពិសេស ដែលព្រះជាម្ចាស់ផ្តល់ឲ្យគាត់ តែគាត់យក

អំណាចចេស្តានោះ ទៅប្រើជាប្រយោជន៍ផ្ទាល់ខ្លួនវិញ ។ ដោយសារតែគាត់ចង់បានប្រាក់ គេបានជួលគាត់ឲ្យដាក់បណ្តាសាដល់រាស្ត្ររបស់ព្រះជាម្ចាស់។ បាឡាមមានចិត្តរវើរវាយគឺថាគាត់ត្រូវតែគោរពស្មោះស្ម័គ្រ ចំពោះព្រះជាម្ចាស់ តែគាត់បែរទៅជាមានបំណងចំណេញផ្ទាល់ខ្លួន ។ នៅក្នុងគម្ពី ២ ពេត្រុស ២:១៥ បានចែងថា គាត់បានស្រឡាញ់ "កំរៃនៃការទុច្ចរិត" ។ ក្រោយមកគាត់ត្រូវបាត់បង់លុយអស់ និងបាត់បង់ជីវិតទៀត ។

## ការស្កប់ចិត្ត

ការស្កប់ចិត្តគឺជា "ការដឹងជាក់ថា ព្រះជាម្ចាស់បានផ្តល់ឲ្យយើងគ្រប់យ៉ាងដែលយើងត្រូវការ សំរាប់សុភមង្គលបច្ចុប្បន្នរបស់យើង" ។ អ្វីៗដែលយើងត្រូវការនោះគឺខុសពីអ្វី ដែលយើងចង់បាន! ព្រះគម្ពីរបានលើកទឹកចិត្តឲ្យមានសេចក្តីសុខសាន្ត និង ស្កប់ចិត្តជាមួយនឹង៖

- *អ្វីដែលយើងមាន* ។ មជ្ឈដ្ឋានដែលនៅជុំវិញយើងបានប្រាប់យើងថា មានទ្រព្យសម្បត្តិកាន់តែច្រើន និងនាំឲ្យយើងមានសុភមង្គល ។ ប៉ុន្តែនៅក្នុងគម្ពីរហេព្រើរ ១៣:៥ បានចែងថា "ចូរកុំឲ្យជីវិតអ្នករាល់គ្នាស្រឡាញ់ប្រាក់ ហើយនិង ចូរស្កប់ស្កល់ជាមួយនឹងអ្វី ដែលអ្នកមានហើយប៉ុណ្ណោះចុះ ។"
- *ទោះបីស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ ទោះការនោះល្អ ឬអាក្រក់ក៏ដោយ* ។ យើងត្រូវដើរតាមគំរូរបស់លោកសាវ័កប៉ូល នៅពេលដែលគាត់ និយាយថា "ខ្ញុំរៀនស្កប់ចិត្តនៅគ្រប់កាលៈទេសៈទាំងអស់ ខ្ញុំធ្លាប់ទាំងឆ្អែត ទាំងឃ្លាន ទាំងមាន ទាំងខ្វះខាត" (ភីលីព ៤:១២) ។
- *អ្វីដែលយើងអាចរកបាន* (លូកា ៣:១៤) ។ គឺជាការងាយធ្វើឲ្យយើងប្រៀបធៀបពីប្រាក់ខែរបស់យើងទៅនឹងប្រាក់ខែអ្នកដទៃ និង មិនសប្បាយចិត្តនៅពេលឃើញគេមានប្រាក់ខែច្រើនជាងយើង ។ យើងគួរតែមានឥរិយាបថមួយដែលថា "យើងខំធ្វើការដោយអស់ពីចិត្តរបស់យើង ទុកដូចជាការធ្វើថ្វាយព្រះអម្ចាស់មិនមែនធ្វើសំរាប់ផ្គាប់ដល់មនុស្សឡើយ ព្រោះយើងដឹងថានឹងទទួលបានរង្វាន់ពីព្រះអម្ចាស់មក" (កូល៉ុស ៣:២៣-២៤) ។
- *អ្នកដទៃដែលបានទទួលព្រះពរ ឬ មានអត្ថប្រយោជន៍លើសយើង* ។ នៅក្នុងលោកុប្បត្តិ ១៣:៤-១១ អាប្រាហាមបានអនុញ្ញាតឲ្យ ឡុត ជ្រើសរើសយកដីមុនគេ គឺជាដីដែលនៅចំពីមុខគេ ។ គាត់សប្បាយរីករាយ ដោយបានទទួល

នូវព្រះពរចំរុងចំរើន ដោយបានទឹកដីមានដីជាតិល្អ ដោយមិនដណ្តើមយកជារបស់សំរាប់ខ្លួនឯងឡើយ ។ បើយើងដឹងពីការស្កប់ចិត្ត នោះយើងនឹងអាចសប្បាយរីករាយនៅពេលដែលយើងឃើញ អ្នកដទៃបានទទួលព្រះពរ ឬមានច្រើនជាងយើង ។

**អាថ៌កំបាំង ពី យ៉ាង នៃការស្កប់ចិត្ត** ។ អាថ៌កំបាំងទីមួយ នៃការស្កប់ចិត្តនោះគឺស្ថិតលើឥរិយាបថរបស់យើង ។ យើងត្រូវតែមានភាពកត្តញ្ញូ និងរីករាយនឹងអ្វីដែលយើងមាន (ប្រាក់ ទ្រព្យ សុខភាព គ្រួសារ) មិនត្រូវឲ្យយើងរអ៊ូរទាំចំពោះអ្វីដែលយើងមិនមាន ។ យើងមិនត្រូវប្រៀបធៀបនូវអ្វីដែលយើងមាន ឬប្រៀបខ្លួនយើងទៅនឹងមនុស្សដែលនៅជុំវិញយើងឡើយ គឺហុចផលមកឲ្យមានតែសេចក្តីអំនួតតែប៉ុណ្ណោះ(បើសិនជាយើងមានច្រើនជាងគេ) ឬនាំឲ្យយើងច្រណែន (បើយើងមានតិចជាងគេ) ។

អាថ៌កំបាំងទី ២ គឺផ្អែកលើទំនាក់ទំនងរបស់យើងជាមួយនឹងព្រះជាម្ចាស់ ។ គំរូដ៏ល្អបំផុតនោះ យើងប្រទះឃើញនៅក្នុងជីវិតរបស់លោក ប៉ូល ដែលគាត់មាន "អាថ៌កំបាំង" នៃការស្កប់ចិត្ត ដែលអាចផ្តល់កម្លាំងឲ្យគាត់អាចធ្វើការអ្វីគ្រប់យ៉ាងនៅក្នុងជីវិតរបស់គាត់ ដោយព្រោះព្រះជាម្ចាស់ផ្តល់កម្លាំង ឲ្យគាត់ (ភីលីព ៤:១៣) ។

ទីបី យើងអាចស្កប់ស្កល់ចិត្ត ដោយសារតែការចងចាំនូវសេចក្តីពិតដូចខាងក្រោមនេះគឺ៖

- ព្រះជាម្ចាស់មិនដែលចាកចោលយើងទេ (ហេព្រើរ ១៣:៥) ការធានាអះអាងពីសេចក្តីស្មោះត្រង់ និង ព្រះវត្តមានរបស់ព្រះជាម្ចាស់ នៅក្នុងជីវិតរបស់យើងនឹងនាំឲ្យយើងមានការស្កប់ស្កល់ក្នុងចិត្ត ទោះបីជាយើងមានស្ថានភាពលំបាកលំបិនផ្នែកប្រាក់កាសក៏ដោយ ។
- យើងមិនបានយកអ្វីមកសោះ នៅពេលដែលយើងកើតមកក្នុងលោកិយនេះ ហើយ និង មិនអាចយកអ្វីចេញពីនេះទៅវិញបាន នៅពេលដែលយើងស្លាប់ (១ ធីម៉ូថេ ៦:៧) ។ ប្រាក់កាស និង ទ្រព្យធនរបស់យើងគ្រាន់តែជាការបណ្តោះអាសន្នតែប៉ុណ្ណោះ ហើយនិងមិនមានតម្លៃអ្វីទាំងអស់ នៅពេលដែលយើងចប់ពីលោកិយនេះទៅ (ម៉ាថាយ ៦:១៩) ។ ការគោរពប្រតិបត្តិព្រះដែលមានទាំងចិត្តស្កប់ស្កល់ផង នោះគឺជាកំរៃធំមែនទែន (១ ធីម៉ូថេ ៦:៦) ។

ការស្កប់ចិត្ត និង ជីវិតដែលកោតខ្លាចព្រះនោះគឺជាអត្ថប្រយោជន៍ធំធេងជាងការខំព្យាយាមប្រមូលទ្រព្យធនទៅទៀត ។

- ការមានគ្រាន់តែគ្រប់ល្មមសំរាប់សេចក្ដីត្រូវការរបស់យើងនោះគឺជាទិសដៅរបស់យើងហើយ ។ អ្នកនិពន្ធបទគម្ពីរសុភាសិត ៣០:៨-៩ បានចែងថា "សូមកុំឲ្យទូលបង្គំទីទ័លក្រ(មានតិចពេក) ឬ មានស្ដុកស្ដម្ភពេក(មានច្រើនពេក) តែសូមផ្ដល់ឲ្យទូលបង្គំមានអាហារប្រចាំថ្ងៃ(គ្រាន់តែគ្រប់ល្មម) ក្រែងលោទូលបង្គំមានច្រើនពេក ទៅជាភ្លេចព្រះអង្គ ឬ ក្រែងទូលបង្គំក្រពេក ទៅជាលួចគេនាំឲ្យខូចព្រះនាមរបស់ព្រះរបស់ទូលបង្គំ ។"

ការមានឥរិយាបថខាងលើនេះ គឺអាស្រ័យលើកម្លាំង ដែលព្រះជាម្ចាស់ប្រទានឲ្យមកមិនមែនពឹងលើកម្លាំងផ្ទាល់ខ្លួនឡើយ ហើយនិងការចងចាំពីព្រះបន្ទូលនៃសេចក្ដីពិតរបស់ព្រះនៃព្រះជាម្ចាស់ និង ជួយឲ្យយើងបានស្កប់ចិត្ត ទោះប្រឈមមុខនឹងកាលៈទេសៈណាក៏ដោយ ។

## ការថ្វាយដង្វាយ

យើងបានគាំទ្រដល់ការងាររបស់ព្រះជាម្ចាស់ និង គោលបំណងព្រះរាជហឫទ័យរបស់ព្រះអង្គ ដោយការថ្វាយដល់ប្រជារាស្ត្ររបស់ព្រះអង្គ និង អស់អ្នកដែលកំពុងត្រូវការ ។ ការឲ្យដល់អ្នកដទៃ គឺជាទឹកចិត្តខាងក្នុងរបស់យើង គឺជាការសំខាន់ទីមួយ ។

**មានហេតុផលបីយ៉ាងចំពោះការថ្វាយដង្វាយ** ។ "អ្នករាល់គ្នាបានទទួលដោយឥតគិតថ្លៃ ចូរឲ្យទៅវិញក៏មិនត្រូវសំចៃអ្វីដែរ" បទគម្ពីម៉ាថាយជំពូក ១០:៨ ។ "ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម្លេះ ទើបទ្រង់ ប្រទានព្រះរាជ បុត្រាទ្រង់តែមួយ" អាននៅក្នុងយ៉ូហាន ៣:១៦ ។ ដំបូង*យើងឲ្យទៅអ្នកដទៃ ដោយឆ្លើយតបជាធម្មតា ព្រោះការ ដែលបានទទួលជាច្រើន* រួចហើយមកពីព្រះជាម្ចាស់ ។ នៅពេលដែល យើងពិត ជាដឹងគុណានូវអ្វីទាំងអស់ ដែលយើងបានទទួលពីព្រះជាម្ចាស់ យើងត្រូវប្រគល់ ឲ្យទៅអ្នកដទៃដោយមានចិត្តសទ្ធាដែរ ។

ទីពីរ *ការឲ្យនេះគឺធ្វើឲ្យអំណាចនៃសេចក្ដីលោភលន់ និង សម្ភារៈនិយមនៅក្នុងជីវិតបាក់បែក* (សម្ភារៈនិយមមានន័យថា ការគិតគូរពីការឲ្យតម្លៃលើសម្ភារៈធ្ងន់ពេក) ។ ១ ធីម៉ូថេ ៦:១៧-១៨ បានលើកទឹកចិត្តយើង មិនឲ្យដាក់សេចក្ដីសង្ឃឹមរបស់យើងទៅលើទ្រព្យសម្បត្តិ ប៉ុន្តែសូមដាក់សេចក្ដីសង្ឃឹមរបស់

យើងទៅលើព្រះជាម្ចាស់ និង *ត្រូវមានចិត្តសទ្ធា និង ព្រមចែកចាយដោយស្មោះ ស្ម័គ្រ* នៅក្នុងគម្ពីរ លូកា ១៨:២២ ព្រះយេស៊ូ បានលើកទឹកចិត្តដល់នាម៉ឺនវ័យ ក្មេងស្រដៀងគ្នានេះដែរ ដែលថា "ចូរលក់របស់របរដែលអ្នកមានទាំងអស់ *ហើយនិងចូរឲ្យរបស់នោះចែកទៅអ្នកក្រ . . .*" ទម្លាប់នៃការចែកឲ្យអ្នកដទៃដោយសុទ្ធចិត្តនោះ នឹងជួយបំផ្លាញដល់អំណាចនៃសេចក្ដីលោភលន់ និង ទម្លាប់ "ដែលចង់បានហើយចង់បានទៀត" គឺអាចចាក់ឫសនៅក្នុងជីវិតរបស់យើងយ៉ាងងាយស្រួល ។

នៅក្នុងគម្ពីរកិច្ចការ ជំពូក ២០:៣៥ ព្រះយេស៊ូមានបន្ទូលថា៖ «ការឲ្យនោះបានទទួលព្រះពរជាងការទទួល» ។ មនុស្សដែលសប្បុរស តែងបានទទួលព្រះពរ តាមបទគម្ពីរសុភាសិត ២២:៩ ។ ហេតុផលទី ៣ នៃការឲ្យ គឺថានៅពេលដែលយើងព្រមធ្វើការនោះដោយសទ្ធា*នោះយើងនឹងបានទទួលនូវព្រះពរត្រឡប់មកវិញ* ។ ២ កូរិនថូស ៩:៦ បានពណ៌នាពីច្បាប់នៃការព្រោះចុះ និង ការប្រមូលច្រូត កាត់ដែលបានចែងថា "អ្នកណាដែលបានព្រោះតិច និង ច្រូតបានតិច ហើយឯអ្នកណាដែលព្រោះច្រើននឹងច្រូតបានច្រើនដែរ" ។ នៅពេលដែលយើងឲ្យដោយសទ្ធា យើងនឹងបានទទួលព្រះពរពីព្រះជាម្ចាស់ក៏បានច្រើនលើសពីការស្មានទៅទៀត ។ លូកា ៦:៣៨ លើកទឹកចិត្តយើងអំពីការឲ្យរបស់យើង ដោយសេចក្ដីសន្យាថា "បើយើងវាល់ឲ្យគេប៉ុណ្ណានោះ យើងនឹងបានទទួលតាមរង្វាល់ដែលយើងបានវាល់ឲ្យគេនោះដែរ ។ យើងឲ្យទៅអ្នកដទៃច្រើនប៉ុណ្ណានោះ យើងនឹងបានទទួលមកក្នុងជីវិតយើងវិញបានច្រើនប៉ុណ្ណោះដែរ ។

***តើយើងត្រូវឲ្យទៅអ្នកណា?*** ព្រះគម្ពីរបានប្រាប់យើងថាយើងគួរឲ្យទៅ:

- អ្នកទាំងឡាយណាដែលយើងធ្វើការ និង បំរើព្រះជាម្ចាស់ជាព័ន្ធកិច្ចនៅក្នុងក្រុមជំនុំ ។ ១ ធីម៉ូថេ ៥:១៧; ១ កូរិនថូស ១៦:១ ។
- រាស្ត្ររបស់ព្រះដែលកំពុងខ្វះខាត រ៉ូម ១២:១៣; ២ កូរិនថូស ៨:១៤; យ៉ាកុប ២:១៥-១៧ ។
- អ្នកដែលយើងបានទទួលនូវការលើកទឹកចិត្ត ផ្នែកខាងឯព្រលឹងវិញ្ញាណ ឬ ទទួលនូវសេចក្ដីបង្រៀន ។ រ៉ូម ១៥:២៧ ។
- ជនក្រីក្រ និង ជនកំពុងខ្វះខាត ។ ម៉ាថាយ ៦:២

សុភាសិត ១៩:១៧ បានចែងថា អ្នកណាដែលមានចិត្តអាណិត ចែកដល់ពួកទាល់ក្រ នោះឈ្មោះថាថ្វាយឲ្យព្រះអម្ចាស់ខ្ចី ទ្រង់នឹងតបស្នងសងគុណអ្នកនោះវិញនៅពេលក្រោយ ។

***តើយើងគួរថ្វាយប៉ុន្មានទៅ?*** ដប់ភាគរយនៃប្រាក់ចំណូល (ដង្វាយ ១ ភាគ ១០) ដែលបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងគម្ពីរសញ្ញាចាស់ (ម៉ាឡាគី ៣:៨-១០) ។ រីឯនៅក្នុងគម្ពីរសញ្ញាថ្មី មិនបានផ្ដល់ពីតួលេខច្បាស់លាស់ទេ គោលការណ៍នៃការថ្វាយដង្វាយនេះមាននៅក្នុង ចោទិយកថា ១៤: ២២-២៩ គឺជាគោលការណ៍នៃចិត្តសប្បុរស ដែលបានចែងនៅក្នុងបទគម្ពីរខាងលើគឺ ២ កូរិនថូស ៩:៦ និង លូកា ៦:៣៨ ដែលបង្ហាញប្រាប់ឲ្យយើងត្រូវថ្វាយយ៉ាងតិច ១០ ភាគរយ និងច្រើនជាងនេះទៅទៀត តាមដែលព្រះជាម្ចាស់ផ្ដល់ឲ្យយើងនូវការចំរុងចំរើនផ្នែកថវិកានោះ ។

គំរូនៃការថ្វាយដង្វាយ នៅក្នុងព្រះគម្ពីរខាងក្រោមនេះ ជួយឲ្យយើងនូវការបង្ហាញផ្លូវដូចតទៅ៖

- ម៉ាឡាគី ៣:៨ បានបង្ហាញថាយើងអាច*កេងយករបស់ព្រះជាម្ចាស់ បើសិនជាយើងបានឲ្យនូវអ្វីជារបស់ផងព្រះជាម្ចាស់ទៅព្រះអង្គ* គឺមានន័យថា បើយើងមិនបានថ្វាយដង្វាយ ១ភាគ១០ (នៅក្នុងខ ១០) យើងនឹងបានទទួលព្រះពរដ៏ច្រើនមហិមា ។
- អាប្រាហាំបានថ្វាយ *១០% នៃអ្វីៗដែលគាត់មានជូនទៅពួកបូជាចារ្យ* នៅក្នុងលោកុប្បត្តិ ១៤:២០ ។
- រាស្ត្ររបស់ព្រះជាម្ចាស់ *ត្រូវផ្ដល់អ្វីដែលជាចំណែកនៃព្រះពររបស់ព្រះជាម្ចាស់ដែលបានប្រទានពរ* ដល់គេ (ចោទិយកថា ១៦:១៧) ។
- អ្នកក្រុងកូរិនថូស *គេបានឲ្យច្រើនហួសពីលទ្ធភាពរបស់គេទៅទៀត* នៅក្នុងកណ្ឌគម្ពីរ ២ កូរិនថូស ៨:៣ ។
- កូនាលាស *បានឲ្យដោយសទ្ធាដល់អ្នកដែលកំពុងខ្វះខាត* នៅក្នុងកណ្ឌគម្ពីរកិច្ចការ ១០:២ ។
- ស្ត្រីមេម៉ាយដ៏ក្រីក្រម្នាក់ *បានថ្វាយទាំងអស់នូវអ្វីដែលគាត់មានសំរាប់រស់នៅ* ក្នុងកណ្ឌគម្ពីរម៉ាកុស ១២:៤៤ ។

- ដាវីឌមានបំណងថ្វាយទៅព្រះជាម្ចាស់ *តែអ្វីដែលមានតម្លៃដល់ទ្រង់ផ្ទាល់តែប៉ុណ្ណោះ* នៅក្នុងគម្ពីរ ២៨:២៨ ។
- នៅក្នុងពួកជំនុំកាលពីជំនាន់ដើម *គ្រប់ទាំងរបស់ទាំងអស់គេយកមកដាក់រួម* ដោយចែកចាយគ្នាក្នុងចំណោមពួកអ្នកជឿ (កិច្ចការ ៤:៣២) ។

**តើយើងត្រូវថ្វាយដោយរបៀបណា?**

យើងត្រូវថ្វាយ . . . ទៅព្រះជាម្ចាស់ជាដំបូងនូវអ្វី ដែលជាពិសេសបំផុតពីទ្រព្យធន ដែលយើងរកបានមក ។ សុភាសិត ៣:៩ ។

យើងត្រូវថ្វាយ . . . ដោយចិត្តត្រេកអរ មិនមែនស្ទាក់ស្ទើរឡើយ ឬ នៅក្រោមការបង្ខិតបង្ខំឡើយ ។ កូរិនថូស ៩:៧ យើងត្រូវថ្វាយ . . . ដោយគ្រប់ទាំងការប្រឹងប្រែងដ៏ពិសេសបំផុតរបស់យើង ។ កូរិនថូស ៨:៧ ។

យើងត្រូវថ្វាយ . . . ដោយសម្ងាត់មិនចាំបាច់ឲ្យនរណាដឹងឡើយ មានតែព្រះជាម្ចាស់ទើបអាចជ្រាប និង ឃើញយើង ។ ម៉ាថាយ ៦:៣-៤ ។

យើងត្រូវថ្វាយ . . . គឺជាឯកសិទ្ធិ ដែលយើងបានថ្វាយដល់រាស្ត្ររបស់ព្រះជាម្ចាស់ ។ ២កូរិនថូស ៨:៤ ។

យើងត្រូវមាន . . . វិន័យនៃការលៃប្រាក់ទុកដោយឡែក រាល់អាទិត្យ នៃប្រាក់ចំណូលរបស់យើង ។ ១ កូរិនថូស ១៦:២ ។

ដូចដែលលោក ប៉ូល មានប្រសាសន៍ សូមឲ្យដង្វាយសប្បុរសរបស់យើងបង្ហាញឲ្យឃើញថាមាន “ក្លិនក្រអូប ដែលជាដង្វាយ ដែលព្រះជាម្ចាស់ព្រមទទួលយក និង គាប់ព្រះហឫទ័យដល់ព្រះជាម្ចាស់” ។ ដោយព្រោះតែយើងបានថ្វាយដល់ព្រះជាម្ចាស់ មានសេចក្តីសន្យាមួយឃ្លាចែងថា “ព្រះជាម្ចាស់នឹងបំពេញគ្រប់ទាំងអស់ ដែលអ្នករាល់គ្នាត្រូវការ តាមភោគសម្បត្តិនៃទ្រង់ដ៏ឧត្តម ក្នុងព្រះគ្រីស្ទយេស៊ូ” ភីលីព ៤:១៨-១៩) ។

HONEYCOMB 1/2 (October 2000): 68–79

# "Faith" in the Book of Ruth

Russell H. BOWERS, Jr.

## Background

The refreshing story of Ruth takes place "in the days when the judges ruled" (Ruth 1:1). This was in general a morally and religiously abysmal era, when "Israel had no king" and "everyone did as he saw fit" (Jud 21:25; cp 17:6; 18:1; 19:1). With no central government to encourage stability, Israel cyclically invoked God's help against her enemies but quickly fell away once it was received (Jud 2:10–19; 10:6–16). The nation's neighbors exploited her weakness by invading and oppressing her citizens.

Against such a background, Ruth's protagonists demonstrate that even in the darkest times people may be found who love God and live righteously. On the one hand, Micah's idolatry and opportunism (Jud 17), Dan's rapacity (Jud 18), Gibeah's debauchery, Benjamin's preference for tribe over justice, and Israel's rash vows and antidotes (Jud 19–21), depict the general tenor of the times. By contrast, the decisive faith of Ruth and the generous character of Boaz blaze as novae in the midnight sky. Further, we see God's grace in mellowing the embittered Naomi and in keeping his word to provide a ruler (and later messiah) through Judah.

The Talmud teaches that Samuel wrote the book of Ruth, though not all modern scholars concur. It falls in the third part of the Hebrew canon, the *kethubim* or "writings" (parts one and two

being the *torah* or "law" and the *nebi'im* or "prophets."[1] In the Talmud Ruth was the first book in the *kethubim*, but was later transferred to the *megilloth*, a collection of five rolls within the *kethubim*. Each of the *megilloth* is read during one of the Jewish feasts; Ruth, the second, is read during the Feast of Weeks or Pentecost at the end of the grain harvest.[2] Later, the Septuagint or Greek translation of the Old Testament, followed by the Latin Vulgate and subsequent Western translations, placed Ruth after Judges because of their close relation in time.




[1]See Luke 24:44 where Jesus spoke about "the Law (*torah*) of Moses, the Prophets (*nebi'im*), and the Psalms (which is often the first and certainly the longest book of the *kethubim*)."

[2]The other books of the *megilloth* are Song of Songs (which is read at Passover), Lamentations (read on the ninth of Ab), Ecclesiastes (read during the Feast of Booths), and Esther (read during Purim).

## A Homiletic Approach

This article will not attempt to exegete the book, but rather suggest one homiletic approach and then propose further themes for study. It is possible to trace the development of Ruth's *faith* through the book as follows: the *decision* of faith (1), the *work* of faith (2), the *request* of faith (3), and the *reward* of faith (4).

**The Decision of Faith (chapter one)**

Chapter one begins with Elimelech and his family moving to Moab to escape a famine. The text does not state whether he inquired of God before leaving Judah, or instead made this decision on his own. However this may be, his actions recall those of Abraham, who earlier had left the land of promise for Egypt because of famine with no recorded authorization by God, and demonstrated a lack of faith while there (Gen 12:10–20). It is possible (but not certain) that Elimelech's lack of faith in God to provide in Judah stands by design in the story in contrast with Ruth's decision to abandon Moab for Judah, and its gods for Yahweh. At any rate Elimelech, whose name means "my God is king," leaves Bethlehem, the "house of bread," because of a famine. His purpose was to "sojourn" or "live for a while" (גור) there. But then as now such "temporary" departures often have a way of becoming more permanent than intended. Elimelech himself died, his sons married, and after ten years they too perished. The "sojourn" out of the land of promise had taken on the appearance of a settled change of address.

In time the widowed[3] Naomi hears that Yahweh has "come to the aid of" his people and lifted the famine. So she and her two daughters-in-law start out for Judah. Before they have gone far Naomi counsels them to return home, praying that they find "rest" in the home of another Moabite husband since they could not wait

---

[3]The repeated note that Naomi "was left with her two sons (v. 3)" and that she "was left without her two sons and her husband (v. 5)" underscores her loss and desolation.

for sons from her even if (as seemed unlikely) she were to bear them. Naomi (נָעֳמִי), a name which means "pleasant," laments that her life has become "bitter," and adopts that name (מָרָא, "Mara") for herself (1:20). Not only has the "pleasant" woman become "bitter," but the "full" is now "empty" (1:21). The fullness the family had hoped to gain by leaving Judah had not materialized. Her life has become bitter and empty because in her view Yahweh's hand had gone out against her. God never rebukes her for that assessment, but by the story's end has so worked that she has a "son" (4:17) who will "renew [her] life and sustain [her] in [her] old age" (4:15). Thus the bitter one will once again enjoy pleasantness; the empty will again be full. But, not imagining that such a happy outcome could await her, Naomi urges her daughters-in-law to return to Moab to seek "rest" while she goes home to Judah to pursue her lot alone.

At first both assure Naomi they would go with her. But after Naomi outlines her own plight and their prospects, Orpah returns to Moab. By contrast, in her classic reply Ruth binds herself to her mother-in-law. She commits herself firmly to share her lot. As part of that commitment, Ruth declares that Naomi's God will be her God (1:16) and takes an oath in Yahweh's name (1:17), so that Boaz later correctly observes that the Moabitess has come to take refuge under the wings of Yahweh, the God of Israel (2:12). This is Ruth's *decision of faith.*

This decision is worth examining. First, it was made in the face of the negative prospects it entailed. Humanly speaking her future looked better if she were to follow Orpah back to Moab—a husband, a home, and "rest" more likely awaited her there. A biblical decision of faith often means abandoning what appear to be good earthly prospects for seemingly poorer ones.[4] Second, the

---

[4]This motif runs throughout the scriptures. Notable examples include Abraham's willingness to take the arid regions of Canaan in contrast with Lot's choice (Gen 13), and Jesus' instruction that the one who seeks to save his life will lose it, while the one who loses his life for the sake of Jesus and the gospel will find it (Matt 16:25–26 and parallels).

decision was made firmly. One reason God honored her faith, and her story is told today, is that the choice she made was clear and decisive. Throughout the scriptures, that is the kind of faith God wants.[5] Third, Ruth's decision determined her destiny. Orpah chose one way, apparently based on her human vision and analysis—what may be called "walking by sight, not by faith" (in contrast with 2 Cor 5:7)—and we hear no more of her. Ruth made a contrary choice, and all the good that she soon came to enjoy followed as a consequence. Despite the bleak prospects, Ruth chose decisively to accompany Naomi and trust Yahweh, and that decision set in motion the events which produced all the good she soon enjoyed.

**The Work of Faith (chapter two)**

But does faith stop with a decision, or even a verbalization of that decision? Does a decision to trust God mean that the new believer sits and waits for God to act on his or her behalf? Do we "claim" a blessing and wait for God to supernaturally bestow it upon us? Is faith divorced from works?

Not so with Ruth. She acted on her word, accompanying Naomi to Bethlehem in Judah as the barley harvest was beginning (1:22). Barley, often considered inferior to wheat,[6] was harvested in April–May; wheat followed a few weeks later. Rather than wait for her and her mother-in-law's needs to be miraculously supplied, Ruth proposes that she glean in the barley fields. As standing grain was cut and bound into sheaves, some would inevitably be missed or dropped. The Mosaic Law prescribed that these should be left

---

[5]See, for example, Joshua's challenge to decisively choose which god they would follow (Josh 24:14–15), Elijah's call for decision in the question of Yahweh vs. Baal (1 Ki 18:21), and the glorified Lord's revulsion against lukewarmness (Rev 3:15–16).

[6]For example, wheat was twice as expensive as barley in 2 Ki 7:1; three times as expensive in Rev 6:6. The comparison of Gideon and Israel to "a round loaf of barley bread" in Jud 7:13 aptly symbolizes their inferiority to Midian.

"for the poor and the alien."[7] This good law simultaneously provided for the poor and encouraged their dignity by allowing them to *work* for their food rather than simply *beg* for it. Thus the twin evils of tight-fistedness on the part of the wealthy and a sense of entitlement to unearned welfare on the part of the poor were avoided. Gleaning was hard work, it was humble work, it did not generally yield an abundant return, but it did provide something. Ruth was humble and committed enough to be willing to undertake the task of seeking permission (2:2, 7), of gleaning, and of gleaning *barley*. In doing so she displayed not a *lack* of faith that her new God would provide, but rather a *living* faith[8] which was willing to pursue the means that this God had already ordained to supply her needs. Not only does she work, but she works long and hard.[9]

Unbeknown to Ruth, she happened to choose a field belonging to Boaz, a respected relative of Elimelech (2:1, 3, 20). The greetings exchanged between him and his harvesters (2:4) suggest his godly, kindly character. Even in the dark days of the judges God has those who fear and honor him. He will later be seen to be a generous (2:14–16; 3:15), honest (3:18), prudent and hardworking man (4:1–10). He notices and inquires about Ruth, and provides generously for her once he learns who she is. He does this because he has been told about her *work of faith*—how she has *taken refuge* under Yahweh's wings and *worked hard* for her mother-in-law (2:11–12). He prays that God would bless her (2:12)—little knowing that he will be the means through whom that blessing will come. He urges Ruth for her safety to stay with his fields and workers (2:8–9)—a matter with which Naomi

---

[7]Lev 19:9–10; 23:22; Deut 24:19–22. Boaz went beyond what the Law required (2:15–16; 3:15). The result was that Ruth came home with an extraordinarily large quantity for a gleaner—about 22 liters (2:17). Thus in one day's work she gathered enough food to feed the two women for three weeks or so. This surprising amount prompted Naomi's question of Ruth and blessing on the as yet unknown landowner (2:18–19).

[8]See James 2:14–26.

[9]2:7, 17–18, 23. The two harvest seasons mentioned in 2:23 would have lasted about seven weeks.

concurs (2:22)—again suggesting the general darkness of the times.

**The Request of Faith (chapter three)**

Faith may be strong to make a decision which apparently contravenes common sense and then to act decisively on that decision. But biblical faith is not content with what it alone can achieve. It acknowledges its need, and asks God to do what it cannot.

Earlier Naomi had prayed that Yahweh would grant her daughters-in-law "rest" (מְנוּחָה) in the home of another husband (1:9). It had seemed highly unlikely to her that Ruth—a foreigner[10]—would ever be so blessed in Judah. But now, with her own needs being met and hopes renewed, Naomi turns her thoughts away from her bitter bereavement to her daughter-in-law, and suggests that she will now try to find "rest" (מָנוֹחַ, translated in the NIV as "a home")[11] for her (3:1). The one through whom she will seek it is Boaz, who has already shown himself to be kindly disposed toward Ruth.

The Torah provided that if brothers were living together and one died without a son, the surviving brother should marry the widow. The first child born to that union would bear the deceased's name (Deut 25:5–10). It was this practice which lay behind the Sadducees' question of Jesus in Matt 22:23–33 and parallels. By outlining the plan of 3:3–4, Naomi is urging Ruth to tacitly ask Boaz to perform this responsibility of levirate marriage. Spreading the corner of one's garment over another (3:9) is a request for marriage, as Ezek 16:8 suggests.

---

[10]Repeated references to Ruth as "the Moabitess" throughout the book (1:22; 2:2, 6, 21; 4:5, 10) emphasize her foreignness.

[11]The root of both מְנוּחָה and מָנוֹחַ is נוּחַ, which "signifies not only absence of movement but being settled in a particular place (whether concrete or abstract) with overtones of finality, or (when speaking abstractly) of victory, salvation, etc." מָנוֹחַ "denotes a place of *nûaḥ* (motionless, security) for animals or people, i.e. a place to settle down, a home" [*TWOT*, s.v. נוּחַ]. The word here thus implies security, not leisure.

This may strike the reader as rather forward, but faith is willing to humble oneself and ask for big things. The persistence of the Syrophoenician woman (Matt 15:21–28; Mark 7:24–30) further illustrates that truth. Here Ruth, who through her *work of faith* has been supplying the needs of both herself and Naomi, makes a bold, tacit *request of faith* that more be done for her.

A "threshing floor" was an elevated level place of smooth rock or pounded earth, usually east or downwind from the city. Workers tossed the threshed grain into the breeze that usually rose in the afternoon from the Mediterranean. The chaff would blow away, but the heavier grain fall to the ground to be gathered. Here the unpretentious Boaz would spend the night, whether to guard his harvest or in celebration of it. Although some interpreters see lewdness in Ruth's action of "uncovering Boaz' feet," both Boaz' statement in 3:11 that Ruth is known as a woman of character, as well as the whole tenor of the story, argue against that assessment. She is simply—but admittedly quite clearly—asking that Boaz perform his obligation as kinsman-redeemer (גֹּאֵל). Her bathing, perfuming, and dressing (3:3), of course, were not designed to discourage his response to her.

Whether or not Ruth knew it, Elimelech had a relative closer than Boaz who retained the first right to buy his estate and take Ruth as his wife. Boaz, startled in the middle of the night as he sleeps on the threshing floor, awakes to find—of all things!—a woman at his feet. Learning her identity and hearing her request, Boaz proposes to Ruth that in the morning he will inform this relative of his option to redeem and then, if this closer kinsman declines, promises to do it himself. He then has Ruth lie down until morning, and before she leaves gives her six measures of barley.

Naomi naturally is eager to hear how things went. When she hears Ruth's story and sees the grain Boaz has sent, she urges Ruth to *wait* to see the outcome, assured that Boaz would act on his promise that very day.

And so the *request of faith* becomes the *rest of faith.* Faith takes courage to *ask* for big things—even that mountains be

removed (Matt 21:21–22)—and then *rests* in faith that God will act. One is reminded of Jehoshaphat, who *interceded* with God against the coalition marching against him, and who was told to *rest and wait* for God's deliverance (2 Chron 20). Hannah pled for a son and then, resting in faith for God's answer, "went away and ate something, and her face was no longer downcast" (1 Sam 1:18). These and others made *requests of faith* to God—not for extravagant items for self-indulgence, but for basic needs in line with his covenant—and then *rested* in anticipation of the answer. Again it is helpful to remember that Ruth's request followed both her *decision of faith* and her *work of faith*, and did not comprise a lazy or escapist approach to life's needs and responsibilities. Her request was made for what God had already promised in the Law but which was beyond her ability in herself to make happen.

**The Reward of Faith (chapter four)**

Chapter four finds Boaz hard at work fulfilling his promise. He will do everything with energy, propriety, and thoroughness.

The "town gate" (4:1) was a public center where business was often transacted and judgments rendered.[12] Boaz went to the gate and, when the closer relative approached, had him turn aside to this "courtroom." He then invited a full quorum of ten elders to witness his discussion. Upon hearing Boaz' word that Elimelech's property is for sale, the kinsman expresses interest in acquiring it. But when he learns that that entails marrying Ruth and raising an heir for Elimelech, he demurs. Then follows a description of a practice which had become archaic and required explanation by the time the book was written—that of giving a sandal to legalize a transaction (4:7–8). Boaz then states his intentions to redeem the property and marry Ruth as clearly and firmly as did Ruth to

---

[12]See, e.g., Gen 23:10, 18; 34:20, 24; Deut 17:5; 21:19; 22:15, 24; 25:7; and throughout the O.T.

abandon Moab and follow Naomi (4:9–10, cp. 1:16–17).[13] The ten elders affirm that they have witnessed the transaction, implying that all is in order. They invoke Yahweh's blessing on this proposed marriage, praying that God would bless it with children. In time Yahweh answered their prayer. He enabled Ruth to conceive (4:13) and bear a son.

And now Naomi's fortunes have turned full cycle. She left Judah full, returned empty (1:21), and now has been filled again. The woman named "Pleasant" who assumed the title "Bitter" now has the "pleasant" prospect of a גֹּאֵל who will renew her life and sustain her in her old age (4:15).[14] She takes the child in her lap and cares for him (4:16). All this because the blessing of Yahweh has come to her through her return to the land of promise, and the ministry of her faithful daughter-in-law who was better to her than seven sons (4:15).[15]

The genealogy that follows demonstrates just how significant and far-reaching Ruth's *decision, work,* and *request* of faith proved to be. Perez, with whom the genealogy starts (4:18), was a son of Judah,[16] to whom rulership was promised by Jacob.[17] Sure enough, Obed—the child born to Boaz and Ruth—becomes the father of Jesse, who himself was the father of David—king of Israel and human ancestor of Jesus the Messiah.[18] Who ever knows

---

[13]Just as Boaz' selfless, faithful character parallels that of Ruth, so the unwilling kinsman-redeemer's more self-centered and "pragmatic" character parallels that of Orpah.

[14]Previously in the book Boaz had been considered the גֹּאֵל. But now in 4:14–15 that title is applied to the child born to Boaz and Ruth as well. Obed (עוֹבֵד) will serve (עָבַד) to "redeem" Naomi from emptiness, insignificance, and insecurity.

[15]This is very high praise in a day when sons often seemed to be valued more than daughters.

[16]Gen 38 tells the story of Perez' conception and birth. Cp. Gen 46:12.

[17]Gen 49:10.

[18]Having Ruth the Moabitess in his ancestry may help explain why, though Moab was included among Israel's enemies (1 Sam 12:9;

how significant will be one person's *decision, work,* and *request* of faith? Who ever can tell how great the *reward of faith* for any one person will be? Not only was Ruth blessed with "rest" in the home of a husband and child, but she enjoyed the respect of those who knew her (3:11; 4:15), and became an ancestor of the messiah. All this for a foreigner who put faith in the God of Israel and acted on that faith.[19]

## Other Considerations

As stated at the beginning, this article does not attempt to exegete the book of Ruth, but simply to suggest one line of thought—the character and development of Ruth's faith—that runs throughout it. Other themes which may be profitably pursued include:

- a character study of Naomi who, though living in a foreign land for a decade or more and at the end of that time berating the lot assigned to her by Yahweh, nevertheless was so compelling a personality that Ruth would abandon her home, her prospects, and her gods to follow her to Judah.
- reflections on the sovereignty of God, who works behind the scenes so that Ruth "happens" to choose Boaz' field in which to glean, causes Boaz to awaken at this right time, ensures that the close relative passes the gate the next

---

14:47), David took his parents to the king of Moab for safekeeping during the time he fled from Saul (1 Sam 22:3–4).

[19]The genealogy of Jesus in Matt 1 lists four women, none of whom would ordinarily be expected to have been granted such an honor. Tamar had been Judah's daughter-in-law, and his liaison with her was immoral (Gen 38). Rahab was a foreigner from the doomed city of Jericho, and by many translations a prostitute. Ruth was a foreigner and a Moabitess—a fact reiterated throughout the book (see footnote 10). Deut 23:3 states that ordinarily no Moabite could enter the assembly of Yahweh even down to the tenth generation. Finally, Bathsheba or "Uriah's wife" should not have been David's spouse. God's dealings with Israel—and with humanity as a whole—are a matter of grace.

morning, enables Ruth to bear a son, etc. Similarities may be drawn to the book of Esther, where God's name is not mentioned but his work in the events of the story is very clear.

- a study of "harsh" prayers to or statements against Yahweh in the Bible on the part of his believers, including Naomi, Job, Asaph, Jeremiah, etc.
- a study of the גֹּאֵל or kinsman redeemer, who 1) must be a close relative, 2) must be able to redeem, and 3) must be willing to redeem. Parallels can be drawn to Jesus, the great antitype of the Old Testament גֹּאֵל, who 1) took on humanity that he might be our "close relative" (Heb 2:14–18; 4:14–16), 2) is able to redeem (Heb 7:25), and 3) was willing to redeem (John 10:17–18; Luke 22:41–42). The word גָּאַל, of which גֹּאֵל is a participle, occurs 23 times in Ruth.[20]
- the contribution of the book of Ruth to the concept of covenant-loyalty or loyal-love (חֶסֶד, 1:8; 2:20; 3:10).
- the role that Ruth's submission to her mother-in-law and willingness to obey her played in the good that came to her.

May God grant that as we study the faith and character of Ruth all of us—men and women—would appropriately follow in her steps.

[20]2:20; 3:9; 3:12 (2 times), 13 (4 times); 4:1, 3, 4 (5 times), 6 (5 times), 7, 8, 14.

សំណាំឱកឃ្មុំ ១/២ (តុលា ២០០០) ៨០-៩៦

# “ជំនឿ” នៅក្នុងកណ្ឌគម្ពីរនាងរស់

ដោយ លោក រ៉ស់ បាតទើស៍

✱✱✱✱✱✱✱✱✱✱✱✱✱✱

## ប្រវត្តិដើម

រឿងនាងរស់នេះកើតឡើងស្រស់ៗនៅក្នុង “សម័យដែលពួកចៅហ្វាយគ្រប់គ្រង” (នាងរស់ ១:១) ។ រឿងនេះរៀបរាប់ជាទូទៅពីភាពអាក្រក់ជួរជាតិផ្នែកសីលធម៌ និងផ្នែកសាសនាក្នុងសម័យកាលមួយដែល “ប្រទេសអ៊ីស្រាអែលគ្មានស្តេចគ្រប់គ្រង” ហើយនិង មនុស្សគ្រប់រូបធ្វើអ្វីៗតាមតែក្បាលចិត្តរបស់ខ្លួន” (ចៅហ្វាយ ២១:២៥ ជំពូក ១៧:៦; ១៨:១; ១៩:១) ។ ដោយគ្មានរដ្ឋាភិបាលគ្រប់គ្រងដើម្បីជំរុញឲ្យមានស្ថេរភាព អ៊ីស្រាអែលបានអធិស្ឋានសុំជំនួយពីព្រះជាម្ចាស់ ដើម្បីប្រឆាំងតបតជាមួយនឹងខ្មាំងសត្រូវរបស់ខ្លួនម្តងហើយម្តងទៀតកាលពីសម័យនោះ (ចៅហ្វាយ ២:១០-១៩; ១០:៦-១៦) ។ ប្រទេសជាតិដែលនៅជិតខាង ដោយឃើញថាអ៊ីស្រាអែលខ្សោយដូច្នេះហើយ ទើបគេចូលលុកលុយទន្ទ្រានទី គាបសង្កត់ដល់ប្រជារាស្ត្រអ៊ីស្រាអែល ។

ផ្អែកលើប្រវត្តិដើមនៃរឿងនេះ នាងរស់ជាតួអង្គសំខាន់ ដែលបង្ហាញយ៉ាងច្បាស់ពីជំនឿរបស់ខ្លួន ទោះបីជាស្ថិតនៅក្នុងសម័យដ៏ខ្មៅងងឹតយ៉ាងណាក៏ដោយ ក៏នាងនៅតែស្រឡាញ់ព្រះជាម្ចាស់ និង រស់នៅដោយសុចរិតបំផុត ។ ផ្ទុយទៅវិញលោក មីកា ជាអ្នកថ្វាយបង្គំរូបសំណាក និងជាអ្នកឱកាសនិយម (ឆ្អិនក្បាលស៊ីក្បាលឆ្អិនកន្ទុយស៊ីកន្ទុយ) (ចៅហ្វាយ ១៧) ការវាយឆក់ប្លន់របស់ពួកអំបូរដាន់ (ចៅហ្វាយ ១៨) អំពើអបាយមុខរបស់ពួកគីបៀរ ពួកបេនយ៉ាមីន គិតពីអំបូររបស់ខ្លួន ដោយមិនខ្វល់ពីសេចក្តីយុត្តិធម៌ឡើយ ហើយនិងការឆាប់នឹងបែរ

រកព្រះ និង ឆាប់នឹងភ្លេចព្រះ របស់រាស្ត្រអ៊ីស្រាអែល (ចៅហ្វាយ ១៩-២១) បង្ហាញឆ្លុះបញ្ចាំងពីសភាពការណ៍ជាទូទៅនៃសម័យកាលនោះ ។ តែផ្ទុយទៅវិញ ជំនឿដ៏មុតមាំរបស់ នាងរស់ និង ទឹកចិត្តដ៏សប្បុរសរបស់បូអូស បានចាំងជះពន្លឺចាំងចែង នៅក្នុងលំហអាកាសដ៏ងងឹតនាពេលពាក់កណ្តាលអាធ្រាត ។ លើសពីនោះទៅទៀត យើងបានឃើញព្រះគុណរបស់ព្រះជាម្ចាស់ ដោយបង្វិលដួងចិត្តដ៏ជូរចត់របស់នាង ណាអូមី ឲ្យទៅជាដួងចិត្តផ្អែមឆ្ងាញ់ ហើយរក្សាព្រះបន្ទូលសន្យារបស់ព្រះអង្គ ដែលសន្យាថានឹងផ្តល់ឲ្យមានអ្នកដឹកនាំម្នាក់ (និងក្រោយមកជាព្រះមេស្ស៊ី) តាមរយៈអំបូរ យូដា ។




ក្រុមអ្នកគ្រប់គ្រងច្បាប់របស់យូដាបានប្រាប់ឲ្យដឹងថា សាំយូអែល ជាអ្នកសរសេរកណ្ឌគម្ពីរនាងរស់ ទោះបីជាពួកអ្នកប្រាជ្ញនៅពេលសម័យបច្ចុប្បន្នមិនយល់ព្រមទាំងអស់ក៏ដោយ ។ រឿងនេះចែកចេញជាបីផ្នែក តាមសំណេររបស់

ហេព្រើ (ផ្នែកទីមួយ និងផ្នែកទី២ គឺជា "កណ្ឌច្បាប់" និង ជា "កណ្ឌព្យាការី"[១] ។ នៅក្នុងផ្ទៃ រឿងរបស់កណ្ឌនាងរស់ គឺជាសៀវភៅទីមួយ នៅក្នុងសំណេររបស់សាសន៍ហេព្រើ ប៉ុន្តែក្រោយមក ក៏ត្រូវបានគេផ្ទេរមក ជាការប្រមូលផ្តុំជាប្រាំផ្នែកនៃសំណេររបស់ហេព្រើនោះ ។ សំណេរនិមួយៗនៃសំណេរទាំងប្រាំនោះគឺយកមកអាននៅក្នុងពិធីបុណ្យនៃពួកយូដាកណ្ឌនាងរស់ជាកណ្ឌទី២ ដែលយកមកអាននៅក្នុងពិធីបុណ្យប្រចាំសប្តាហ៍ ឬ ពិធីបុណ្យថ្ងៃទី៥០ នៅខាងចុងនៃរដូវច្រូតកាត់ប្រមូលភោគផល ។ [២] ក្រោយមក ការបកប្រែព្រះគម្ពីរសញ្ញាចាស់ ត្រូវធ្វើតាមការបកប្រែជាភាសាឡាតាំង និងបន្តបន្ទាប់មកក្នុងការបកប្រែរបស់ពួកបស្ចឹមប្រទេស គេបានដាក់គម្ពីរនាងរស់នៅបន្ទាប់ពីកណ្ឌគម្ពីរពួកចៅហ្វាយ ពីព្រោះតែកណ្ឌគម្ពីរមានការទាក់ទងគ្នាយ៉ាងជិតស្និតនៅក្នុងពេលនោះ ។

## របៀបអធិប្បាយ

អត្ថបទនេះនឹងមិនប៉ុនប៉ងពន្យល់ឲ្យស៊ីជម្រៅនូវកណ្ឌគម្ពីរនេះឡើយ ប៉ុន្តែគ្រាន់តែផ្តល់ការណែនាំពីរបៀបអធិប្បាយ និង បន្ទាប់មកផ្តល់នូវផ្ទៃរឿងសំខាន់សំរាប់សិក្សា ។ យើងអាចស្រាវជ្រាវស្តីពីការចំរើនលូតលាស់នៃជំនឿរបស់នាងរស់ នៅក្នុងជំពូកដូចតទៅ៖ ការសម្រេចចិត្តដោយជំនឿ (ជំពូក ១) , កិច្ចការនៃជំនឿ (២) ការស្នើសុំដោយជំនឿ (៣) ហើយនិងរង្វាន់នៃជំនឿ (៤) ។

**ការសម្រេចចិត្តដោយជំនឿ (ជំពូក ១)**

ជំពូក ១ ចាប់ផ្តើមរៀបរាប់ពីការរត់គេចពីគ្រោះអត់ឃ្លានរបស់លោកអេលីម៉ាឡេក ព្រមទាំងគ្រួសាររបស់គាត់ ទៅកាន់ស្រុកម៉ូអាប់ ។ អត្ថបទនេះមិនបាន

---

*[១] សូមមើល លូកា ២៤:៤៤ នៅត្រង់កន្លែងដែលព្រះយេស៊ូនិយាយពី "ក្រិត្យវិន័យ របស់លោកម៉ូសេ (ភាសាហេព្រើហៅថា តូរ៉ា) កណ្ឌគម្ពីរពួកហោរា និង កណ្ឌទំនុកតម្កើង (ដែលជាញយៗជាកណ្ឌគម្ពីរ ទីមួយ និង តាមពិតទៅជាកណ្ឌគម្ពីរដែលវែងជាងបំផុតនៃសំណេររបស់ពួកហេព្រើ)*

*[២] កណ្ឌគម្ពីរនៃសំណេរទាំងប្រាំនោះ គឺជាបទចំរៀង (ដែលគេយកទៅអាននៅថ្ងៃបុណ្យរំលង) បរិទេវ (អាននៅថ្ងៃទី៩ នៃខែ Ab) សាស្តា (អាននៅពិធីបុណ្យ Booths) និង អេសធើ (អាននៅក្នុង ពិធីបុណ្យ Purim) ។*

បញ្ជាក់ប្រាប់ថាតើគាត់បានទូលសួរព្រះជាម្ចាស់ឬក៏អត់ទេ មុនពេលដែលគាត់ចាកចេញពីស្រុកយូដា ឬក៏ប្រហែលជាគាត់ធ្វើការសម្រេចចិត្តដោយខ្លួនឯង ។ ទោះជាយ៉ាងណាក៏ដោយ ការនេះប្រហែលជាគាត់ធ្វើដូចជាអាប្រាហាំ ដែលបានចាកចេញពីទឹកដីសន្យាជាលើកដំបូង ធ្វើដំណើរទៅកាន់ប្រទេសអេស៊ីព្ទ ដោយសារតែគ្រោះអត់ឃ្លាន ដោយគ្មានកំណត់ហេតុណាមួយបង្ហាញពីការយល់ព្រមពីព្រះជាម្ចាស់នោះឡើយ ហើយនិង បង្ហាញឲ្យឃើញថាគាត់ខ្វះជំនឿលើព្រះជាម្ចាស់ នៅពេលដែលគាត់កំពុងស្នាក់នៅក្នុងស្រុកនោះ (លោកុប្បត្តិ ១២:១០-២០) ប្រហែលជាអាច (ប៉ុន្តែមិនច្បាស់) មានន័យថា អេលីម៉ាឡេកខ្វះជំនឿនៅក្នុងព្រះជាម្ចាស់ ក្នុងការដែល ព្រះអង្គផ្គត់ផ្គង់អាហារឲ្យនៅក្នុងស្រុកយូដា តែផ្ទុយទៅវិញក្នុងសាច់រឿងនេះ នាងរស់នៅតែស្មោះត្រង់ សម្រេចចិត្តចាកចេញពីស្រុកម៉ូអាប់មកកាន់ស្រុកយូដាវិញ ហើយនិង បែរចេញពីព្រះរបស់ខ្លួនមកជឿលើព្រះយេហូវ៉ា(ព្រះយ៉ាវេ) ។ ទោះបីជាយ៉ាងណាក៏ដោយ អេលីម៉ាឡេក ដែលឈ្មោះនោះមានន័យថា "ព្រះជាម្ចាស់របស់ខ្ញុំជាស្តេច" ចាកចេញពីបេថ្លេហឹម ដែលមានន័យ "ដំណាក់នៃនំបុ័ង" ដោយសារតែគ្រោះអត់ឃ្លាន ។ គោលបំណងរបស់គាត់ គឺគ្រាន់តែ "ស្នាក់នៅ" ឬ "រស់នៅមួយរយៈ" នៅទីនោះ ។ ប៉ុន្តែបន្ទាប់មកគឺថាឥឡូវនេះការដែលថាចាកចេញទៅ"បណ្តោះអាសន្ន"នោះ តាមពិតទៅប្រែក្លាយទៅជាស្នាក់នៅរហូតទៅវិញ ។ អេលីម៉ាឡេកខ្លួនឯងផ្ទាល់គាត់ក៏ត្រូវស្លាប់ កូនប្រុសរបស់គាត់ទាំងពីរដែលរៀបការរួចបាន១០ឆ្នាំក៏ស្លាប់ដែរ ។ ការ"ស្នាក់នៅមួយរយៈ ក្រៅពីទឹកដីសន្យា គឺបង្ហាញឲ្យឃើញថា បានផ្លាស់ប្តូរអស្ស័យដ្ឋាននៃការតាំងទីលំនៅ ។

នៅក្នុងកំឡុងពេលនៃស្ថានភាពជាស្រីមេម៉ាយ[៣] ណាអូមីឮថាព្រះយ៉ាវេយាងមកដើម្បីជួយរាស្ត្ររបស់ព្រះអង្គឲ្យរួចពីគ្រោះទុរភិក្ស ។ ដូច្នេះគាត់ និង កូនប្រសារស្រីរបស់គាត់ចាប់ផ្តើមធ្វើដំណើរត្រឡប់ទៅស្រុកយូដា ។ មុនពេលដែល

---

[៣] *កំណត់សំគាល់លើកឡើងម្តងហើយម្តងទៀតពី ណាអូមី "នាងត្រូវប្តីស្លាប់ចោល នៅជាមួយកូនប្រុសពីរនាក់ (ខ ៣) ហើយបន្ទាប់មក នាងត្រូវ "ប្តី និង កូនប្រុសទាំងពីរស្លាប់ចោលទៀត (ខ ៥)" បញ្ជាក់សំខាន់លើការដែលគាត់មានការបាត់បង់ និង ការកំសត់ទុរគត៌របស់គាត់ ។*

ពួកគេធ្វើដំណើរមិនទាន់ឆ្ងាយប៉ុន្មាន ណាអូមីបានផ្ដល់ការប្រឹក្សាដល់កូនប្រសារស្រីទាំងពីរនាក់ ឲ្យគេត្រឡប់ទៅផ្ទះវិញ ដោយអធិស្ឋានសុំឲ្យគេបាន "សំរាក" នៅក្នុងស្រុកដោយរៀបការប្ដីថ្មីទៀត ដែលជាជនជាតិម៉ូអាប់ដូចគ្នា ដោយហេតុថាពួកគេមិនអាចរង់ចាំរៀបការជាមួយកូនប្រុសរបស់គាត់ (វាហាក់ដូចជាមិនអាចទៅរួចឡើយ ថាគាត់នឹងអាចបង្កើតកូនប្រុស សំរាប់ឲ្យកូនប្រសាររបស់គាត់ធ្វើជាប្ដីទៀត) ។ ឈ្មោះណាអូមី មានន័យថា "រីករាយ" ដោយសារតែសេចក្ដីទុក្ខសោកដែលជីវិតរបស់គាត់មាននោះ ក្លាយទៅជា "ជូរចត់" ហើយគាត់បានដូរឈ្មោះ ទៅជា (ម៉ារ៉ា) វិញ (១:២០) ។ មិនគ្រាន់តែក្លាយពីស្ត្រី "រីករាយ" ទៅជា "ជូរចត់" ប៉ុណ្ណោះទេ តែថែមទាំងក្លាយពី "ពេញ" ទៅជា "ទទេ" ទៅវិញ (១:២១) ។ ភាពពេញលេញរបស់គ្រួសារ ដែលសង្ឃឹមថានឹងបានទទួលដោយការចាកចេញពីស្រុកយូដានោះមិនចេញជារូបរាងឡើយ។ ជីវិតរបស់គាត់(ណាអូមី)បានក្លាយទៅជាជូរល្វីង និងបាត់បង់គ្មានសល់ ពីព្រោះតាមគំនិតរបស់គាត់បានគិតថា ព្រះយ៉ាវេ (យេហូវ៉ា)បានលូកព្រះហស្តមកទាស់នឹងគាត់ ។ ព្រះជាម្ចាស់មិនបន្ទោសដល់ គាត់ចំពោះការប៉ាន់ស្មានរបស់គាត់ឡើយ ។ ប៉ុន្តែចុងបញ្ចប់របស់សាច់រឿងពិតជាបានសម្រេចមែន ដែលថាគាត់ពិតជាអាចមាន "កូនប្រុស" មួយមែន (៤:១៧) ដែលនឹងផ្ដល់នូវ "ការកែប្រែ ជាថ្មីដល់ជីវិតគាត់ និង ជួយផ្ដល់ការគាំទ្រដល់ជីវិតរបស់គាត់ នៅក្នុងកាលដែលគាត់ចាស់ហើយនោះ (៤: ១៥) ហេតុដូច្នេះ អ្នកដែលធ្លាប់ឈឺចុកចាប់នោះ បានក្លាយទៅជាមានអំណររីករាយឡើងវិញ អ្នកដែលគ្មានអ្វីសោះ នឹងទៅជាមានពេញពោរឡើងវិញ ។ ប៉ុន្តែ ដោយគាត់មិនដែលគិតស្រមើស្រមៃថា នឹងមានការសប្បាយរីករាយបែបហ្នឹងអាចកើតមានឡើងសោះ ទើបណាអូមីជំរុញ ឲ្យកូនប្រសារស្រីរបស់ គាត់ឲ្យវិលត្រឡប់ទៅម៉ូអាប់វិញ ដើម្បីទៅរកការ "សំរាក" នៅខណៈដែលគាត់ វិលត្រឡប់ទៅស្រុកកំណើត នៅឯយូដាវិញ ដើម្បីទៅរស់នៅកំសត់ម្នាក់ឯង ។

មុនដំបូងកូនប្រសារទាំងពីរនាក់ធានាអះអាងជាមួយ ណាអូមី ថា ពួកគេនឹងទៅជាមួយនឹងគាត់ ។ ប៉ុន្តែបន្ទាប់ពី ណាអូមី រៀបរាប់ពីបញ្ហារបស់គាត់ផ្ទាល់ប្រាប់ដល់គេ និង បញ្ជាក់ប្រាប់ពីហេតុផលរបស់គេចំពោះការដែលគេព្រមទៅតាមគាត់នោះ នាងអ័រប៉ា ក៏ត្រឡប់ទៅឯស្រុកម៉ូអាប់វិញ ។ តែផ្ទុយទៅវិញនាងរស់ឆ្លើយតបទៅម្ដាយក្មេកវិញថា នាងស្ម័គ្រចិត្តទៅតាមម្ដាយក្មេក ។ នាងប្ដូរផ្ដាច់

យ៉ាងមុតមាំថា នឹងទៅជាមួយម្ដាយក្មេក ។ ក្រៅពីការប្តូរផ្ដាច់បែបនេះ នាងរស់ប្រកាសថាព្រះរបស់ណាអូមី ក៏ជាព្រះរបស់នាងដែរ (១:១៦) ហើយបានស្បថដោយនូវព្រះនាមរបស់យ៉ាវេ (១:១៧) ដូច្នេះក្រោយមកបូអូសបានសង្កេតឃើញយ៉ាងច្បាស់ថា សាសន៍ម៉ូអាប់បានមកពឹងជ្រក នៅក្រោមចំអេងស្លាបរបស់ព្រះយ៉ាវេ ជាព្រះរបស់អ៊ីស្រាអែល (២:១២) ។ នេះជាការសម្រេចចិត្ត នៃជំនឿរបស់នាងរស់ ។

សេចក្តីសម្រេចចិត្ត គឺមានតម្លៃណាស់ក្នុងការធ្វើការសង្កេត ដោយពិនិត្យពិច្ច័យ ។ ទីមួយរឿងនេះផ្ដល់ឲ្យមានហេតុការណ៍ជាអវិជ្ជមាន ។ និយាយតាមនិស្ស័យមនុស្ស អនាគតរបស់នាងរស់មើលទៅហាក់ដូចជាមានភាពប្រសើរឡើង បើនាងព្រមត្រឡប់ទៅម៉ូអាប់ជាមួយនាងអ័រប៉ាវិញ គឺថាអាចមានប្តីមានផ្ទះ និងបាន "សំរាក" ដែលហាក់បីដូចជាកំពង់រង់ចាំទទួលនាងនៅទីនោះ ។ ការសម្រេចចិត្តនៃជំនឿស្របតាមព្រះគម្ពីរជារឿយៗមានន័យថាត្រូវលះបង់ចោលនូវការល្អប្រសើរតាមគំនិតរបស់លោកិយ ដែលមើលទៅមិនល្អនោះដើរតាមការសម្រេចចិត្តស្របតាមព្រះគម្ពីរ[៤] ។ ទី២ ការសម្រេចចិត្តនោះបានធ្វើឡើងដោយមុតមាំ ។ ហេតុផលទី១ ព្រះជាម្ចាស់ផ្ដល់កិត្តិយសដល់ជំនឿរបស់នាង ហើយនិងរឿងរបស់នាងត្រូវបានគេយកមកនិយាយនៅដល់សព្វថ្ងៃនេះ គឺថាការជ្រើសរើសរបស់នាងគឺច្បាស់លាស់នឹងសម្រេចចិត្តយ៉ាងមុតមាំ ។ នៅក្នុងបទគម្ពីរទាំងមូល គឺជំនឿបែបនេះហើយ ដែលព្រះជាម្ចាស់សព្វព្រះហឫទ័យ[៥] ។ ទីបី ការសម្រេចចិត្តរបស់នាងរស់ កំណត់ឲ្យឃើញពីទិសដៅអនាគតរបស់នាង ។ នាង

---

[៤] *គំនិតនេះបានលេចឡើងនៅក្នុងគម្ពីរទាំងមូល ។ គំរូគួរឲ្យកត់សំគាល់ រាប់បញ្ចូលទាំងការស្ម័គ្រចិត្តរបស់អាប្រាហាំ ដោយយល់ព្រមយកតំបន់មិនសូវមានជីជាតិ នៃទឹកដីកាណាន ដែលផ្ទុយពីការជ្រើសរើសរបស់ ឡុត (លោកុប្បត្តិ ១៣) ហើយនិងសេចក្តីបង្រៀនរបស់ព្រះយេស៊ូ ដែលបានបញ្ជាក់ថាអ្នកណាដែលចង់បានជីវិតនោះ នឹងបាត់ជីវិត តែអ្នកណា ដែលបាត់ជីវិត ដោយព្រោះព្រះយេស៊ូ និងដំណឹងល្អ នឹងបានជីវិតវិញ (ម៉ាថាយ ១៦:២៥-២៦) ។*

[៥] *សូមមើលគំរូនៃការជ្រើសរើសរបស់ យ៉ូស្វេ ដោយមុតមាំក្នុងការជ្រើសយកព្រះមួយណាសំរាប់ដើរតាម (យ៉ូស្វេ ២៤:១៤-១៥) ការត្រាស់ហៅរបស់ព្រះជាម្ចាស់ឲ្យធ្វើការសម្រេចចិត្ត រវាងព្រះយ៉ាវេ និង ព្រះបាល (១ ពង្សាវតា ១៨:២១) ការថ្វាយសិរីល្អដល់ព្រះជាម្ចាស់ ដែលស្អប់ជំនឿក្តៅមិនក្តៅ ត្រជាក់មិន ត្រជាក់ (វិវរណៈ ៣:១៥-១៦) ។*

អ័របា៉ បានជ្រើសរើសយកផ្លូវមួយ ដោយពឹងផ្អែកលើការយល់ឃើញ និង ការវិភាគរកហេតុផលរបស់មនុស្ស ដែលគេហៅថា "ការដើរដោយការមើលឃើញ មិនមែនការដើរដោយជំនឿ"ឡើយ(គឺផ្ទុយគ្នាជាមួយនឹង២កូរិនថូស៥:៧) ។ យើងមិនបានឮគេនិយាយអំពីនាងអ័របា៉ឡើយ ។ នាងរស់ធ្វើការជ្រើសរើសផ្ទុយពីនាងអ័របា៉ ហើយនិងមិនយូរប៉ុន្មានការល្អទាំងអស់នាងបានទទួលនូវការសប្បាយរីករាយចំពោះការដែលនាងសម្រេចចិត្តនោះ ។ ទោះបីជាមិនឃើញមានអ្វីជាទីសង្ឃឹមយ៉ាងណាក៏ដោយនាងរស់នៅតែសម្រេចចិត្តទៅតាមណាអូមី និង ទុកចិត្តដល់ព្រះយ៉ាវេ ហើយការសម្រេចចិត្តនោះធ្វើឲ្យព្រឹត្តិការណ៏វិលទៅមុខទៅរកការល្អគ្រប់យ៉ាង ដែលនាងបានទទួលការសប្បាយរីករាយយ៉ាងឆាប់ នៅក្នុងការសម្រេចចិត្តរបស់នាង ។

## កិច្ចការនៃជំនឿ (ជំពូក ២)

ប៉ុន្តែតើជំនឿចប់ត្រឹមតែការសម្រេចចិត្ត ឬក៏គ្រាន់តែនិយាយខ្ញុំសម្រេចចិត្តហើយឬយ៉ាងណា? តើការសម្រេចចិត្តទុកចិត្តព្រះជាម្ចាស់មានន័យថា អ្នកជឿថ្មីនោះត្រូវអង្គុយរង់ចាំឲ្យព្រះធ្វើការជំនួសឬយ៉ាងណា? តើយើង"អះអាង" ចង់បានព្រះពររបស់ព្រះជាម្ចាស់ ហើយចាំឲ្យព្រះផ្តល់ឲ្យយើងតាមបែបមួយដ៏អស្ចារ្យឬ? តើជំនឿ មិនចាំបាច់អ្វីឲ្យយើងធ្វើការកាងារឬអី?

ចំពោះនាងរស់មិនដូច្នេះឡើយ ។ នាងបានធ្វើតាមពាក្យសំដីរបស់នាងដោយព្រមដើរតាមណាអូមី ទៅបេថ្លេហិមនៅក្នុងស្រុកយូដា នៅក្នុងខណៈដែលរដូវស្រូវឱកកំពុងចាប់ផ្តើមប្រមូលផល (១:២២) ។ ស្រូវឱកជារឿយៗ គេតែងគិតថាស្រូវឱកស្រាលជាងស្រូវសាឡី [៦]គេប្រមូលផលស្រូវឱកនៅក្នុងខែមេសា-ឧសភា ឯស្រូវសាឡីវិញ គេប្រមូលផលនៅពីរបីអាទិត្យក្រោយមក ។ នាងរស់មិនរង់ចាំឲ្យព្រះបំពេញសេចក្តីត្រូវការរបស់ម្តាយក្មេករបស់នាងមក តាមបែប

---

*(៦) ឧទាហរណ៍ ស្រូវឱក មានតម្លៃថោកជាងស្រូវសាឡីពីរដង នៅក្នុង ២ ពង្សាវតាក្សត្រ ៧:១ ថោកជាងបីដង នៅក្នុង វិវរណៈ ៦:៦ ការប្រៀបធៀបរបស់ គីឌាន និង អ៊ីស្រាអែល ចំពោះ "ដុំនំបុ័ងមូល ដែលធ្វើអំពី ស្រូវឱក" នៅក្នុង ចៅហ្វាយ ៧:១៣ ដែលជានិមិត្តសញ្ញាយ៉ាងច្បាស់ ពីភាពទន់ខ្សោយរបស់គេចំពោះសាសន៍ ម៉ាឌាន ។*

អស្ចារ្យនោះឡើយ ។ នាងរស់ស្នើសុំទៅរើសកួរស្រូវឱកនៅឯវាលស្រែ ។ គឺថា នៅខណៈដែលគេច្រូតស្រូវចងជាកណ្តាប់ តែមានកួរស្រូវខ្លះត្រូវបាក់ធ្លាក់មកដី ក៏គេច្រូតមិនអស់ ។ ក្រិត្យវិន័យនៅគម្ពីរសញ្ញាចាស់បានពណ៌នាថា កួរស្រូវបែបនេះត្រូវទុកសំរាប់"ពួកអ្នកក្រ និងពួកអ្នកមកពីក្រៅស្រុក"[៧] ។ ច្បាប់ដ៏ប្រពៃនេះផ្តល់ឲ្យអ្នកក្រ និង ជួយលើកទឹកចិត្តឲ្យគេរក្សាភាពថ្លៃថ្នូររបស់ពួកគេ ដោយទុកឱកាសឲ្យគេធ្វើការមុនពេលទទួលទានអាហារ មិនមែនគ្រាន់តែដើរសុំទានគេនោះឡើយ ។ ការនេះការពារការអាក្រក់ពីរយ៉ាង មិនឲ្យកើតមានឡើងគឺ មិនឲ្យពួកអ្នកមានកំណាញ់ហួសហេតុពេក និង មិនឲ្យអ្នកក្របានទទួលអាហារដោយស្រួលពេក ដោយមិនបានបញ្ចេញពលកម្មនោះដែរ ដែលជាហេតុនាំឲ្យបាត់បង់ភាពថ្លៃថ្នូររបស់ខ្លួន ។ ការរើសកួរស្រូវ គឺជាការលំបាកណាស់ គឺជាការងារដែលត្រូវចេះបន្ទាបខ្លួន ជាទូទៅការងារនោះវាមិនបានផលច្រើនណាស់ណានោះឡើយ តែវាអាចផ្តល់ឲ្យបានផលខ្លះ ។ នាងរស់ព្រមបន្ទាបខ្លួន និង ប្តូរផ្តាច់ស្ម័គ្រចិត្តធ្វើការងារនៃការស្វែងរកនូវការអនុញ្ញាត (២:២,៧) សុំរើសកួរស្រូវឱក ។ ក្នុងការធ្វើដូច្នេះនាងមិនបានបង្ហាញឲ្យឃើញថា នាងខ្វះជំនឿចំពោះព្រះថ្មីរបស់នាងឡើយ ក្នុងការដែលព្រះអង្គផ្តល់មកឲ្យនាងនូវអ្វី ដែលនាងត្រូវការនោះ ប៉ុន្តែនាងបង្ហាញពីជំនឿដ៏រស់[៨] ដែលនាងធ្វើតាមផ្លូវដែលព្រះជាម្ចាស់ អង្គនេះបានផ្តល់នូវការផ្គត់ផ្គង់ដល់សេចក្តីត្រូវការរបស់នាង ។ នាងមិនគ្រាន់តែធ្វើការប៉ុណ្ណោះទេ តែនាងធ្វើការយ៉ាងយូរ និង លំបាកទៀតផង (២:៧, ១៧, ១៨, ២៣)[៩] ។

---

(៧) *លេវីវិន័យ ១៩:៩-១០; ២៣:៣២ ចោទិយកថា ២៤:១៩-២២ ។ បូអូសបានធ្វើហួសពីច្បាប់តម្រូវឲ្យធ្វើ (២:១៥-១៦; ៣:១៥) ។ លទ្ធផលនោះគឺ នាងរស់ត្រឡប់មកផ្ទះបានស្រូវច្រើនហួសពីការ ដែលនាងរើសកួរស្រូវធម្មតាទៅទៀត គឺប្រហែលជា មួយថាំង (២:១៧) ។ ហេតុដូច្នេះ នាងរើសមួយថ្ងៃអាចចិញ្ចឹមស្ត្រីពីរនាក់រហូតបានបីអាទិត្យឯណោះ ។ ចំនួនដ៏ច្រើននេះ ធ្វើឲ្យណាអូមី សួរដល់នាងរស់ ហើយនិងសុំឲ្យព្រះជាម្ចាស់ប្រទានពរដល់ម្ចាស់ស្រែ ទោះបីជាមិនទាន់បានដឹងថាអ្នកនោះជាអ្នកណាក៏ដោយ ។ (២:១៨-១៩)។*

(៨) *សូមមើល យ៉ាកុប ២:១៤-២៦*

(៩) *រដូវច្រូតកាត់ដែលមានលើកមកនិយាយក្នុង ២:២៣ មានរយៈពេលដែលប្រហែលប្រាំពីរអាទិត្យ*

ដោយមិនគ្រោងទុកជាមុនសោះ នាងរស់បានជ្រើសរើសស្រែដែលជាកម្មសិទ្ធិរបស់ បូអូស ជាសាច់ញាតិដ៏គួរឲ្យគោរពរាប់អានរបស់អេលីម៉ាឡេក (២:១,៣,២០) ។ តាមការប្រាស្រ័យទាក់ទងរវាងគាត់ និងអ្នកចម្រូតរបស់គាត់(២:៤)បង្ហាញឲ្យយើងដឹងថា គាត់មានចរិតសប្បុរស និង កោតខ្លាចព្រះ ។ ទោះបីជានៅក្នុងយុគសម័យងងឹត ក្រោមការដឹកនាំរបស់ពួកចៅហ្វាយ ក៏នៅមានមនុស្ស ដែលកោតខ្លាចព្រះជាម្ចាស់ ហើយនិងថ្វាយព្រះកិត្តិយសដល់ព្រះអង្គដែរ ។ ក្រោយមកយើងឃើញថាគាត់ជាមនុស្សសប្បុរស (២:១៤-១៦; ៣:១៥) ស្មោះត្រង់ (៣:១៤) នឹងធឹង និង ឧស្សាហ៍ធ្វើការងារ (៤:១-១០) ។ គាត់សង្កេតមើល និងសាកសួរអំពីនាងរស់ ហើយនិងផ្តល់ឲ្យនាងដោយចិត្តសប្បុរស នៅពេលដែលគាត់ដឹងថានាងរស់ជានរណាហើយនោះ ។ គាត់ធ្វើដូច្នេះ ពីព្រោះមានគេប្រាប់គាត់ពីកិច្ចការនៃជំនឿរបស់នាង ពីរបៀបដែលនាងមកពឹងជ្រកនៅក្រោមចំអេងស្លាបរបស់ព្រះយ៉ាវេ ហើយខំធ្វើការបំរើដល់ម្តាយក្មេក (២:១១-១២) ។ គាត់អធិស្ឋានសុំឲ្យព្រះជាម្ចាស់ប្រទានពរដល់នាង (២:១២) ដោយដឹងតិចៗថាគាត់នឹងអាចជាផ្លូវមួយដែលអាចនាំព្រះពរចុះមកបាន ។ គាត់បានជំរុញឲ្យនាងរស់ ស្នាក់នៅស្រែរបស់គាត់ និង នៅជាមួយអ្នកច្រូតរបស់គាត់ដោយយល់ដល់សុវត្ថិភាពរបស់នាង(២:៨-៩)-ណាអូមីក៏ជំរុញឲ្យនាងរស់ រើសកួរស្រូវនៅស្រែរបស់បូអូសតទៅទៀតដែរ ដើម្បីចៀសវាងកុំឲ្យមនុស្សអាក្រក់ធ្វើបាប(២:២២) ។

**ការស្នើសុំដោយជំនឿ** (ជំពូក ៣)

ជំនឿអាចរឹងមាំបានក្នុងការសម្រេចចិត្ត ដែលផ្ទុយស្រឡះពីការវិនិច្ឆ័យផ្ទាល់ខ្លួន ហើយបន្ទាប់មកអនុវត្តនូវការសម្រេចចិត្តយ៉ាងម៉ត់ចត់ ប៉ុន្តែជំនឿតាមព្រះគម្ពីរ គឺមិនរីករាយជាមួយនឹងអ្វី ដែលយើងសម្រេចបានតែមួយមុខប៉ុណ្ណោះទេ ។ ជំនឿគឺទទួលស្គាល់ពីសេចក្តីត្រូវការ ហើយនិង ទូលសុំឲ្យព្រះជាម្ចាស់ធ្វើការអ្វី ដែលមិនអាចធ្វើបាន ។

កាលពីដំបូងណាអូមី បានអធិស្ឋានសុំព្រះជាម្ចាស់ឲ្យព្រះអង្គផ្តល់ការសំរាកដល់កូនប្រសារស្រីរបស់គាត់ នៅក្នុងផ្ទះរបស់ប្តីម្នាក់ផ្សេងទៀត (១:៩)

ដូចជាមិនទំនងសោះចំពោះនាងរស់ ដែលនាងជាជនស្រុកក្រៅ[១០] ដែលអាចនាំព្រះពរមកស្រុកយូដាយ៉ាងច្រើនម្ល៉េះ ។ ប៉ុន្តែឥឡូវនេះ ដោយសារសេចក្តីត្រូវការផ្ទាល់របស់គាត់បានសម្រេច និង សេចក្តីសង្ឃឹមបានកែប្រែជាថ្មីឡើង ណាអូមីបង្វែរគំនិតរបស់គាត់ ពីការទុក្ខព្រួយដ៏ល្វីងជូរចត់ចំពោះកូនប្រសារស្រីរបស់គាត់ ហើយក៏មានគំនិតថា គាត់នឹងត្រូវស្វែងរក "ការសំរាក"[១១] ឲ្យនាងរស់ (៣:១) ។ ម្នាក់ ដែលគាត់ត្រូវស្វែងរកនោះគឺ បូអូស ដែលគាត់បានបង្ហាញពីភាពសប្បុរសរបស់គាត់ ចំពោះនាងរួចទៅហើយ ។

តាមច្បាប់របស់ពួកយូដា បានបង្ហាញថា បើបងប្អូនប្រុសរស់នៅជាមួយគ្នាហើយមានម្នាក់ស្លាប់ហើយគ្មានកូនប្រុស បងប្អូនប្រុសដែលនៅរស់នោះ ត្រូវរៀបការជាមួយស្ត្រីមេម៉ាយនោះ ។ កូនទីមួយដែលបានកើតមកនោះ ត្រូវដាក់ឈ្មោះតាមត្រកូលអ្នកស្លាប់ (ចោទិយកថា ២៥:៥-១០) ។ ទម្លាប់នេះហើយដែលធ្វើឲ្យពួកសាឌូស៊ីចោទសួរដល់ព្រះយេស៊ូនៅក្នុង ម៉ាថាយ ២២:២៣-៣៣ ហើយ និង ការចាក់បណ្តោយស្របទៅនឹងខគម្ពីរនោះ ។ ដោយបង្ហាញត្រួសៗ តាមផែនការនៃជំពូក ៣:៣-៤ ណាអូមី បានជំរុញឲ្យនាងរស់ឲ្យទៅសុំបូអូសបង្ហាញពីភាពទទួលខុសត្រូវ ក្នុងការដែលគាត់អាចរៀបការជាមួយនាងបាន។ ការត្រដាងសំលៀកបំពាក់របស់នរណាម្នាក់គ្របទៅម្នាក់ទៀត (៣:៩) គឺមានន័យថា ជាការស្នើសុំរៀបការ ដូចនៅក្នុងអេសេគាល ១៦:៨ ។

រឿងនេះអាចធ្វើឲ្យអ្នកអានភ្ញាក់ផ្អើល ព្រោះវាចំៗពេក ប៉ុន្តែជំនឿគឺព្រមបន្ទាបខ្លួន និងហ៊ានសុំចំពោះការធំ ។ ការទទូចយ៉ាងខ្លាំងរបស់ស្ត្រីម្នាក់នៅក្នុង (ម៉ាថាយ ១៥:២១-២៨ ; ម៉ាកុស ៧:២៤-៣០) គួសបញ្ជាក់បន្ថែមលើសេចក្តីពិតនោះ ។ ចំពោះនាងរស់ កិច្ចការនៃជំនឿរបស់នាងបានក្លាយទៅជាការផ្គត់ផ្គង់ដល់សេចក្តីត្រូវការរបស់នាងផ្ទាល់ និង របស់ណាអូមីផង គឺនាងបានធ្វើដោយ

---

[១០] *ខគម្ពីរយោងលើកយកមកនិយាយពីនាងរស់ ដែលជាសាសន៍ "ម៉ូអាប់"នៅក្នុងកណ្ឌគម្ពីរទាំងមូល (១:២២; ២:២, ៦, ២១; ៤:៥, ១០) ដែលបាននិយាយសង្កត់ធ្ងន់ថា នាងជាសាសន៍ដទៃ ។*

[១១] *ភាសាហេព្រើ បានបកប្រែថា "សំរាក" គឺជានិមិត្តសញ្ញាបញ្ជាក់ថា បានស្នាក់នៅក្នុងកន្លែងពិសេសណាមួយ ។ គឺជាកន្លែង ដែលត្រូវកសាងជីវិត គឺជាផ្ទះ ដែលគេចង់និយាយពីកន្លែងមានសន្តិសុខ មិនមែនជាការលំហែកាយនោះទេ ។*

ចិត្តក្លាហាន នាងស្មើដោយជំនឿឥតមានស្ទាក់ស្ទើរ ជាហេតុនាំឲ្យកិច្ចការជាច្រើនបានសម្រេចចំពោះរូបនាង ។

"លានបោកស្រូវ" គឺជាកន្លែងដែលគេលើកឡើងឲ្យខ្ពស់បន្តិច ធ្វើឲ្យរាបស្មើ ដោយរៀបថ្ម ឬ បុកបង្ហាប់ដី តាមធម្មតាស្ថិតនៅខាងកើត ឬ នៅក្រោមខ្យល់ពីទីក្រុង ។ អ្នកច្រូតផាត់ចំបើង រោយស្រូវនៅពេលមានជំនោរបក់មក ដែលតាមធម្មតាបក់មកពីសមុទ្រ មេឌីតេរ៉ាណេ នៅពេលរសៀល ។ អង្កាម ឬ សំដីស្រូវប៉ើងខ្ចាត់ខ្ចាយទៅ ប៉ុន្តែគ្រាប់ស្រូវដែលមានជាក់គ្រាប់នោះត្រូវធ្លាក់នៅ លើដីដើម្បីឲ្យគេអាចប្រមូលកើបដាក់ជង្រុក ។ ចំណែកឯ បូអូស ដ៏ជាមនុស្ស សាមញ្ញដែលមិនប្រកាន់ខ្លួនបានសំរាន្តនៅឯលានបោកស្រូវ មិនដឹងថាគាត់សំរាន្តយាមស្រូវ ឬ សំរាន ដោយមានពិធីបុណ្យអ្វីឡើយ ។ ទោះជាយ៉ាងណាក៏ ដោយមានអ្នកបកស្រាយខ្លះ បានឃើញពីភាពឲ្យដៃ នៅក្នុងទង្វើរបស់នាងរស់ ដែលបានបើក "ភួយចុងជើងរបស់ បូអូស" ។ សេចក្តីថ្លែងការណ៍របស់ បូអូស នៅក្នុង ៣:១១ ដែលបង្ហាញឲ្យដឹងថា នាងរស់ ជាស្ត្រីមានចរិតល្អ ដូចជាតួអង្គ សំខាន់នៅក្នុងរឿងទាំងមូលដែរ គេបានប្រកែកប្រឆាំងចំពោះការប៉ាន់ស្មានបែបនេះ ។ នាងរស់គឺគ្រាន់តែព្រមសុំឲ្យបូអូស បង្ហាញពីកាតព្វកិច្ចរបស់គាត់ក្នុងនាមជាសាច់ញាតិដែលអាចជួយសង្គ្រោះនាងបាន ។ ការដែលនាងងូតទឹកសំអាតខ្លួន លាបទឹកអប់ និង ស្លៀកពាក់ស្អាតបាត (៣:៣) តាមពិតទៅមិនមែនមានបំណងចង់បង្អាក់ការឆ្លើយតបរបស់គាត់ចំពោះនាងនោះឡើយ ។

មិនថាឡើយនាងដឹង ឬ មិនបានដឹងថា អេលីម៉ាឡេក មានសាច់ញាតិជិតៗជាង បូអូស ដែលមានសិទ្ធិនឹងទិញដីរបស់គាត់ និង អាចយកនាងរស់ ធ្វើជាប្រពន្ធរបស់គាត់ ។ បូអូស ភ្ញាក់ក្រញាងទាំងកណ្តាលយប់ នៅពេលដែលគាត់ដេកនៅឯលានបោកស្រូវ ភ្ញាក់ឡើងឃើញស្ត្រីម្នាក់នៅចុងជើងរបស់គាត់ ។ គាត់បានស្គាល់ពីអត្តសញ្ញាណរបស់នាង និង បានឮពីសំណើរបស់នាង បូអូសបានស្នើដល់នាងរស់ថា នៅពេលព្រឹកឡើង គាត់នឹងប្រាប់សាច់ញាតិម្នាក់ទៀត ដែលអាចជួយលោះនាងបាន ហើយបន្ទាប់មកបើសាច់ញាតិម្នាក់នោះ គេមិនព្រមប្រើសិទ្ធិរបស់គេ ដើម្បីលោះនាងទេ គាត់សន្យាថានឹងលោះនាង ដោយខ្លួនឯង ។ បន្ទាប់មកគាត់បានប្រាប់ឲ្យនាងរស់ដេកលក់ទល់ភ្លឺ ហើយមុនពេលនាងចាកចេញទៅ គាត់បានឲ្យស្រូវឱកទៅនាង ៦ រង្វាល់ (មួយតៅ) ។

ណាអូមី ចង់ដឹងឮយ៉ាងខ្លាំងថា តើរឿងរ៉ាវនោះទៅជាយ៉ាងណាហើយ ។ នៅពេលដែលគាត់ឮរឿងរ៉ាវ ដែលនាងរស់រៀបរាប់ប្រាប់ និង ឃើញស្រូវដែលបូអូស ផ្ញើមកឲ្យគាត់ គាត់បានលើកទឹកចិត្តឲ្យនាងរស់រង់ចាំមើលលទ្ធផលជាយ៉ាងណា ថែមទាំងអះអាងថា បូអូសនឹងប្រកាន់តាមពាក្យសន្យារបស់គាត់ ។ នៅថ្ងៃនេះឯង គាត់នឹងធ្វើការនោះ ។

ដូច្នេះសំណើនៃជំនឿ បានក្លាយជាការសំរាកនៃជំនឿ ។ ជំនឿធ្វើឲ្យហ៊ានសុំកិច្ចការធំៗ សូម្បីតែភ្នំក៏អាចរើបានដែរ (ម៉ាថាយ ២១:-២២) ហើយបន្ទាប់មកយើងសំរាកក្នុងជំនឿ ដែលទុកឲ្យព្រះធ្វើការនោះជំនួសយើង ។ ការនេះធ្វើឲ្យយើងនឹកឃើញដល់ស្តេច យេហូសាផាត ដែលបានទូលអង្វរដល់ព្រះជាម្ចាស់ប្រឆាំងនឹងកងទ័ពចំរុះ ដែលបានដើរជាក្បួនមកប្រឆាំងទាស់នឹងទ្រង់ ហើយពេលនោះ ស្តេចយេហូសាផាត បានទទួលបញ្ជាថាឲ្យសំរាក និង រង់ចាំ ការដែលព្រះជាម្ចាស់រំដោះឲ្យរួចពីដៃសត្រូវ (២ របាក្សត្រ ២០) ។ នាងហាណាអធិស្ឋានទូលសូមកូនប្រុស ហើយបន្ទាប់មកក៏សំរាកក្នុងជំនឿ សំរាប់ចម្លើយរបស់ព្រះជាម្ចាស់ "បានចេញទៅ ហើយនិងទទួលទានចំណីអាហារខ្លះ និង ទឹកមុខរបស់គាត់បាត់ទុក្ខព្រួយ" (១សាំយូអែល ១:១៨) ។ អ្នកទាំងនេះ និង អ្នកដទៃទៀតបានស្មើចំពោះព្រះជាម្ចាស់ មិនសុំព្រះជាម្ចាស់សំរាប់របស់អ្វីមួយ ដោយបំណងអាត្មានិយមរបស់ខ្លួនច្រើនហួសហេតុ ប៉ុន្តែយើងសុំសំរាប់របស់អ្វី ដែលជាសេចក្តីត្រូវការចាំបាច់ ដែលស្របជាមួយនឹងសេចក្តីសញ្ញារបស់ព្រះអង្គ ហើយនិងបន្ទាប់មកសំរាកដោយសង្ឃឹមរង់ចាំទទួលចម្លើយពីព្រះអង្គ ។ នៅមានទៀតសំខាន់បំផុតគឺត្រូវចងចាំពី សំណើរបស់នាងរស់ គឺនាងធ្វើតាំងពីការសម្រេចចិត្តដោយជំនឿ និង ការធ្វើការដោយជំនឿរបស់នាង និងនាងមិនបានផ្តេកផ្តួលលើភាពខ្ជិលច្រអូសឬគេចវេះពីភាពទទួលខុសត្រូវ និង សេចក្តីត្រូវការរបស់ជីវិតរស់នៅឡើយ ។ សំណើរបស់នាងបានធ្វើឡើងស្របតាមសេចក្តីសន្យារបស់ព្រះជាម្ចាស់ដែលមាននៅក្នុងក្រិត្យវិន័យ ប៉ុន្តែគឺវាហួសពីសមត្ថភាពរបស់នាង ដែលអាចធ្វើការងារនោះឲ្យកើតឡើងដោយខ្លួនឯងបាន ។

## រុទ្ធានខែជំនឿ (ជំពូក ៤)

នៅក្នុងជំពូក ៤ យើងឃើញថា បូអូស ខំប្រឹងធ្វើការទាល់តែបានសម្រេចតាមសេចក្ដីសន្យារបស់គាត់ ។ គាត់នឹងធ្វើកិច្ចការគ្រប់យ៉ាងទាំងអស់ ដោយប្រើកម្លាំង ភាពមានសីលធម៌ និង ភាពម៉ត់ចត់បំផុតរបស់គាត់ ។

"ច្រកទ្វារទីក្រុង" (៤:១) គឺជាមណ្ឌលសាធារណៈសំរាប់មនុស្សធ្វើជំនួញទូទៅ ធ្វើការដោះដូរ និងផ្ដល់ការវិនិច្ឆ័យផ្សេងៗ[១២] ។ បូអូសបានទៅទ្វារ ទីក្រុង ហើយនៅពេលដែលសាច់ញាតិជិតដិតរបស់គាត់បានដល់ គាត់បាននាំម្នាក់នោះទៅកាន់បន្ទប់"កាត់ក្ដី" ។ បន្ទាប់មកគាត់អញ្ជើញចាស់ទុំគម្រប់ដប់នាក់មកធ្វើជាសាក្សីនៅក្នុងពេលពិភាក្សារបស់គាត់ ។ នៅពេលដែលពាក្យសំដីរបស់ បូអូស ដែលថាអេលីម៉ាឡេកមានទ្រព្យសំរាប់លក់ ។ សាច់ញាតិជិតដិតនោះ បានបង្ហាញពីការចាប់អារម្មណ៍ដោយសួររករបស់នោះ ។ ប៉ុន្តែនៅពេលដែល គាត់បានដឹងថារឿងនោះទាក់ទងទៅនឹងការរៀបការជាមួយនាងរស់ និងការបន្តពូជពង្សឲ្យអេលីម៉ាឡេក គាត់ក៏ប្រកែកភ្លាម ។ បន្ទាប់ក្រោយមក មានការពណ៌នា ពីទំលាប់ដែលបានក្លាយជាទំនៀមទំលាប់តាំងពីយូរណាស់មកហើយ ដែលត្រូវឲ្យមានការពន្យល់នៅចំពេល ដែលកំណត់គម្ពីរនេះបានសរសេរឡើង ចំពោះការដែលប្រគល់ស្បែកជើងឲ្យ គឺបង្ហាញពីភាពស្របច្បាប់ក្នុងការធ្វើការជួញដូរ(៤:៧-៨) ។ បន្ទាប់មក បូអូស បញ្ជាក់ថា គាត់មានបំណងនឹងលោះស្រែអំពកនោះ និង ព្រមរៀបការជាមួយនាងរស់ ដោយបញ្ជាក់យ៉ាងមុតមាំ និង ច្បាស់លាស់ដូច ដែលនាងរស់សម្រេចចិត្តចាកចោលស្រុកម៉ូអាប់ និង ព្រមតាម ណាអូមី ដូច្នេះដែរ (៤:៩-១០ ជំពូក ១:១៦-១៧)[១៣] ចាស់ទុំទាំងដប់នាក់បានបញ្ជាក់ថា គេបានធ្វើជាសាក្សីចំពោះការដោះដូរនេះដោយព្រលយពាក្យ ប្រាប់ឲ្យដឹងថាគ្រប់យ៉ាងទាំងអស់មានសណ្ដាប់ធ្នាប់ត្រឹមត្រូវ ។ ពួកគេអធិស្ឋានសុំព្រះពរសំរាប់ការស្នើសុំការរៀបការនេះ ហើយគេអធិស្ឋានសូមឲ្យពួកគេឆាប់មានកូន ។ មិនយូរប៉ុន្មាន ព្រះអម្ចាស់

---

[១២] *សូមមើល ឧទាហរណ៍ លោកុប្បត្តិ ២៣:១០,១៨; ៣៤:២០,២៥; ចោទិយកថា ១៧:១៥; ២១:១៩; ១៥,២៤; ២៥:៧ ហើយនិងនៅទូទាំងគម្ពីរសញ្ញាចាស់ទាំងមូល ។*

[១៣] *ដូចជា បូអូស មានចិត្តមិនគិតពីអាត្មានិយម ចរិតស្មោះត្រង់ ស្របគ្នានឹងនាងរស់ ដូច្នេះសាច់ញាតិដែលមានសិទ្ធិលោះនាងបាន គេប្រកែកមិនព្រម ព្រោះអ្នកនោះមានចរិតគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន និងធ្វើអ្វីៗតាម "ការវិនិច្ឆ័យតាមក្បួនខ្នាត" ចរិតលក្ខណៈនេះស្របទៅ នាង អ័រប៉ា ។*

ឆ្លើយតបនឹងសេចក្ដីអធិស្ឋានរបស់គេទាន់ពេល ។ នាងរស់ក៏មានផ្ទៃពោះ(៤:១៣) និងកើតបានកូនប្រុសមួយ ។

ឥឡូវនេះ សម្បត្តិរបស់ណាអូមី បានមកពេញលេញដូចមុនវិញហើយ។ គាត់បានចាកចេញពីយូដាទៅដោយពេញពោរ ដល់ត្រឡប់មកវិញទទេ (១:២១) ហើយឥឡូវនេះគាត់បានទទួលពេញពោរឡើងវិញទៀតហើយ ។ ស្ត្រីដែលមានឈ្មោះ "រីករាយ" ដែលបានសន្និដ្ឋានថាជាចំណងជើងដែល "ជូរចត់" នោះ ឥឡូវនេះ បែរជាមានសេចក្ដី "រីករាយ" ដោយមានអ្នកជួយលោះ ដែលជួយឲ្យជីវិតរបស់គាត់បានកែប្រែជាថ្មី និងជួយគាំទ្រជីវិតរបស់គាត់ កាលដែលគាត់ចាស់ហើយនោះ (៤:១៥)[១៤] ។ ណាអូមី បានលើកកូនតូចមកដាក់លើភ្លៅ ហើយបីបមថ្នមថែកូនក្មេងនោះ (៤:១៦) ។ គ្រប់ការទាំងអស់នេះ គឺដោយសារតែព្រះពររបស់ព្រះជាអម្ចាស់ ដែលបានប្រទានពរមកដល់គាត់ ដោយព្រោះគាត់បានវិលត្រឡប់មកកាន់ទឹកដីសន្យាហើយនិងដោយសារតែ ការងារនៃកូនប្រសារស្រីដ៏ស្មោះត្រង់ ដែលគ្រាន់បើជាងកូនប្រុស ៧ នាក់ ទៅទៀត (៤:១៥)[១៥] ។

បញ្ជីរៀបរាប់ពីពង្សាវតា ដែលបានបង្ហាញពីភាពដ៏មានសារសំខាន់ និងហួសពីការដែលយើងអាចគិតដល់ ចំពោះការសម្រេចចិត្ត កិច្ចការ និងសំណើដោយជំនឿរបស់នាងរស់ ។ ប៉េរេសដែលមានពង្សាវតាចាប់ផ្ដើមនៅក្នុង (៤:១៨) ជាកូនរបស់យូដា[១៦] ដែលព្រះជាម្ចាស់បានសន្យានឹងផ្ដល់ឲ្យមានអ្នកដឹកនាំមកយ៉ាកុប[១៧]នោះ ។ មែនហើយអូបិឌជាកូនរបស់បូអូសនិងនាងរស់ហើយកូននោះ

---

(១៤) *នៅខាងដើមនៃកណ្ឌគម្ពីរនេះ គេបានពិចារណាឃើញថា បូអូស ជាសាច់ញាតិដែលអាចលោះនាងរស់បាន ។ ប៉ុន្តែ ឥឡូវនេះនៅក្នុងជំពូក ៤:១៤-១៥ ចំណងជើងនោះ គេបានយកមកប្រើចំពោះកូនក្មេងដែលបានកើតមកពី បូអូស និងនាងរស់ ផងដែរ ។ អូបិឌ នឹងដើរតួជា "អ្នកសង្គ្រោះឬអ្នកលោះ" ណាអូមីឲ្យរួចពីភាពទទេស្អាត ភាពមិនសំខាន់ និង ភាពគ្មានក្ដីសុខនោះទៅវិញ ។*

(១៥) *ការនេះគឺជាការ ដែលទទួលបានសេចក្ដីកោតសរសើរខ្លាំងណាស់ នៅក្នុងសម័យនោះ កូនប្រុសហាក់ដូចជាមានតម្លៃខ្លាំងជាងកូនស្រី ។*

(១៦) *លោកុប្បត្តិ ៣៨ បានថែងប្រាប់ពីរឿងចាប់កំណើត និងការកើតរបស់ប៉េរេស ។ (លោកុប្បត្តិ ៤៦:១២)*

(១៧) *លោកុប្បត្តិ ៤៩:១០*

ក្លាយជាឪពុករបស់អ៊ីសាយ ហើយនិង អ៊ីសាយជាឪពុករបស់ដាវីឌ ជាស្តេចនៃអ៊ីស្រាអែល និងជាពូជពង្សវង្សត្រកូល ដែលព្រះយេស៊ូជាព្រះមេស្ស៊ីយាងមកចាប់ កំណើតជាមនុស្ស[១៨] ។ តើនរណានឹងដឹងបានថាវាសំខាន់យ៉ាងម៉េចនោះចំពោះការសម្រេចចិត្ត កិច្ចការ និង សំណើដោយជំនឿរបស់មនុស្សម្នាក់នោះ? តើនរណាអាចដឹងបានថាតើរង្វាន់នៃជំនឿនោះធំប៉ុណ្ណាឡើយ សំរាប់មនុស្សដែលបានទទួលការនោះ? នាងរស់មិនគ្រាន់តែបានទទួលព្រះពរ ដោយបាន "សំរាក" នៅក្នុងផ្ទះមានប្តីមានកូន តែនាងរីករាយចំពោះការគោរពរាប់អាន ចំពោះអស់អ្នកដែលបានស្គាល់នាងតែប៉ុណ្ណោះទេ (៣:១១; ៤:១៥) គឺនាងថែមទាំងបានក្លាយទៅជាពូជពង្សវង្សត្រកូល ដែលព្រះមេស្ស៊ី នឹងមកចាប់កំណើត ។ ការទាំងអស់នេះគឺសំរាប់ជនបរទេសដែលបានដាក់ជំនឿរបស់ខ្លួន ជឿដល់ព្រះជាម្ចាស់នៃអ៊ីស្រាអែល និងធ្វើការប្រព្រឹត្តិតាមជំនឿនោះ[១៩] (គឺនឹងបានដូចជា នាងរស់ដែរ) ។

## ការពិចារណាដទៃផ្សេងទៀត

ដូចដែលបានជំរាបពីខាងដើមរួចមកហើយថា អត្ថបទនេះមិនបានមានបំណងពន្យល់ឲ្យស៊ីជម្រៅនៃកណ្ឌគម្ពីរនាងរស់ទេ ប៉ុន្តែគ្រាន់តែផ្តល់ការណែនាំ

---

[១៨] *ការរាប់ នាងរស់ ជាសាសន៍ ម៉ូអាប់ បញ្ចូលក្នុងវង្សត្រកូលរបស់គាត់ អាចជួយពន្យល់ពីហេតុអ្វីបានជាការនេះកើតឡើងបាន ដ្បិតអី ពួកម៉ូអាប់ គឺធ្លាប់ជាខ្មាំងសត្រូវរបស់អ៊ីស្រាអែល (១ សាំយូអែល ១២:៩; ១៤:៤៧) ព្រះបាទដាវីឌ បាននាំយកឪពុកម្តាយរបស់ទ្រង់ទៅលាក់នៅឯម៉ូអាប់ ព្រោះខ្លាចស្តេចសូលធ្វើបាបក្នុងពេលដែលស្តេចសូលដេញតាមនោះ (១ សាំយូអែល ២២:៣-៤) ។*

[១៩] *បញ្ជីរាយនាមពង្សាវតានៃព្រះយេស៊ូ នៅក្នុងម៉ាថាយ ១បានចុះបញ្ជីស្ត្រី ៤ នាក់ ក្នុងចំណោមស្ត្រីទាំងបួននាក់ ក្នុងចំណោមស្ត្រីទាំងបួន គ្មានស្ត្រីណាម្នាក់ ដែលគួរឲ្យគោរព ឬគួរផ្តល់កិត្តិយសឡើយ ។ នាងតាម៉ាជាកូនប្រសាររបស់យូដា និង យូដាមានទំនាក់ទំនងជាមួយនាងជាអំពើអសីលធម៌ (លោកុប្បត្តិ ៣៨)។ នាងរ៉ាហាបជាស្រីបរទេសម្នាក់មកពីទីក្រុង យេរីខូ ដែលខូចបាក់ ហើយមានអ្នកបកស្រាយជាច្រើនថានាងជាស្រីសំផឹង ។ នាងរស់ជាស្រីបរទេសម្នាក់ និងជាសាសន៍ម៉ូអាប់ ដែលហេតុការណ៍នោះ គេបានលើកមកបញ្ជាក់ម្តងហើយម្តងទៀត នៅក្នុងកណ្ឌគម្ពីរទាំងមូល (ចូរសង្កេតមើល នៅក្នុងកំណត់ចំណាំទំព័រក្រោម ត្រង់លេខ ១០) ។ ចោទិយកថា ២៣:៣ បានបញ្ជាក់ថា គ្មានសាសន៍ម៉ូអាប់ណាម្នាក់អាចអនុញ្ញាតឲ្យចូលទៅក្នុងរួមប្រជុំនៃព្រះយ៉ាវេបានឡើយ សូម្បីតែដប់ជំនាន់ក្រោយមកទៀត ក៏មិនអនុញ្ញាតឲ្យចូលរួមដែរ ។ ទីបំផុត បេតសេបា ឬ "ប្រពន្ធរបស់អ៊ូរី" មិនគួរឲ្យក្លាយជាមហេសីព្រះបាទដាវីឌបានឡើយ ។ ព្រះជាម្ចាស់ប្រព្រឹត្តិជាមួយរាស្ត្រអ៊ីស្រាអែល និងជាមួយមនុស្សជាតិទាំងអស់ គឺដោយព្រោះតែព្រះគុណាប៉ុណ្ណោះ ។*

ឲ្យគិតពីតួអង្គ និង ការរីកចំរើននៃជំនឿរបស់នាងរស់ ដែលមាននៅក្នុងកណ្ឌគម្ពីរនេះទាំងមូល ។ ខ្លឹមសារដទៃទៀតនៃរឿងនេះ ដែលប្រហែលជាមានប្រយោជន៍ក្នុងការតាមដាននោះគឺ៖

- ការសិក្សាពីចរិតលក្ខណៈនៃតួអង្គ ណាអូមី ទោះបីជារស់នៅក្នុងទឹកដីបរទេស(ប្រទេសក្រៅ) អស់រយៈពេលមួយទសវត្សរ៍ឬយ និងនៅក្នុងពេលចុងបញ្ចប់និយាយបញ្ចេញកំហឹងចំពោះវាសនា ដែលព្រះយ៉ាវេបានដាក់កំរិតឲ្យរូបគាត់ ទោះជាយ៉ាងណាក៏ដោយ គាត់មានបុគ្គលិកលក្ខណៈដែលគួរឲ្យចាប់ចិត្តជិតអារម្មណ៍ បង្ខំឲ្យនាងរស់ចាកចោលផ្ទះសម្បែងចោលក្តីសង្ឃឹម និង ព្រះរបស់ខ្លួនមកព្រមតាម ណាអូមី ទៅកាន់ស្រុកយូដា ។
- រំពឹងគិតពីអធិបតេយ្យភាពនៃព្រះជាម្ចាស់ ដែលធ្វើការពីក្រោយឆាក ដើម្បីឲ្យនាងរស់ "ពើបប្រទះ" ដោយជ្រើសរើសទៅរើសកួរស្រូវ នៅក្នុងស្រែបូអូស ដែលបណ្តាលឲ្យ បូអូសភ្ញាក់ឡើងចំពេលដ៏ត្រឹមត្រូវនេះ ហើយដឹងប្រាកដ ថាសាច់ញាតិជិតដិតម្នាក់ទៀត នឹងដើរកាត់ទ្វារក្រុង នៅពេលព្រឹកឡើង ហើយដឹងទៀតថាអាចឲ្យនាងរស់បានកូនប្រុសជាដើម ។ ស្រដៀងគ្នានេះដែរ អាចធ្វើឲ្យយើងគិតដល់កណ្ឌគម្ពីរ អេសធើរ ដែលនៅក្នុងនោះព្រះនាម របស់ព្រះជាម្ចាស់មិនបានលើកមកនិយាយឡើយ តែការងាររបស់ព្រះអង្គ មាននៅក្នុងព្រឹត្តិការណ៍ក្នុងសាច់រឿងនោះយ៉ាងច្បាស់ ។
- ការសិក្សានៃការអធិស្ឋាន "ដែលមិនសមរម្យ" ឬ ការថ្លែងពាក្យសំដីមិនល្អប្រឆាំងទាស់នឹងព្រះជាម្ចាស់ (យ៉ាវេ) នៅក្នុងព្រះគម្ពីររបស់ពួកអ្នកជឿ របស់ព្រះអង្គ គឺគិតបញ្ចូលទាំង ណាអូមី យ៉ូប អាសាភ យេរេមា ។ល។
- ការសិក្សាពីញាតិសន្តាន ដែលអាចលោះបាន ដែល (១) ត្រូវតែជាសាច់ញាតិដែលជិតដិតជាងគេ (២) ត្រូវតែអាចជួយលោះបាន និង (៣) ត្រូវតែមានបំណងចង់លោះ ។ ភាពស្របគ្នានេះអាចធ្វើឲ្យយើងគិតដល់ព្រះយេស៊ូដែលជាតួអង្គដ៏សំខាន់ក្នុងការសម្រេចនូវការប្រោសលោះ ស្របតាមព្រះគម្ពីរសញ្ញាចាស់ ដែលទី (១) បានយកនិស្ស័យជាមនុស្ស ដែលក្លាយជា "សាច់ញាតិយ៉ាងជិតស្និតរបស់យើង" (ហេព្រើ ២:១៤-១៨; ៤:១៤-១៦) ទី (២) គឺអាចជួយប្រោសលោះបាន (ហេព្រើ ៧:២៥) ហើយនិងទី (៣) មាន

បំណាងនឹងជួយប្រោសលោះ (យ៉ូហាន ១០:១៧-១៨; លូកា ២២:៤១-៤២)។ ពាក្យនេះបានលេចឡើង ២៣ ដងនៅក្នុងកណ្ឌគម្ពីរនាងរស់ ។[២០]

- កណ្ឌគម្ពីរនាងរស់ផ្ដល់ឲ្យនូវគំនិតនៃសន្ធិសញ្ញាដ៏ស្មោះស្ម័គ្រ ឬ សេចក្ដីស្រឡាញ់ដ៏ស្មោះស្ម័គ្រ (១:៨; ២:២០; ៣:១០) ។
- តួនាទី ដែលនាងរស់ព្រមចុះចូលជាមួយនឹងម្ដាយក្មេករបស់នាង និងស្មោះស្ម័គ្រស្ដាប់បង្គាប់តាមនោះ ឃើញមានការល្អកើតឡើងចំពោះនាង ។

សូមព្រះអង្គប្រទានពរ មកឲ្យយើងរាល់គ្នាទាំងប្រុសទាំងស្រី នូវចរិតលក្ខណៈ និង ជំនឿរបស់នាងរស់ នៅពេលដែលយើងសិក្សាពីជំនឿ និង ចរិតលក្ខណៈរបស់នាង សូមឲ្យយើងដើរតាមលំអាននៃជំហានរបស់នាងឲ្យបានល្អត្រឹមត្រូវ ។

---

(២០) *២:២០; ៣:៩; ៣:១២(២ ដង), ១៣(៤ ដង); ៤:១,៣,៤(៥ ដង), ៦(៥ ដង), ៧, ៨, ១៤ ។*

HONEYCOMB 1/2 (October 2000): 97–101

# Meet Noun Pheap

Mark FENDER



*Mr. Noun Pheap*

World War II had ended one year earlier. A couple living in Poyon village, Ta Moeun commune, Battambang district, gave birth to a son named Noun Pheap. He was the fifth of ten children—four boys and six girls. Pheap's parents were farmers who employed two servants—one man and one woman.

Pheap recalls being a very active boy. When his father's servant went with an ox-cart, he would cry and beg to go along. Because they all loved him, they often let him go. One day his father and the servants went with the ox-cart early in the morning to the rice paddy, and Pheap also went with them. On the way back home the ox-cart was loaded full with sheaves of rice. About two kilometers from his house, Pheap fell asleep and tumbled off the ox-cart in front of the wheel. This was very dangerous. As Pheap lay unmoving and semi-conscious on the ground, one ox kicked him so that he jerked his head out of the way just as a heavy wagon wheel was about to crush it. The wheel ended up running over only his finger, inflicting a scar that he still bears today. This close brush with death gave him the sense that some unseen power was protecting and preserving him for His purposes. The young Pheap fell off the cart not just this once, but on four occasions!

Pheap attended school for fifteen years. Pol Pot made him despair, since all his efforts at learning now seemed to be wasted. When the regime fell he returned to live with his family. In 1981 during the Republic of Kampuchea he started working with the postal service in Battambang district. He married in 1982, and fathered three children—two daughters and a son. Noun Kanya is now fourteen years old, Noun Kolyan is twelve, and his son Noun Boramy is ten. From 1982–84, he left for Phnom Penh to study how to work for the postal service. When he finished in early 1985, he was sent by the Ministry of Post to work as a director for the postal service in Pras Net Pras district in Battambang province.

He struggled in his heart because of jealousy over the prosperity and success of the wicked. This struggle, however, subsided to calmness, though he did not know how. He used to tell his family and friends, "In these times if there are 1,000 people like me who are not jealous of the wicked and try to be like them, the society will prosper and make good progress." He said this even before he knew there is one true God.

Another wonderful circumstance took place while he worked in the postal service in Phnom Penh. Why did he have no responsibility to inspect packages entering the country from

abroad? Why did he have such responsibilities only in Pras Net Pras?

In 1986–87 there were three to four hundred packages coming in Pras Net Pras Postal service. One was filled with Christian tracts and booklets about the "Only True God."

Intrigued by this booklet, Pheap asked the owner of the package if he could have a copy. Pheap was able to read this booklet and compare it with the Bible. He especially remembers that Isaiah 57:20 likened the wicked to the restless, tossing sea that stirs up dirt and mire. Pheap compared this image of an unsettled, rough, and dirty life with his own experiences of drinking and dancing. After reading this booklet, in late 1989 Pheap visited his village to find a way to change his work place. When he reached his home village and met his relatives he received an audiotape from his uncle, who was a pastor in the United States. This tape again communicated the message that Jesus is the only true God, confirming what Pheap had read in the booklet.

In 1989 the Ministry of Post transferred Pheap to Battambang. This was the result of the Holy Spirit's work in his life. He felt restless and took a *reemock-moto* to Chkae Koun, about seven kilometers from where he lived. He went there to visit some Christians who lived there before the fall of Cambodia. There were believers in that area. He met with some church elders, and they gave him a Bible and hymnal. He spent a whole morning in Chkae Koun to receive instruction on how to use these books.

He traveled to Chkae Koun for five weeks to worship the Lord with them. Later, he and his relatives decided to use a house in which to worship. For more than one year he worshiped the Lord, but did not yet decide to give his life to Jesus. Finally, in 1990, without a pastor present to give any kind of instruction or invitation, Pheap knelt, confessed his sin, and gave his life to Jesus. His family joined him in following Christ a few months later.

In 1991 his American pastor uncle came to visit. He told his uncle, "Our relatives and neighbors need Jesus." He asked if his uncle could erect a small building in which to worship God. His uncle was so excited and he answered, "Our God not only can

provide a small building, but He can provide His children a church where they can worship Him happily."

After his conversion, Pheap began a church called Bethany Church near the Battambang district post office. He focused his ministry primarily on his relatives, but with uncles, nephews, cousins, etc., this became a sizeable number of people—around three hundred.

Pheap took up study with Theological Education by Extension (TEE) materials in the early 1992, and continued for about three years. TEE is a decentralized system of biblical and theological education that takes training to pastors in ministry, rather than requiring potential leaders to come to a central institution. After some study with this material, Pheap felt that Jesus was close to him, and that Jesus had become real in his life. After he finished TEE grade four, he began teaching the materials to others. Pheap was chosen by the Christian and Missionary Alliance (CMA) to be the regional TEE director responsible for four provinces in northwest Cambodia.

Eventually Jeff Williams, a CMA missionary active in TEE, asked Pheap to join the Theological Education by Extension Association of Cambodia (TEEAC). Pheap did not immediately agree, but asked Jeff to pray for him for about three months. He finally joined in July 1997. TEEAC is an association designed to facilitate and promote the ongoing development of TEE in Cambodia. It is responsible for standardizing policy and procedures, stipulating accreditation standards, producing study materials, and networking among different ministries using the TEE system. Pheap fulfills an administrative role in TEEAC's Phnom Penh office. Through this work, he wants to be involved in training church leaders, strengthening them so that they can in turn train others.

His involvement in TEEAC meant leaving his peaceful village life for the more tense, expensive lifestyle of Phnom Penh. Pheap was willing to make this sacrifice in order to serve God in this way. His family was supportive, and they share this sense of God's direction to Phnom Penh. Every night they praise God and

study together before going to sleep. Pheap's ministry in the capital also allowed him to help with some newly planted churches, and to teach in five different places using the TEE material. He has been especially involved with the Jerusalem Church in Phnom Penh.

Pheap has a passion to be involved in the Lord's work. When asked what the most difficult part of being a Christian is, he did not respond by addressing issues of temptation, social pressures, or persecution. The biggest challenge Pheap mentioned was the difficulty of converting devoted Buddhists to the Christian faith. Obviously, this man loves to share the gospel! In fact, the his greatest joy comes when he shares God's message and people respond to the gospel by putting faith in Christ. Pheap is willing to travel significant distances if it means people may respond to the good news about Jesus Christ. Lately, he has been encouraged by the life and ministry of the apostle Paul, since Paul was willing to endure many things for the sake of the work that God had called him to do. On a recent mission trip, the taxi that Pheap was in had an accident and went onto the other side of the road. This incident reminded him that the apostle Paul, too, endured shipwrecks and other hardships as he pursued the ministry the Lord had laid out for him.

As Pheap looks to the future, he hopes for more involvement in TEE ministry from other church leaders. In fact, he is hoping that from 1,000 to 1,500 students will enroll in TEE training programs. Pheap would appreciate your prayers that God would bless the ministry of TEEAC. The association especially needs financial support for the work of translating TEE materials. Also, there is a need for additional teachers in grades two through four of the TEE system. Clearly, God is using this faithful servant to lead others to Christ and raise additional leaders in the church in Cambodia.

សំណុំទឹកឃ្មុំ ១/២ (តុលា ២០០០)៖ ១០២-១០៨

# ការជួបជាមួយលោកគ្រូ នួន ភាព

****************

ដោយ លោក ម៉ាក ហ្វេនឌើ



*លោកគ្រូ នួន ភាព*

មុនសង្គ្រាមលោកទី ២ បានរលត់រលាយផុតទៅ អស់រយៈពេលមួយ ឆ្នាំ នៅក្នុងសហគមន៍មួយ ក្នុងភូមិប៉ោយយង់ ឃុំតាម៉ឺន ស្រុកបាត់ដំបង មានគ្រួសារមួយនៅក្នុងភូមិនោះ ។ គ្រួសារនោះបង្កើតបានកូនប្រុសម្នាក់ ឈ្មោះ នួន

ភាព ។ គាត់ជាកូនទីប្រាំ នៅក្នុងចំណោមបងប្អូនទាំងដប់នាក់របស់គាត់គឺមាន ប្រុស ៤ នាក់ និង ស្រី ៦ នាក់ ។ ឪពុកម្ដាយ របស់លោកគ្រូ នួន ភាព ជាកសិករ គាត់មាន ជើងឈ្នួល ២ នាក់ ប្រុសម្នាក់ ស្រីម្នាក់ ។

កាលពីនៅកុមារភាពលោកគ្រូ នួន ភាព ចងចាំបានថា គាត់ជាក្មេងម្នាក់ ដែលរពឹសណាស់ ។ ពេលឪពុកគាត់ ឬ ជើងឈ្នួលបររទេះទៅណាមកណា គាត់ តែងតែយំទារទៅជាមួយ ព្រោះពួកគេស្រឡាញ់គាត់ណាស់ ។ ថ្ងៃមួយឪពុកគាត់ និង ជើងឈ្នួល បររទេះចេញពីព្រលឹមទៅដឹកកណ្ដាប់នៅឯស្រែ លោកគ្រូ នួន ភាព ក៏ទៅជាមួយដែរ ។ ពេលរទេះផ្ទុកកណ្ដាប់ពេញត្រឡប់ទៅទីលានបញ្ជាន់ ស្រូវដែលចម្ងាយប្រហែល ២គីឡូម៉ែត្រ លោកគ្រូ នួន ភាព ក៏ងងុយដេក ក៏ងក់ ធ្លាក់ពីលើរទេះចំពីមុខកង់រទេះ ។ នេះជាហេតុការណ៍ប្រកបដោយគ្រោះថ្នាក់ដល់ ជីវិត ។ ម្ដងនេះហើយ ដែលកង់រទេះផ្ទុកធ្ងន់ដោយកណ្ដាប់ស្ទើរតែកិនក្បាល របស់គាត់ស្លាប់ ពេលនោះគាត់គិតថាជាសំណាងល្អដោយគោវាភ្ញាក់ធាក់គាត់មួយ ជើង កង់រទេះដ៏ធ្ងន់នេះទំពារបានត្រឹមតែម្រាមដៃមួយមានស្លាកស្នាម រហូតដល់ សព្វថ្ងៃ ។ ការធ្លាក់ចំពីមុខកង់រទេះលើកនេះ គាត់ហាក់ដូចជាបាត់ស្មារតីមិនដឹង ខ្លួនសោះ គ្រោះថ្នាក់ប៉ឹះៗស្លាប់នេះធ្វើឲ្យគាត់គិតថាប្រហែលជាមានអំណាចអ្វីមួយ ដែលមើលមិនឃើញថាតើនរណាមួយដែលការពារឲ្យរួចពីគ្រោះថ្នាក់នេះ ។ គ្រោះ ថ្នាក់នេះកម្រួចជីវិតណាស់ ព្រោះធ្លាក់ចំពីមុខកង់រទេះ ។ គាត់ដឹងយ៉ាងច្បាស់ថា ព្រះអាទិករ ដែលប្រកបដោយសេចក្ដីស្រឡាញ់ ព្រះអង្គបានគ្រប់គ្រងមើលថែ និង ការពារព្រមទាំងថែបំរុងគាត់ ទុកសំរាប់ផែនការនៃព្រះរាជបំណងរបស់ព្រះអង្គ ។ កុមារ នួន ភាពមិនគ្រាន់តែធ្លាក់របៀបនេះតែម្ដងនោះទេ តែមានគ្រោះ ថ្នាក់បែបនេះ ៤ ដង ឯណោះ ។

គាត់បានចូលរៀននៅសាលារៀនអស់ រយះ ១៥ ឆ្នាំ ។ ប៉ុល ពត បានធ្វើ ឲ្យរលាយសេចក្ដីសង្ឃឹមរបស់គាត់ ដោយព្រោះគាត់គិតថាចំណាយពេល ឥត ប្រយោជន៍ ដើម្បីសិក្សា ។

នៅពេលរបប ប៉ុល ពត បានរលត់រលាយទៅ គាត់បានទៅរស់នៅជួបជុំ គ្រួសារឡើងវិញ ។ នៅក្នុងឆ្នាំ ១៩៨១ គាត់ចាប់ផ្ដើមធ្វើការនៅប៉ុស្ដិ៍ប្រៃសណីយ៍ ស្រុក បាត់ដំបង ក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ គាត់បានរៀបការ ក្នុងឆ្នាំ ១៩៨២ មាន កូន ៣ នាក់ កូនស្រី ២ នាក់ និង កូនប្រុសម្នាក់ ។ កូនស្រី

ច្បង ឈ្មោះ នួន កន្យា អាយុ ១៤ ឆ្នាំ កូនស្រីបន្ទាប់ឈ្មោះ នួន កល្យាណ អាយុ ១២ ឆ្នាំ និង កូន ប្រុស ពៅ នួន បូរ៉ាមី អាយុ ១០ ឆ្នាំ ។ ពីចុងឆ្នាំ ១៩៨២ ដល់ ១៩៨៤ គាត់ចេញទៅរដ្ឋធានីភ្នំពេញ ចូលសិក្សាបច្ចេកទេសអាជីវកម្មប្រៃសណីយ៍ ពេលបញ្ចប់ការសិក្សាដើមឆ្នាំ ១៩៨៥ ក្រសួងបានផ្លាស់គាត់ទៅបង្កើតប៉ុស្តិ៍ប្រៃសណីយ៍ថ្មីនៅស្រុកព្រះនេត្រព្រះ ក្នុងខេត្តបាត់ដំបង ។

គាត់បាននិយាយប្រាប់យើងពីទឹកចិត្ត ផ្ទាល់របស់គាត់ ឲ្យយើងបានដឹងពីការប្រយុទ្ធប្រឆាំងនឹងជម្រៅចិត្តខាងក្នុង ហើយបង្ហាញឲ្យយើងឃើញពីការដោះស្រាយចម្ងល់ជាច្រើន ដែលកើតឡើង ដោយសារការច្រណែន ព្រោះគាត់បាននិយាយថាហេតុអ្វីបានជា មនុស្សអាក្រក់ចេះតែមានស្តុកស្តម្ភ និង ចំរើនឡើង ។ នៅពេលនោះគាត់បានប្រាប់យើងថា គាត់បានបំប្រែសេចក្តីក្តៅក្រហាយនេះមកជាសេចក្តីស្ងប់ស្ងៀមវិញ មិនដឹងជាមូលហេតុអ្វី មកអង្រួនចិត្តគាត់ ។ លោកគ្រូបាន និយាយទៀតថា "មនុស្សនៅសម័យនេះ បើបានប្រហែលខ្ញុំ ១០០០ នាក់នោះ សង្គមរីកចំរើនហើយ" ។ ពាក្យនេះ គាត់តែងតែនិយាយប្រាប់ប្រពន្ធកូន និង មិត្តសម្លាញ់របស់គាត់មិនដែលដាច់ មុនពេលដែលគាត់មិនទាន់ដឹងថាមានព្រះពិតតែមួយនៅឡើយទេ ។

ការអស្ចារ្យមួយទៀត ហេតុអ្វីក៏កាលពីគាត់ធ្វើការនៅប៉ុស្តិ៍ប្រៃសណីយ៍នៅភ្នំពេញ គាត់គ្មានមុខងារត្រួតពិនិត្យកញ្ចប់ផ្ញើមកបរទេស? ចុះនៅប្រៃសណីយ៍ស្រុកព្រះនេត្រព្រះវិញ ហេតុអ្វីក៏គាត់មានមុខងារត្រូវត្រួត ពិនិត្យកញ្ចប់ផ្ញើមកពីបរទេសវិញ? ។

នៅឆ្នាំ ១៩៨៦ ដល់ ១៩៨៧ ក្នុងមួយឆ្នាំៗ កញ្ចប់ប្រៃសណីយ៍ផ្ញើចូលប៉ុស្តិ៍ស្រុកព្រះនេត្រព្រះ ពី ៣០០ ទៅ ៤០០ កញ្ចប់ ។ មានកញ្ចប់មួយ មានសុទ្ធតែខិត្តប័ណ្ណ និង សៀវភៅព្រះពិតតែមួយ ។

ដោយមានការចាប់អារម្មណ៍ និង កូនសៀវភៅនោះ គាត់ក៏បានសុំម្ចាស់គេមួយក្បាល ។ គាត់អានសៀវភៅនោះ អានចុះអានឡើងរៀងរាល់ថ្ងៃ ក៏ពើបប្រទះឃើញចំណាងជើងមួយនៅ អេសាយ ៥៧:២០ ដែលចែងប្រៀបធៀបមនុស្សអាក្រក់ ប្រៀបទៅនឹងទឹកសមុទ្រ ដែលចេះតែកំរើក ឥតមានស្ងប់ឡើយ ហើយទឹកនោះចេះតែបារល្បប់ និង ភក់ឡើង ។ គាត់ក៏បានប្រៀបធៀបជីវិតរបស់គាត់ និង ជីវិតមនុស្សច្រើនទៀតដែលអាក្រក់ ហេតុអ្វី? ព្រោះតែទឹកសមុទ្រមិនចេះ

ស្ងប់ឡើយ ។ ជីវិតគាត់ផ្លាល់ជាជីវិតមួយចង់សប្បាយជាមួយមិត្តភក្តិ ស៊ីផឹកជប់លៀងរាំរែក ដែលគាត់គិតថាជាការអាក្រក់ណាស់ ។ បន្ទាប់ពីអានកូនសៀវភៅព្រះពិតតែមួយចប់នៅចុងឆ្នាំ ១៩៨៩ គាត់ក៏ទៅលេងស្រុកកំណើត ដើម្បីស៊ើបសួរពីការផ្លាស់ប្តូរកន្លែងធ្វើការផង ។ ពេលដល់ស្រុកកំណើតជួបជុំបងប្អូន ហើយគាត់ក៏បានទទួលខ្សែអាត់ម៉ាញ៉េពីឪពុកមារបស់គាត់ ដែលជាគ្រូគង្វាលនៅសហរដ្ឋអាមេរិក ។ ខ្សែអាត់នេះនិយាយទាក់ទង នឹងព្រះយេស៊ូគ្រីស្ទជាព្រះពិតតែមួយម្តងទៀត ដែលបញ្ជាក់បន្ថែមពីអ្វីៗទាំងអស់ ដែលគាត់បានអាននៅក្នុងកូនសៀវភៅ ។

នៅក្នុងឆ្នាំ១៩៨៩ សេចក្តីសំរេចរបស់ក្រសួងបានឲ្យគាត់ទៅបំរើការប្រៃសណីយ៍នៅស្រុកបាត់ដំបងវិញ ។ នេះជាលទ្ធផលមួយដែលព្រះវិញ្ញាណបរិសុទ្ធបណ្តាលឲ្យជីវិតគាត់ នៅមិនសុខក៏នាំបងប្អូនជិះមួយរ៉ឺម៉កម៉ូតូទៅ ភូមិ ឆ្កែកូនចម្ងាយ៧គីឡូម៉ែត្រ ដើម្បីទៅសាកសួរគ្រីស្ទបរិស័ទនៅទីនោះ ព្រោះនៅពីសង្គមមុននៅភូមិនោះគេជឿព្រះយេស៊ូ ។ ពួកគាត់ក៏ជួបចាស់ទុំនៅទីនោះមែន គេក៏ឲ្យនូវព្រះគម្ពីរធំមួយក្បាល សៀវភៅចំរៀងទំនុកដំកើងមួយក្បាល ។ អស់រយៈពេលមួយព្រឹកនៅភូមិឆ្កែកូន ពួកគេបង្ហាត់របៀបបើកព្រះគម្ពីរ របៀបរកបទចំរៀងសរសើរដំកើងព្រះ ។

គាត់ធ្វើដំណើរទៅភូមិឆ្កែកូន អស់រយៈ៥សប្តាហ៍ទៅជួបជាមួយក្រុមជំនុំ ។ ក្រោយមកគាត់ និង ពួកបងប្អូនក៏សំរេចចិត្តយកផ្ទះមួយខ្នងថ្វាយបង្គំព្រះ ។ ក្នុងរយៈពេលជាង ១ ឆ្នាំ ក្នុងការថ្វាយបង្គំព្រះ គាត់នៅមិនទាន់សំរេចចិត្តថ្វាយខ្លួនទាំងស្រុងទៅព្រះពិតតែមួយនៅឡើយទេ ។ នៅក្នុងឆ្នាំ ១៩៩០ គ្មានគ្រូគង្វាលណាម្នាក់ប្រាប់គាត់ ឬ អញ្ជើញគាត់ឲ្យថ្វាយខ្លួនឡើយ គឺគាត់លុតជង្គង់ចុះឱនក្បាលចំពោះព្រះយេស៊ូ សារភាពអំពើបាប ហើយថ្វាយជីវិតគាត់ទៅព្រះយេស៊ូដោយខ្លួនឯង ។ ប៉ុន្មានខែក្រោយមក ប្រពន្ធគាត់ក៏ថ្វាយជីវិតដល់ព្រះគ្រីស្ទដែរ ។

នៅឆ្នាំ ១៩៩១ ឪពុកមារបស់គាត់ជាគ្រូគង្វាលនៅសហរដ្ឋអាមេរិកបានមកលេង គាត់បាននិយាយប្រាប់ឪពុកមារបស់គាត់ថា “បងប្អូនយើងព្រមទាំងអ្នកជិតខាង គេកំពុងត្រូវការព្រះយេស៊ូ” ។ គាត់សួរថាតើលោកមាអាចជួយធ្វើរោងមួយសំរាប់ថ្វាយបង្គំព្រះបានទេ? ។ លោកមាគាត់មានចិត្តរំភើបណាស់ គាត់បានឆ្លើយ

ថា "ព្រះនៃយើងមិនមែនមានត្រឹមតែរោងទេ គឺមានព្រះវិហារសំរាប់កូនព្រះអង្គថ្វាយបង្គំយ៉ាងអរសប្បាយផង" ។

ពេលនោះលោកគ្រូ នួន ភាព និង បងប្អូន គាត់ចាប់ផ្តើមបង្កើតព្រះវិហារមួយឈ្មោះបេថានី ដើម្បីថ្វាយសិរីរុងរឿងដល់ព្រះយេស៊ូ ចំពីមុខសាលាស្រុកបាត់ដំបងកាលពីសម័យមុន ។ គាត់ផ្តោតយកចិត្តទុកដាក់លើកិច្ចការ របស់គាត់ជាដំបូងលើសាច់ញាតិរបស់គាត់ដូចជាមាមីង បងប្អូនជីដូនមួយ និងក្មួយៗជាដើម ។ កិច្ចការនេះព្រះបានធ្វើឲ្យមានការរីកចំរើនឡើង មានមនុស្ស ជាច្រើនថ្វាយខ្លួនជាង ៣០០ នាក់ បានអង្គុយថ្វាយបង្គំព្រះ ។

គាត់បានផ្តើមរៀន ធីអ៊ីអ៊ី នៅក្នុងឆ្នាំ១៩៩២ រហូតមកអស់រយៈពេលជាង៣ឆ្នាំ ។ ធីអ៊ីអ៊ី គឺជាប្រព័ន្ធរៀនព្រះគម្ពីរបំបែកជាផ្នែកៗ និងការអប់រំផ្នែកវិជ្ជាព្រះ/ ទេវសាស្ត្រដែលអប់រំហ្វឹកហ្វឺនដល់គ្រូគង្វាលទាំងឡាយ ដែលកំពុងបំរើព្រះជាម្ចាស់ដោយមិនតម្រូវឲ្យអ្នកដឹកនាំទាំងនោះ មករៀននៅវិទ្យាស្ថានក្នុងទីក្រុងឡើយ ។ បន្ទាប់ពីគាត់បានរៀនមេរៀនខ្លះតាមរយៈមេរៀន ធីអ៊ីអ៊ី គាត់មានអារម្មណ៍ថាព្រះយេស៊ូគង់នៅជិតគាត់ ហើយដឹងថា ព្រះយេស៊ូពិតជាគង់នៅក្នុងជីវិតគាត់មែន ។ បន្ទាប់រៀនមេរៀន ធីអ៊ីអ៊ី ចប់កម្រិតទី ៤ គាត់ក៏ចាប់ផ្តើមប្រើមេរៀននេះបង្រៀនដល់អ្នកដទៃ ។ លោកគ្រូ នួន ភាព បានទទួលកាតតែងតាំងដោយអង្គការគ្រីស្ទបរិស័ទមួយឈ្មោះថា ស៊ីអឹមអេ ឲ្យធ្វើជាអ្នកទទួលខុសត្រូវផ្នែកមេរៀន ធីអ៊ីអ៊ី ប្រចាំតំបន់ដែលមាន ៤ ខេត្តនៅក្នុងភូមិភាគពាយព្យនៃប្រទេសកម្ពុជា ។

ចុងក្រោយមកលោក ជេហ្វវិលីយ៉ាំ ដែលជាបេសកជន/សាសនទូត ដ៏សកម្មម្នាក់ផ្នែកមេរៀន ធីអ៊ីអ៊ី របស់អង្គការ កាម៉ា បានសុំឲ្យលោកគ្រូ នួន ភាព ឲ្យចូលរួមនៅក្នុងសមាគម ធីអាក់ ។ លោកគ្រូ នួន ភាព មិនបានទទួលយល់ព្រមភ្លាមទេ ប៉ុន្តែគាត់បានសុំឲ្យលោក ជេហ្វ ជួយអធិស្ឋានឲ្យគាត់ អស់រយៈពេលប្រហែល ៣ ខែ ។ ទីបំផុតគាត់ក៏យល់ព្រមចូលបំរើការក្នុងសមាគមនេះ នៅខែកក្កដា ឆ្នាំ១៩៩៧ ។ ធីអាក់ គឺសមាគមមួយ ដែលគេបង្កើតឡើង ដើម្បីសម្របសម្រួលដល់ផ្នែកអភិវឌ្ឍន៍របស់មេរៀន ធីអ៊ីអ៊ី ដែលកំពុងដំណើរការនៅតាមតំបន់ឆ្ងាយៗនៅក្នុងប្រទេសកម្ពុជា ។ សមាគមនេះមានការទទួលខុសត្រូវសំរាប់រៀបចំគោលច្បាប់ជាមាត្រដ្ឋាន ផ្តល់យល់ព្រមទទួលស្គាល់ជាមាត្រដ្ឋានគំរូ ផលិតសម្ភារៈសិក្សា ហើយនិងធ្វើការទំនាក់ទំនងជាមួយនឹងព័ន្ធកិច្ចផ្សេងៗដែលប្រើ

ប្រព័ន្ធមេរៀន ធីអ៊ីអ៊ី ។ លោកគ្រូ នួន ភាព មានតួនាទីជាអ្នកកាន់ការផ្នែករដ្ឋបាល នៅក្នុងការិយាល័យសមាគម ធីអាក់ ក្រុងភ្នំពេញ ។ តាមរយៈកិច្ចការនេះ គាត់ចង់ធ្វើការចូលរួមក្នុងការហ្វឹកហ្វឺន ដល់អ្នកដឹកនាំពួកជំនុំព្រមទាំងជួយពង្រឹងពួកគេ ដើម្បីឲ្យគេអាចហ្វឹកហ្វឺនបន្តឲ្យអ្នកដទៃទៀត ។

ការព្រមចូលរួមបំរើការនៅក្នុងសមាគម ធីអាក់ គឺបានន័យគាត់ព្រមចាកចេញពីភូមិស្រុក ដែលធ្លាប់រស់នៅដោយសុខសាន្ត មករស់នៅក្នុងជីវភាពមួយដ៏តានតឹង ដែលអ្វីៗក៏ថ្លៃដែរនៅក្នុងទីក្រុងភ្នំពេញ ។ លោកគ្រូ នួន ភាព ស្ម័គ្រចិត្តព្រមធ្វើការលះបង់ ដើម្បីបំរើព្រះទោះបីជាលំបាកបែបនេះក៏ដោយ ។ គ្រួសាររបស់គាត់ ព្រមគាំទ្រគំនិតរបស់គាត់ ដែលគាត់ព្រមមកធ្វើការនៅទីក្រុងភ្នំពេញ ដោយដឹងពិតប្រាកដថា នេះជាការដឹកនាំរបស់ព្រះជាម្ចាស់ ។ រៀងរាល់យប់គ្រួសាររបស់គាត់តែងតែសរសើតម្កើងព្រះ និង សិក្សាព្រះគម្ពីរជាមួយគ្នា មុនពេលចូលសំរាន្ត ។ ព័ន្ធកិច្ចបំរើព្រះរបស់លោកគ្រូ នួន ភាព នៅក្នុងទីក្រុងនោះ អាចអនុញ្ញាតឲ្យគាត់មានឱកាស ទៅជួយដល់អ្នកដែលទើបនឹងបង្កើតព្រះវិហារ ថ្មីៗ និង គាត់បានទៅជួយពង្រឹងពួកជំនុំ ៥ កន្លែងផ្សេងៗទៀតដោយប្រើមេរៀន ធីអ៊ីអ៊ី ។ ជាពិសេសនៅក្នុងទីក្រុង ភ្នំពេញ គាត់បានចូលរួមថ្វាយបង្គំព្រះនៅជាមួយព្រះវិហារយេរូសាឡឹម ។

លោកគ្រូ នួន ភាព មានចិត្តឆេះឆួលចង់បំរើការងាររបស់ព្រះជាម្ចាស់ ។ នៅ ពេលដែលយើងសួរគាត់ថា តើមានអ្វី ដែលធ្ងន់ធ្ងរលំបាកបំផុត? គាត់មិនបានឆ្លើយថា គឺជាសេចក្តីល្បួង បញ្ហាសង្គមតាបសង្កត់ ការបៀតបៀន ជាពិសេសថវិកាគ្រួសារនោះទេ ។ បញ្ហាធំបំផុត ដែលគាត់បានលើកឡើងនោះ គឺការពិបាកក្នុង ការនាំពុទ្ធសាសនិកជន ដែលជឿស៊ប់លើទំនៀមទំលាប់ ពួកជឿអារក្សអ្នកតា ពួកដែលមិនជឿលើអ្វីទាំងអស់មកជឿលើ ព្រះយេស៊ូ ។ ពិតប្រាកដណាស់ បុរសម្នាក់នេះពិតជាស្រឡាញ់ក្នុងការផ្សាយដំណឹងល្អ! តាមពិតទៅអំណរដ៏ខ្លាំងបំផុតរបស់គាត់នោះ គឺនៅពេលដែលគាត់ផ្សាយដំណឹងល្អ ហើយមានមនុស្សព្រមទទួលជឿព្រះគ្រីស្ទ គាត់មានចិត្តឆេះឆួល ក្នុងការផ្សាយដំណឹងល្អ មនុស្សជាច្រើនបានថ្វាយខ្លួន ដោយសារដំណឹងល្អ ដែលគាត់បានផ្សាយ ។ លោកគ្រូ នួន ភាពស្ម័គ្រចិត្តធ្វើដំណើរទៅកន្លែងឆ្ងាយៗ ឲ្យតែមានជាមនុស្សព្រមទទួលដំណឹងល្អស្តីពីព្រះយេស៊ូគ្រីស្ទ ។ នៅពេលថ្មីៗនេះ គាត់ទទួលបានការលើកទឹកចិត្តយ៉ាង

ខ្លាំងតាមរយៈជីវិតរស់តាមព័ន្ធកិច្ចបំរើព្រះរបស់សាវ័កប៉ូល ដោយហេតុថា លោកប៉ូលស្ម័គ្រចិត្តទ្រាំទ្រនៅគ្រប់ការលំបាកទាំងឡាយ ដោយព្រោះតែការងារ ដែលព្រះបានត្រាស់ហៅឲ្យគាត់មកបំរើ ។ នៅពេលដែលគាត់ធ្វើដំណើរបំពេញបេសកកម្ម ឡានតាក់ស៊ីដែលគាត់បានជិះមានគ្រោះថ្នាក់ក្រឡាប់ទៅម្ខាងផ្ទល់ម្ខាងទៀត ។ ឧប្បត្តិហេតុនេះ ធ្វើឲ្យគាត់នឹកឃើញទៅដល់សាវ័ក ប៉ូល ដែលត្រូវរងទ្រាំលំបាកដោយសារកប៉ាល់លិច និងដោយសារទុក្ខលំបាកដទៃទៀត តែគាត់នៅតែខំមមុលទៅមុខក្នុងការបំរើព្រះអម្ចាស់ ចំពោះកិច្ចការដែលទ្រង់ប្រទានឲ្យគាត់ ។

ចំពោះថ្ងៃអនាគតគាត់សង្ឃឹមថានឹងមានការចូលរួមមកពីព័ន្ធកិច្ច និង ពួកអ្នកដឹកនាំក្រុមជំនុំដទៃទៀតកាន់តែច្រើនឡើង ក្នុងការប្រើមេរៀន ធីអ៊ីអ៊ី ។ តាមពិតទៅគាត់សង្ឃឹមថា មានសិស្សពី ១០០០ ទៅ ១៥០០ នាក់នឹងមកចុះឈ្មោះរៀនតាមកម្មវិធីហ្វឹកហ្វឺន ធីអ៊ីអ៊ី ។

សូមជួយអធិស្ឋានដល់ពួកគាត់សូមឲ្យព្រះជួយដល់ព័ន្ធកិច្ចសមាគម ធីអ៊ីអ៊ីកម្ពុជា ជាពិសេសសេចក្ដីត្រូវការផ្នែកថវិកាសំរាប់ការបកប្រែមេរៀន ធីអ៊ីអ៊ី ។ ហើយក៏សូមជួយអធិស្ឋានឲ្យមានគ្រូបង្ហាត់បន្ថែមទៀត នៅក្នុងកំរិត ២ រហូតដល់កំរិត ៨ នៃប្រព័ន្ធហ្វឹកហ្វឺនតាមមេរៀន ធីអ៊ីអ៊ី ។ ពិតប្រាកដណាស់ព្រះជាម្ចាស់នឹងប្រើបាវបំរើដ៏ស្មោះត្រង់នេះ ដើម្បីដឹកនាំអ្នកដទៃ ឲ្យទទួលជឿព្រះគ្រីស្ទ នឹងដើម្បីបន្ថែមឲ្យមានអ្នកដឹកនាំជាច្រើនទៀត នៅក្នុងពួកជំនុំក្នុងប្រទេសកម្ពុជា ។